ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩**
**សវនាការលើកទី៥១**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍
*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង
លោកស្រី សែ កុលវុឌ្ឍី
លោក ម៉ាតូ គ្រីស្តារ *(Mr. Matteo Crippa)*
កញ្ញា ណាតាចា វិចស៊ែល រីសឺ
*(Ms. Natacha Wexels-Riser)*
លោក អាឡាញ ប្រែអត *(Mr. Aline BRIOT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អានីស អះមេដ *(Mr. Anees AHMED)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំពែល *(Mr.Zachery LAMPEL)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ទី ស្រីនណា

កញ្ញា ម៉ុច សុវណ្ណារី

លោក គឹមម៉េងឃី

លោក គង់ ពិសី

លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៉ែនណឺ*(Mr. Alain Werner)*

**មេធាវីជំនួយការរបស់សាក្សី៖**

លោក គង់ សំអុន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

### លោក សួស ធី


សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៤

សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្តើមពី ....................ទំព័រ ១៣

សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................ទំព័រ ២០

សួរដោយ លោក តាន់ សេណារ៉ុង ផ្តើមពី ....................ទំព័រ ២៦

សួរដោយ លោក អានីស អះមេដ ផ្តើមពី....................ទំព័រ ៣២

សួរដោយ លោក ហុង គីមសួន ផ្តើមពី ....................ទំព័រ ៣៧

សួរដោយ លោក គីមម៉េងឃី ផ្តើមពី....................ទំព័រ ៤៣

សួរដោយ លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី ផ្តើមពី ....................ទំព័រ ៤៧

សួរដោយ កញ្ញា ទី ស្រ៊ីនណា ផ្តើមពី ....................ទំព័រ ៥១

សួរដោយ លោក ការ សាវុត្ថ ផ្តើមពី....................ទំព័រ ៥៥

សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ បន្តពី....................ទំព័រ ៦៥

សួរដោយ លោក ការ សាវុត្ថ បន្តពី ....................ទំព័រ ៦៦

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អានីស អះមេដ | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក សួស ធី | ខ្មែរ |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| ចៅក្រម ធូ មណី | ខ្មែរ |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |
| លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*[សាក្សីចូលកាន់បន្ទប់សវនាការ]*

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០៥:៥២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្តាប់សក្ខីកម្មសាក្សី សួស ធី ។

ដោយតាមរបៀបវារៈដែលបានគ្រោងទុក និងកាលវិភាគ គឺកាលពីម្សិលមិញយើងបានដំណើរការស្តាប់នូវសាក្សី សក្ខីកម្មរបស់សាក្សី សួស ធី ដោយអង្គជំនុំជម្រះ ហើយមិនទាន់ចប់ទេ ហើយព្រឹកនេះយើងបន្ត ដោយអង្គជំនុំជម្រះ-- លោកស្រីមេធាវី អាចរង់ចាំបន្តិច យើងនីតិវិធីផ្តើមមិនទាន់បានចប់នៅឡើយទេ ។

ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមាន ភាគី និងបុគ្គលដែលត្រូវបានកោះអញ្ជើញឲ្យចូលរួមក្នុងដំណើរការសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះមានវត្តមាន សាក្សី សួស ធី មានវត្តមាន ។ សាក្សី KW-15 ដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ពីសាក្សី សួស ធី មានវត្តមានរង់ចាំការកោះហៅពីអង្គជំនុំជម្រះ ។ សាក្សីនេះមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ សាក្សីបានស្បថរួចហើយ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ដែលប៉ុនប៉ងចង់និយាយបញ្ហាអ្វី សូមអញ្ជើញ ។

**លោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្គី៖**

សូមអរគុណ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម! ខ្ញុំសូមដាក់ពាក្យសុំដោយខ្លីការលើកឡើងដោយខ្លីទាក់ទងទៅនឹងសាក្សី សួស ធី តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំធ្វើដូច្នេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញ, ដាក់យ៉ាងម៉េចទៅ?

**លោកស្រី ស៊ីលយីស្ទូត ហ្សីនស្គី៖**

សូមអរគុណ ។ ពាក់ព័ន្ធទៅនឹងសាក្សីរូបនេះ គឺសាក្សី សួស ធី មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទីពីរ ដែលគាត់តំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ដែលគាត់មានការព្រួយបារម្ភទៅលើសក្ខីកម្មរបស់សាក្សីរូបនេះ ។ ដូច្នេះហើយ ស្នើសុំពេលវេលាបន្ថែមទៀត ដើម្បីធ្វើយ៉ាងណាឲ្យយើងអាចសួរទៅកាន់សាក្សីអំពីសំណួរជាក់លាក់ ដែលវាទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីពីររូប ។

សាក្សីបានធ្វើការចុះបញ្ជី ហើយគាត់ជាអ្នកគ្រប់គ្រងទៅលើបញ្ជីអ្នកទោស ហើយបញ្ជីទាំងអស់នោះ គឺយើងឃើញមានឈ្មោះស្វាមីរបស់កូនក្ដីរបស់យើងពីរនាក់មាននៅក្នុងបញ្ជីនោះ ហើយយើងខ្ញុំចង់សួរសំណួរជាក់លាក់ទៅកាន់សាក្សី ហើយការដែលយើងចង់សួរទៅកាន់សាក្សីនេះ គឺយើងមិនអាចធ្វើទៅបាន តាមរយៈពេលវេលាកំណត់ដែលយើងទទួលបាន ។ យើងទទួលបានរយៈពេលសែសិបនាទីចំពោះសាក្សីនេះ។ ដូច្នេះហើយយើងមានរយៈពេលតែសែសិបនាទីសួរសំណួរទូទៅ ហើយយើងមិនមានពេលវេលាជាក់លាក់ដើម្បីសួរទៅកាន់សាក្សីរូបនេះ ។ យើងខ្ញុំចង់តំណាងកូនក្ដីរបស់ខ្ញុំឲ្យមានភាពសមស្របនិងត្រឹមត្រូវ ហើយធ្វើយ៉ាងណាយើងចង់ធានាថា ផលប្រយោជន៍របស់កូនក្ដីរបស់យើងនោះ គឺអាចធ្វើទៅបាន ហើយយើងអាចសួរទៅកាន់សាក្សី ។ សាក្សីរូបនេះគឺជាសាក្សីតែមួយគត់ ដែលគាត់ធ្វើការងារលើបញ្ជីអ្នកទោស ។ ដូច្នេះហើយយើងខ្ញុំស្នើសុំអង្គសវនាការឲ្យធ្វើការផ្ដល់យើងខ្ញុំនូវពេលវេលាបន្ថែមដើម្បីធ្វើការសួរសំណួរជាក់លាក់ទៅកាន់សាក្សីរូបនេះ ដើម្បីឲ្យយើងខ្ញុំអាចបំពេញការងារ និងភារកិច្ចវិជ្ជាជីវៈរបស់យើងខ្ញុំ ។ ដូច្នេះហើយនេះគឺជាសំណើរបស់ខ្ញុំ ប៉ុន្តែយ៉ាងណាក៏ដោយយើងក៏យល់អំពីការផ្ដល់ពេលវេលាជាក់លាក់របស់លោក លោកស្រីចៅក្រមជូនយើងខ្ញុំ ដែលវាជាវិធានទូទៅដែលបានកំណត់ ហើយទោះបីជាវិធានទូទៅក៏ដោយ ក៏អនុញ្ញាតឲ្យយើងក្នុង-- ក៏យើងឃើញថាវាអាចមានអញ្ញត្រកម្មជាក់លាក់ណាមួយក្នុងលក្ខខណ្ឌពិសេស ។

ដូច្នេះហើយយើងខ្ញុំសូមបញ្ជាក់ថា យើងខ្ញុំស្នើសុំរយៈពេលបន្ថែមម្ភៃនាទីទៀត ដើម្បីឲ្យយើងខ្ញុំអាចសួរទៅកាន់សាក្សីរូបនេះនូវសំណួរជាក់លាក់ទាំងឡាយ ។ សូមអរគុណ ។

[០៩:១១:៣៤]

**ប្រធានអង្គជំនុំ៖**

សាជាថ្មីម្តងទៀត អង្គជំនុំជម្រះប្រកាន់ជំហរច្បាស់លាស់ គឺតម្កល់នូវសេចក្តីសម្រេចរបស់ខ្លួនដែលបានចេញរួចហើយ ជាពិសេសគឺសេចក្តីសម្រេចបញ្ជាក់អំពីការកំណត់ពេលវេលា កំហិតអំពីពេលវេលាកាលពីម្សិលមិញ នេះជាជំហររឹងមាំ ។ ប៉ុន្តែ ថ្ងៃនេះអង្គជំនុំជម្រះក៏បានពិនិត្យលទ្ធភាពនៅក្នុងការផ្តល់សក្ខីកម្មរបស់សាក្សីនេះ ដោយសារសាក្សីរូបនេះបានផ្តល់សក្ខីកម្ម ឬក៏នឹងផ្តល់សក្ខីកម្មដែលមានការពាក់ព័ន្ធទៅនឹងឯកសារ ហើយឯកសារជាច្រើនដែលនឹងត្រូវបង្ហាញនៅលើកញ្ចក់អេក្រង់ទូរទស្សន៍។ អ៊ីចឹងកាលពីពេលវេលាដែលបានកំណត់កាលពីសេចក្តីសម្រេចលើកមុនថា កម្រិតថយពេលវេលាសម្រាប់ស្តាប់សក្ខីកម្មសាក្សីនេះរយៈពេលមួយថ្ងៃ អង្គជំនុំជម្រះយល់បានពិភាក្សាឯកភាពគ្នាថា ពន្យារពេល ឬក៏បង្កើនពេលវេលាសម្រាប់ស្តាប់សាក្សីរូបនេះមួយថ្ងៃកន្លះ ដោយពេលវេលាសមាមាត្រនៃភាគីទាំងអស់គឺបង្កើនដូចគ្នា តាមកម្រិតពេលវេលាដែលបានចែកឲ្យសម្រាប់មួយថ្ងៃកន្លះ ។ មួយថ្ងៃ ភាគីតំណាងសហព្រះរាជអាជ្ញា សាមសិបមីនុត មួយថ្ងៃកន្លះសែសិបប្រាំមីនុត គឺគុណនឹងមួយកន្លះ ។ ចំណែកឯភាគីដើមបណ្តឹងរដ្ឋប្បវេណីសរុប គឺសែសិបមីនុត ឡើងដល់ហុកសិបមីនុត ហើយដូចគ្នា គឺមេធាវីការពារក្តីដូចគ្នាគឺហុកសិបមីនុតចំពោះករណីស្តាប់សាក្សីរូបនេះ ។ អ៊ីចឹងមិនប្រគល់ឲ្យដោយឡែកទេ គឺប្រគល់សរុប ធ្វើការបង្កើននូវសមាមាត្រនៃពេលវេលាទាំងខាងភាគី ។

គ្រប់ភាគីទាំងអស់នៅក្នុងរឿងនេះពេលវេលាសមាមាត្រ ហើយបើពិនិត្យភាពកើន ឬក៏ចាំបាច់ម្តែនាទីសម្រាប់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន-- ក្រុមទាំងបួនក្រុមនោះ គឺពិភាក្សាគ្នាទៅ ហើយគួរតែត្រូវបានជ្រើសរើសនូវសំណួរជាក់លាក់ដែលអាចមានប្រយោជន៍នៅក្នុងការស្វែងរកការពិតចៀសវាងការចោទសួរអួសបន្លាយ ឬក៏ធ្វើឲ្យមានការឃ្លាតឆ្ងាយ ឬចេញពីអង្គហេតុ ឬក៏សំណួរច្រំដែលនាំឲ្យខាតពេលវេលាឥតប្រយោជន៍ ។

ជាកិច្ចបន្ត គឺដំណើរការនីតិវិធីស្តាប់សក្ខីកម្ម ។ មន្ត្រីសោតទស្សន៍សូមបង្ហាញនូវឯកសារ ដែលមានលេខ ERN ជាភាសាខ្មែរ 00021134 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

ម៉េចទៅអាចធ្វើបានទេ? ធ្វើមិនបានរាយការណ៍ភ្លាម ពីមូលហេតុនៃការធ្វើមិនបាន មន្ត្រីផ្នែកខាងសោតទស្សន៍!

បញ្ចាំងបង្ហាញមកចំហៀងខាងកើត ចំហៀងខាងស្តាំ ។

ឡើងលើបាទ ឡើងលើ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក សួស ធី ពិនិត្យមើលឯកសារនេះ តើជាឯកសារយ៉ាងម៉េចទៅពាក់ព័ន្ធជាមួយនឹងការងាររបស់លោក? លោកអាចមើលឃើញទេ ឬក៏ទាមទារសូមឲ្យមានការបង្ហាញនូវឯកសារជាក្រដាស?

[០៩:១៧:៤៥]

**ឆ៖** ខ្ញុំបាទមើលឃើញហើយ មិនបាច់បង្ហាញជាក្រដាសទេ ។

**ស៖** ឯកសារនេះយ៉ាងម៉េចទៅ តាមលោកដែលជាធ្លាប់ធ្វើឯកសារ តើជាឯកសារដែលចេញដោយការងាររបស់លោកធ្វើនៅមន្ទីរស-២១ ដែរឬទេ?

**ឆ៖** ឯកសារនេះ គឺមិនមែនចេញដោយខ្ញុំធ្វើទេ នេះប្រហែលជាឯកសារនៅខាង មន្ទីរខាងម៉េង ឬខាងកងសួរចម្លើយ ពីព្រោះបញ្ជីនេះ ខ្ញុំអត់ដែលដាក់លេខមួយ លេខពីរ លេខបី រហូតដល់លេខ១៨បណ្ដោយអ៊ីចឹងទេ អត់ដែលធ្វើអ៊ីចឹងទេ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីផ្នែកខាងសោតទស្សន៍ដកឯកសារនេះចេញ ហើយដាក់ឯកសារដែលមានលេខ ERN 003 43200 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

អាចបង្រួញឲ្យតូចជាងហ្នឹងបន្តិចទៅ ដើម្បីមើលឃើញច្រើនផ្នែក ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក សួស ធី មើលឯកសារនេះមើល តើឯកសារនេះ គឺជាឯកសារដែលលោករៀបចំដែរឬទេ នៅមន្ទីរសន្តិសុខស-២១ នោះ?

**ឆ៖** ចំពោះឯកសារនេះ គឺរបៀបរបបធ្វើឯកសារ គឺវាខុសពីរបៀបរបបខ្ញុំធ្វើឯកសារ គឺខ្ញុំអត់បានដឹងទេ រឿងឯកសារនេះ មានតែមន្ទីររបស់ខាងសួរចម្លើយទេដែលគេធ្វើ ។

**ស៖** មន្ត្រីសោតទស្សន៍ដកឯកសារហ្នឹងចេញ ដាក់ឯកសារមួយទៀតដែលមានលេខ ERN00 21084-- 00021084 ។ លោក សួស ធី ពិនិត្យមើលឯកសារនេះ តើឯកសារចេញពីប្រភពណាមក ឬក៏ឯកសារលោកធ្វើ?

**ឆ៖** របៀបរបបធ្វើឯកសារនេះ គឺខ្ញុំបានធ្វើ ប៉ុន្តែខ្ញុំសូមបញ្ជាក់ការធ្វើឯកសារនេះ គឺពិតប្រាកដដែលខ្ញុំធ្វើ គឺចំពោះអាចុងក្រោយដែលគេដាក់ ផ្សេងៗកំពុងសួរនៅ គឺខ្ញុំអត់បានដឹងទេ គឺអាហ្នឹងគឺអត់ដឹងទេ ។ ប៉ុន្តែ របៀបរបបនេះបើសិនជាមានចំណារ ខាងផ្សេងៗមានដាក់ខាងចុងហ្នឹង គឺប្រហែលជា

អានេះខ្ញុំស្មានមិនច្បាស់ មានតែខាងមន្ទីររបស់ខាងកងស្នួរចម្លើយ គេមានអាចដាក់ខាងចុងនេះបាន ។ ចំពោះខ្ញុំវិញ គឺធ្វើឯកសារ បើថាចូលមក គឺមានតែរបៀបរបបអ៊ីចឹង ដាក់អ៊ីចឹង គឺដាក់ត្រឹមតែ អត់មានចុះខាងផ្សេងៗទេ ។

**ស៖** ចុះអក្សរសរសេរថា "ចប់" ចប់ជាអក្សរដៃ សរសេរដោយដៃហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** ហ្នឹងក៏ជា ក៏មិនមែនជាអក្សរខ្ញុំដែរ ។

**ប្រធានអង្គជំនុំ៖**

លោក ហ្សង់ម៉ាក មានបញ្ហាអីទៅ? សូមអញ្ជើញ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំសូមបំភ្លឺបញ្ហាយើងខ្ញុំភាគច្រើនអត់ចេះអានភាសាខ្មែរនោះទេ ដូច្នេះតើយើងអាចបញ្ជាក់នូវសេចក្ដីសង្ខេប ការសង្ខេបថា តើយើងបង្ហាញឯកសារអ្វីនៅក្នុងអេក្រង់របស់យើង? ខ្ញុំហាក់ដូចជាយល់ថាឯកសារ D80 គឺទាក់ទងទៅនឹងប្រវត្តិរូបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយឯកសារមួយនេះ គឺទាក់ទងទៅនឹងបញ្ជី ។ ដូច្នេះហើយ ខ្ញុំចង់ឲ្យបញ្ជាក់សង្ខេបយ៉ាងម៉េចខ្លះ ថាឯកសារហ្នឹងទាក់ទងយ៉ាងម៉េចខ្លះ ដើម្បីឲ្យវាបញ្ជាក់ទៅលើចំណុចទាំងអស់នេះនៅក្នុងប្រតិចារឹក គឺសូមឲ្យបញ្ជាក់ក្បាលចំណងជើង ។

**ប្រធានអង្គជំនុំ៖**

ឯកសារនេះ គឺចំណងជើងដាក់ថា "ផ្នែកមន្ទីរសេនាធិការ" ។ ដោយឯកសារមានជាច្រើនសែនឯណោះ ហេតុដូច្នេះហើយក៏វាមានបញ្ហារវាងថា ឯកសារនៅមន្ទីរស-២១ ដែលរៀបចំឡើងដោយសាក្សីរូបនេះ និងឯកសារប្រើប្រាស់នៅក្នុងមន្ទីរស-២១ ដែលរៀបចំដោយទីកន្លែងផ្សេងទៀត ហើយការបញ្ជាក់មួយចំនួនដើម្បីផ្ទៀងផ្ទាត់អំពីធៀបទៅនឹងចម្លើយសាក្សីមុនៗ ក៏ដូចជាចម្លើយរបស់ជនជាប់ចោទ ដូចជាឯកសារដែលមានរូបថត ជិន ម៉េត នោះគឺបានបង្ហាញរួចហើយ ថាទម្រង់បែបបទនេះ គឺរៀបចំឡើងដោយមន្ទីរសន្តិសុខស-២៤ ឬក៏មន្ទីរអប់រំកែប្រែសាជាថ្មីព្រៃស ដែលសាក្សីរូបនេះ ហៅថាមន្ទីរ ស-២១(ឃ) ប៉ុន្តែដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់ប៉ុណ្ណោះទេ ផ្ទៀងផ្ទាត់ ។

មន្ត្រីផ្នែកខាងសោតទស្សន៍សូមដកឯកសារហ្នឹងចេញ ហើយដាក់ឯកសារមួយទៀតដែលមានលេខ ERN00106309 ។

ឯកសារនេះ គឺមានចំណងជើងថា“បញ្ជីរាយឈ្មោះអ្នកទោសដែលបានផ្អាកក្នុងខែ១ ឆ្នាំ១៩៧៧” សូមបន្តទៅទំព័រមួយទៀតចុះបន្ទាប់ ។

លោក សួស ធី ពិនិត្យមើលឯកសារនេះដែលមានចំណងជើងអម្បាញ់មិញ ហើយនិងឯកសារនៅក្រដាសបន្ទាប់-- នៅទំព័របន្ទាប់នេះ ហើយនិងជាបន្តបន្ទាប់ទៀតយើងនឹងមើលបណ្តើរៗ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សំណួរសួរថា តើឯកសារនេះជាឯកសារដែលលោករៀបចំនៅក្នុងមន្ទីរសន្តិសុខស-២១ ឬក៏មិនមែនទេ?

**ឆ៖** ចំពោះឯកសារនេះ គឺខ្ញុំមិនបានរៀបចំទេ ពីព្រោះតែមានចូលដល់រឿងផ្អាក រឿងសួរហ្នឹង គឺរបស់-- ដែលមន្ទីររបស់កងសួចម្លើយហើយ គឺខាង ម៉េង ជាអ្នកធ្វើហើយ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍សូមដកឯកសារនេះចេញពីអេក្រង់ទូរទស្សន៍ ហើយដាក់ឯកសារដែលមានលេខ ERN ចាប់ពី 00087036 ។ ឯកសារនេះមានចំណងជើងថា ទីមួយគឺបញ្ជាក់ថាមន្ទីរស-២១ ហើយចំណងជើងឯកសារ “បញ្ជីមនុស្សចូលនៅថ្ងៃទី២៨ ខែ៤ ឆ្នាំ១៩៧៨ ហើយឈ្មោះ ទ្រឿង ធីង្វៀន អាយុ១៤ឆ្នាំ ភេទស្រី ធ្វើចម្ការ ជនជាតិយួន” (មើលដំឡើងមកលើដើម្បីមើលផ្នែកខាងក្រោម ខាងណោះនៅទំព័រអំមិញៗ! ឃើញ អូខេ)

**ស៖** សួស ធី មើលឯកសារនេះមើល តើជាឯកសារចេញពីមន្ទីរស-២១ ហើយលោកធ្វើទេ ហើយឯកសារគឺជាការបញ្ជីទទួលមនុស្សចូលនៅថ្ងៃទី២៨ ខែ៤ ឆ្នាំ១៩៧៨?

[០៩:៣២:១៨]

**ឆ៖** ឯកសាររបៀបនេះគឺ ខ្ញុំបានធ្វើពិតប្រាកដមែន ។

**ប្រធានអង្គជំនុំ៖**

សូមរំកិលទៅឯកសារបន្ទាប់មួយទៀត។ ឯកសារនេះគឺ មានទម្រង់ដូចគ្នា ហើយមានតាមលំដាប់លេខដូចគ្នា ជាមួយគ្នាទេ គ្រាន់តែយើងចង់បញ្ជាក់ដើម្បីឲ្យមានការ មានចំនួនច្រើនដើម្បីផ្ទៀងផ្ទាត់ ហើយក្នុងនេះគឺ មន្ទីរលេខដែលមាន-- ឯកសារដែលមានលេខ ERN00087037 ដាក់ថាមន្ទីរស-២១ បញ្ជីមនុស្សចូលនៅថ្ងៃទី២៨ ខែ៤ ឆ្នាំ១៩៧៨ ឈ្មោះដើម ទា ផល អាយុ២៩ឆ្នាំ ភេទប្រុស ប្រជាជនចាស់ ឃុំតាពៅ ស្រុកចន្ទ្រា តំបន់២៤៣ យួនកៀរឆ្នាំ-- ខែ១ ឆ្នាំ៧៨ សូមមើលផ្នែកខាងក្រោម!

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ចុះឯកសារនេះ លោក សួស ធី តើលោកយល់ថាយ៉ាងម៉េចដែរ ឯកសារនេះ?

**ឆ៖** ឯកសារដែលធ្វើតាមរបៀបរបបហ្នឹងគឺ ខ្ញុំហើយ ។

[០៩:៣៤:៣៥]

**ប្រធានអង្គជំនុំ៖**

មន្ត្រីផ្នែកខាងសោតទស្សន៍ដកឯកសារហ្នឹងចេញ ហើយដាក់ឯកសារថ្មីមួយទៀត ដែលមានលេខ ERN00021273 រហូតដល់ 00021274 ។

តទៀតៗ ទៅក្រោមទៀត ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ចុះឯកសារនេះ? មានទម្រង់អាចខុសគ្នាពីទម្រង់អម្បាញ់មិញ ប៉ុន្តែវាមានឈ្មោះលោក ហើយនិងនេះ-- ឯកសារនេះគឺដែលមានលេខ ERN 00021270 បញ្ជីមនុស្សចូលថ្ងៃទី២៤ ខែ៥ ឆ្នាំ ១៩៧៨ ដែលមានអ្នកចូលចំនួនបួននាក់ ហើយទទួលថ្ងៃទី២៤ ខែ៥ ឆ្នាំ១៩៧៨ អ្នកទទួល ធី ឯកសារនេះលោកយល់ថាម៉េចដែរ?

**ឆ៖** ឯកសារនេះគឺជារបៀបរបបរបស់ខ្ញុំធ្វើទាំងអស់ ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់បន្តិចដើម្បីឲ្យងាយយល់អំពីតាមរយៈបងផ្នែកក្រសួងស-៧១ អានេះតាមរយៈបងហ្នឹង គឺខ្ញុំវៃទៅតាមឯកសារដែលគេយកមនុស្សមក ហើយគេឲ្យបញ្ជីហ្នឹងមក ។ ហើយដូចពេលដែលយើងដែលគេយកមកបញ្ជីនាំមកហ្នឹងគេដាក់តាមរយៈ-- ប៉ុន្តែបើតាមខ្ញុំពិតដែលខ្ញុំទទួល គឺទទួលតែពី ហ៊ុយ ទេ អត់មានតាមគេអ្នកក្រៅមកទេ ពីព្រោះគេអ្នកក្រៅគេអត់មានសិទ្ធិចូលទៅក្នុងគុកទេ ។ ដូច្នេះ ផ្នែកតាមរយៈបងហ្នឹងគឺខាង ហ៊ុយ គេអ្នកទទួលមក ហើយគេឲ្យក្រដាសហ្នឹង ដើម្បីឲ្យខ្ញុំវៃចូលក្នុងបញ្ជី ឲ្យដឹងថាអ្នកទោសនេះមកតាមរយៈបងណា ហើយចំពោះខ្ញុំវិញ គឺមិនបានទទួលផ្ទាល់ពីអ្នកដែលបញ្ជូនមកទេ មានតែ ហ៊ុយ នៅខាងក្រៅទេ ។ ហើយបើតាមឯកសារដែលថា តាមរយៈបងក្រសួងស-៧១ហ្នឹង គឺខ្ញុំវៃទៅតាមដែលបញ្ជីដែលគេឲ្យឈ្មោះអ្នកទោសមក ។

**ស៖** បន្តទៅទៀត អាចឡើងលើបានទេ ។ ប្តូរទៅទំព័រផ្សេងបានទេ? លោកពិនិត្យមើលនូវឯកសារនេះដែលមានលេខ ERN00021273 ដល់ 00021274 ឯកសារនេះគឺនិយាយអំពីមនុស្សចូលថ្ងៃទី២៤ ខែ៥ ឆ្នាំ១៩៧៨ ដែរ ហើយដែលមានសរុបមនុស្សចំនួនម្ភៃប្រាំបួននាក់ ។ រុញមើលទំព័រទីពីរ

នេះគឺអ្នកប្រគល់គឺឈ្មោះ ហ៊ ហើយអ្នកទទួលឈ្មោះ ធី ។ តើលោកពិនិត្យមើលឯកសារនេះ តើលោកមានយោបល់យ៉ាងម៉េចដែរឯកសារនេះ?

**ឆ៖** ចំពោះឯកសារនេះ គឺដូចខ្ញុំសូមបានបញ្ជាក់កាលពីលើកមុនអ៊ីចឹង គឺខ្ញុំមិនបានទទួលផ្ទាល់ពីអ្នកប្រគល់ទេ គឺការបញ្ជាក់ក្នុងបញ្ជីនេះ គឺទៅតាមបញ្ជីដែលគេឲ្យមក គឺខ្ញុំត្រូវទៅតាមដែលបញ្ជីដូចថាខាងដែល ហ៊ ហ្នឹង គេបញ្ជូនមកគឺខ្ញុំសរសេរដាក់ ហ៊ ទៅ ។ ហើយបើខាងក្រសួងណាបញ្ជូនមក ខ្ញុំសរសេរតាមហ្នឹង ។ ប៉ុន្តែ ជាការពិតគឺខ្ញុំទទួលតែពី ហ៊ុយ ដែលនៅខាងក្រៅនោះតែប៉ុណ្ណឹង គឺមិនបានទទួលផ្ទាល់ពីអ្នកដែលយកមកទេ ។

[០៩:៣៩:៤៥]

**ស៖** សំណួរទីពីរគឺ ពាក់ព័ន្ធជានឹងឯកសារដែលយើងបានពិនិត្យផ្ទៀងផ្ទាត់បង្ហាញលោកហើយ ប៉ុន្តែមិនអស់ទេដោយសារឯកសារច្រើន ។ យើងចង់ដឹងថា តើក្នុងមួយថ្ងៃនេះមានការបញ្ជូនចូលដូចជាថ្ងៃទី២៤ ខែ៥ ឆ្នាំ១៩៧៨ តាមបញ្ជីគឺមានចំនួនរហូតទៅដល់ប្រាំលើកឯណោះ បានន័យថាបញ្ជីបញ្ជូនចូលហ្នឹង គឺមានលើកទីមួយគឺបញ្ជូនមកម្នាក់ ថោង ឆែម ។ ទីពីរ បួននាក់ ដូចយើងបានបង្ហាញអំមិញហើយ ទីបីគឺ ពីរនាក់ ទីបួន បួននាក់ ហើយទីប្រាំនេះគឺ ម្ភៃប្រាំបួននាក់ ។ តើមានករណីអ៊ីចឹងទេ? ទទួលក្នុងមួយថ្ងៃហ្នឹង ថ្ងៃទី២៤ ខែ៥ ឆ្នាំ១៩៧៨ ហ្នឹងគឺមានទទួលរហូតដល់ប្រាំលើក ទទួលមនុស្សចូលនៅក្នុងគុកហ្នឹងគឺរហូតដល់ប្រាំលើក ។ តើមានករណីអ៊ីចឹងដែរទេ ទើបលោកធ្វើបញ្ជីដូច្នេះ?

**ឆ៖** ខ្ញុំធ្វើបញ្ជីនេះគឺវាមានករណីអ៊ីចឹងពិតមែន ពីព្រោះអ្នកទោសចូលក្នុងមួយថ្ងៃៗទៅតាមមន្ទីរ ក្រសួង ភូមិភាគ តំបន់ ។ ដូច្នេះ ចូលមក វាមានខ្លះតិចខ្លះច្រើនទៅតាមដែលគេបញ្ជូនមក ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ មន្ត្រីខាងផ្នែកសោតទស្សន៍បង្វែររូបភាពទៅជារូបភាពធម្មតាឡើងវិញ ។

សំណួរបន្តទៀត ពាក់ព័ន្ធជាមួយនឹងអ្នកទោសនៅមន្ទីរអប់រំកែប្រែសាជាថ្មីព្រៃស ឬក៏ហៅថា

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** មន្ទីរស-២១ "ឃ" ដែលលោកបានប្រើ ហើយមានឯកសារខ្លះថា កន្លែងនោះគេហៅថា មន្ទីរស-២៤ ។ សំណួរសួរថា ពាក់ព័ន្ធជាមួយនឹងអ្នកទោស ដែលយកទៅឃុំគ្រងនៅមន្ទីរសន្តិសុខអប់រំ

កែប្រែសាជាថ្មី ព្រៃស ឬក៏ ស-២១ "ឃ" នោះ តើលោកមានការពាក់ព័ន្ធក្នុងការធ្វើបញ្ជីអ្នកទាំងអស់នោះយ៉ាងដូចម្ដេចខ្លះ?

**ឆ៖** ចំពោះអ្នកទោសនៅមន្ទីរស-២៤ គឺខ្ញុំអត់មានទាក់ទងជាមួយនឹងផ្នែកខាងណោះទេពីព្រោះគេមានអ្នកធ្វើបញ្ជីទៅតាមអង្គភាពនីមួយៗ ។ ហើយការធ្វើបញ្ជីនេះ គឺផ្នែកខ្ញុំក៏ត្រូវរាយការណ៍ទៅខាង ម៉េង ដែលជាប្រធានមន្ទីរកងសួរចម្លើយ គឺគេអ្នកសរុប ។ ខាងផ្នែក២៤ ក៏គេធ្វើបញ្ជីអ្នកទោសទៅឲ្យ ម៉េង ដើម្បីឲ្យ ម៉េង ហ្នឹងសរុបដែរ ។

**ស៖** ចុះអ្នកទោសនៅមន្ទីរស-២៤ ឬក៏នៅព្រៃសដែលត្រូវបានដកចេញ យកទៅកម្ទេចដោយផ្ទាល់ បានន័យថា នាំយកចេញពីមន្ទីរស-២៤ ឬក៏ព្រៃស យកទៅត្រង់ទៅជើងឯកតែម្ដងនោះតើការគិតគូរ ឬការរៀបចំបញ្ជីក្នុងការធ្វើបញ្ជីរួមបញ្ចូលមកបញ្ជីរួមអ្នកទោសដែលត្រូវបានកម្ទេចរួចនុំង យ៉ាងដូចម្ដេចដែរ?

[០៩:៤៤:០៧]

**ឆ៖** ចំពោះមន្ទីរស-២៤ គឺខ្ញុំមិនបានដឹងពិតប្រាកដអំពីរឿងអ្នកទោសអីទេ ។ ប៉ុន្តែ បើមានខាង ស-២៤ បញ្ជូនមកគឺគេចូលដាក់គុកខាងគុករបស់ខាងផ្នែកការពារ គឺគុកធំហ្នឹងហើយ ហើយការកម្ទេចគឺទៅតាមការយកចេញជាធម្មតាជាទូទៅដែលខ្ញុំបានបញ្ជាក់ហើយ ។

**ស៖** អ៊ីចឹងបានន័យថា លោកអត់ដឹងរឿងហេតុ ព្រឹត្តិហេតុនៃការដកមនុស្ស ដកអ្នកទោសនៅក្នុងមន្ទីរសន្តិសុខស-២៤ ឬក៏ព្រៃស ពីទីនោះបញ្ជូនត្រង់ទៅសម្លាប់នៅជើងឯកទេ លោកដឹងតែរឿងថា ដកមនុស្សពីមន្ទីរសន្តិសុខស-២៤ មក ត្រលប់មកដាក់នៅមន្ទីរសន្តិសុខស-២១ មជ្ឈមណ្ឌលភ្នំពេញ ហើយចំណាត់ការ គឺដូចជាករណីទូទៅដែរ តែប៉ុណ្ណោះ អ៊ីចឹងមែនទេ?

**ឆ៖** ពិតប្រាកដមែនហើយ ។

**ស៖** លោកបានឆ្លើយផ្ដល់សក្ខីកម្មកាលពីម្សិលមិញថា គ្រប់ករណីដែលការដកមនុស្សឬដកអ្នកទោសបញ្ចេញយកទៅកម្ទេចសុទ្ធតែត្រូវបានធ្វើបញ្ជីត្រលប់មកវិញ ដោយអ្នកដែលនាំមនុស្សយកទៅកម្ទេចនោះ ដោយផ្ទៀងផ្ទាត់ហើយមកតាមច្រករយៈ ហ៊ី ដែលជាអនុប្រធាន ដើម្បីយកមកឲ្យលោកធ្វើបញ្ជីរៀបចំបញ្ជីកម្ទេចអ្នកទោស ហើយរាយការណ៍ទៅថ្នាក់លើ ។ សំណួរសួរថា តើលោកអាចគិតឡើងវិញ ឬក៏មានការចងចាំដែរឬទេថា អ្នកទោសសរុបដែលបាននាំយកទៅកម្ទេចនៅវាលពិឃាតជើងឯកមានចំនួនប្រហែលប៉ុន្មានដែរ?

**ឆ៖** ចំពោះបញ្ហានេះគឺខ្ញុំសូមបញ្ជាក់គឺថាខ្ញុំមិនបានដឹងពិតប្រាកដ ការសម្លាប់រួមនៅបឹងជើងឯកទេ ពីព្រោះការធ្វើបញ្ជីនេះបើនិយាយឲ្យខ្លី គឺខ្ញុំម្នាក់ឯង ។ ដូច្នេះការធ្វើគឺធ្វើតែទាន់សភាពការណ៍មិនបានជាសរុបប្រចាំខែក៏អត់បាន ប្រចាំឆ្នាំក៏បានដែរ ដូច្នេះការងារប្រញ៉ាប់រាល់ថ្ងៃ ដូច្នេះការដោះស្រាយសរុបគឺអត់បានជាគិតគូរទេ ។

**សៈ** លោកបានធ្វើបញ្ជីតាំងពីដើមដំបូងនៃលោក ដែលទទួលភារកិច្ចធ្វើបញ្ជីបញ្ចូលអ្នកទោសនៅគុកហើយបានធ្វើបញ្ជីបញ្ចេញអ្នកទោសទៅវិញ ទោះបីធ្វើការបញ្ចេញដោយផ្ទៀងផ្ទាត់បញ្ជីផ្ទាល់ ឬក៏ករណីខ្លះគ្រាន់តែបានទទួលរបាយការណ៍ពីការដកយកទៅកម្ទេច ហើយធ្វើការ របាយការណ៍ជាលក្ខណ៍អក្សរមក ដើម្បីបញ្ចូលទៅក្នុងបញ្ជីរួមនៃអ្នកទោសបានកម្ទេច ដូចជាករណីអ្នកទោសសំខាន់ៗ ឬក៏អ្នកទោសបរទេសជាដើម ។ សំណួរសួរថា បើការរៀបចំធ្វើបញ្ជីដូច្នេះ ចុងក្រោយគឺមុនពេលថ្ងៃដែលលោកនិងក្រុមរបស់លោកបានចាកចេញពីមន្ទីរសន្តិសុខស-២១ បាននិយថារហូតថ្ងៃទី៦ ឬក៏ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ អ្នកទោសដែលនៅសល់ក្នុងមន្ទីរសន្តិសុខស-២១ មានដែរឬទេ? ហើយបើសិនបើមានៗប្រហែលប៉ុន្មាននាក់?

[០៩:៤៨:១៨]

**ឆ៖** ចំពោះបញ្ហាអ្នកទោសនៅដល់ថ្ងៃទី៦ ឆ្នាំ១៩៧៩ គឺខ្ញុំមិនបានដឹងពិតប្រាកដទេ ប៉ុន្តែចំពោះអ្នកទោសដែលនៅក្នុងអគារធំៗទាំងអស់ គឺគេចាប់បោសសម្អាតចាប់តាំងពីដើមថ្ងៃ ដើមឆ្នាំ ខែមករា រហូតទល់អស់ពីគុកហើយ ។ គឺនៅសល់តែកន្លែងគុកពិសេសទេដែលគេនៅសល់ ។ ចំពោះគុកពិសេសនេះគឺខ្ញុំអត់ដឹងចំនួនពិតប្រាកដប៉ុន្មានទេ ។ ហើយចំពោះអ្នកទោសដែលធ្វើការខាងក្រៅគឺនៅទាំងអស់ ។

**សៈ** លោកជាអ្នកធ្វើការបញ្ជី ហើយកាលពីសក្តិកម្មម្សិលមិញ លោកបាននិយាយច្បាស់លាស់ហើយថា ករណីមួយចំនួនដែលមានភាពបន្ទាន់ ឬក៏មកដល់នេះ គឺរៀបចំរួចហើយត្រូវបញ្ជូនទៅដល់ដាក់នៅក្នុងបន្ទប់ឃុំឃាំងរួម ឬក៏បន្ទប់ឃុំឃាំងដោយឡែកៗទៅតាមទីកន្លែងណាដែលនៅទំនេរ ហើយបន្ទាប់មកលោកធ្វើការទៅត្រួតពិនិត្យម្តងទៀត ដើម្បីបញ្ជាក់ថាអ្នកទោសឈ្មោះអ្វី? ហើយដាក់គុកនៅបន្ទប់ឃុំឃាំងរួមលេខប៉ុន្មាន? ឬក៏បន្ទប់ឃុំឃាំងដោយឡែកលេខប៉ុន្មាន? ដើម្បីងាយស្រួលនៅក្នុងការទំនាក់ទំនង ឬក៏ឆ្លើយតបទៅនឹងសំណូមពររបស់ខាងអ្នកសួរចម្លើយ ឬក៏អ្នកនាំយកទៅកម្ទេចជាដើម ដើម្បីងាយរក ហើយគ្រប់គ្រងឲ្យបាន។ សំណួរសួរថា ក្នុងអំឡុងពេលដែលលោកដើរទៅធ្វើការកិច្ចការអស់ទាំងនោះ ព្រោះលោកបាននិយាយហើយគឺលោកធ្វើការម្ភៃបួនម៉ោងលើម្ភៃបួនម៉ោង តើលោកបាន

ពិនិត្យឃើញ ឬក៏សង្កេតឃើញទិដ្ឋភាពនៃជីវភាពអ្នកទោសដែលរស់នៅៗក្នុងអគារឃុំឃាំងដែលលោកទៅធ្វើការនោះ តើលោកបានឃើញនូវទិដ្ឋភាពយ៉ាងដូចម្តេចខ្លះ? នៃការឃុំឃាំង? នៃការរស់នៅ? នៅក្នុងអំឡុងពេលនៃការជាប់ឃ្នោះនៅទីនោះ? លោកអាចនិយាយរៀបរាប់ប្រាប់ដល់អង្គសវនាការបានដែរឬទេ អំពីទិដ្ឋភាពទូទៅនោះ?

**ឆ៖** ជាទិដ្ឋភាពទូទៅ នៅពេលដែលខ្ញុំទៅស្រង់បញ្ជីចំពោះអ្នកទោសដែលចូលបន្ទប់ណា នោះគឺខ្ញុំមិនសូវជាចាប់អារម្មណ៍ចំពោះអ្នកទោសប៉ុន្មានទេ ។ ប៉ុន្តែខ្ញុំបានដឹងខ្លះៗ ដឹងមួយចំនួនចំពោះអ្នកទោសនៅក្នុងនោះគឺវេទនាណាស់ ហើយភាគច្រើនគឺស្គម ហើយនិងខ្លះគឺស្គមដល់មែនទែនហើយ គឺដោយសារតែការរស់នៅក្នុងបន្ទប់វាគ្មាន គឺថាខ្យល់អាកាសត្រឹមត្រូវអីទេ ។

**សៈ** លោកមានបានឃើញខ្លួន រាងកាយរបស់គាត់ត្រូវដំបៅ ឬក៏ត្រូវមានស្នាមរបួសចេញឈាមអីដែរទេ? ហើយមានការព្យាបាលដែរទេ?

**ឆ៖** ចំពោះទាំងនេះ គឺខ្ញុំមិនបានជាពិនិត្យគ្រប់ជ្រុងជ្រោយទេ ប៉ុន្តែចំពោះការព្យាបាល ការអីគឺនៅលើបញ្ហាពេទ្យទាំងអស់ ។ ហើយជាពិសេសខ្ញុំនិយាយឲ្យត្រង់ គឺខ្ញុំមិនសូវជាចាប់អារម្មណ៍ការងារហ្នឹង ពីព្រោះការងារខ្ញុំវាត្រូវតែ-- នេះហើយវាប្រញាប់មកកន្លែងវិញ ។

**សៈ** លោកអាចនិយាយរៀបរាប់អំពីទិដ្ឋភាពនៃអ្នកទោសដែលនាំឡើងរថយន្ត ពេលដែលមានការពិនិត្យផ្ទៀងផ្ទាត់បញ្ជីចុងក្រោយ ពេលដែលឡើងនាំឡើងរថយន្តប្រគល់ទៅឲ្យក្រុមកងពិសេសដើម្បីនាំទៅកម្ទេច ។ សួរថាទិដ្ឋភាពនៃអ្នកទោស ពេលដែលខណៈពេលដែលនាំឡើងរថយន្តហ្នឹងគឺធ្វើយ៉ាងម៉េច? ទីមួយ ការកោះហៅសារវតារ ឈ្មោះ តើយើងប្រព្រឹត្តទៅយ៉ាងដូចម្តេច? ទីពីរ នៅក្នុងករណីឈឺធ្ងន់ ឬក៏ស្គមបាក់កម្លាំង ដែលអាចករណីខ្លះនិយាយមិនកើត តើការផ្ទៀងផ្ទាត់សារវតារយ៉ាងដូចម្តេច? ហើយការប្រព្រឹត្តិទៅនៅពេលណា នៅក្នុងការ-- ជាញឹកញាប់ក្នុងការបញ្ចេញអ្នកទោសឲ្យទៅឡើងរថយន្ត ហើយនាំទៅកម្ទេចនោះ?

[០៩:៥៣:៥៤]

**ឆ៖** ចំពោះអ្នកទោស ដែលយកទៅកម្ទេចមុននឹងឡើងរថយន្ត គឺមានសភាពគឺស្គម ហើយគេចងមុខចងអី ។ ដូច្នេះ សភាពមុខ ខ្ញុំអត់បានមើលបានត្រឹមត្រូវ ហើយក៏ខ្ញុំមិនចាប់អារម្មណ៍ជាទូទៅ គឺធ្វើយ៉ាងម៉េចសួរឲ្យតែបានច្បាស់ដើម្បីកត់ក្នុងបញ្ជី ។ ដូច្នេះ សភាពទូទៅគឺខ្ញុំមិនបានជាចាប់អារម្មណ៍ខ្លាំងមែនទែនទេ ប៉ុន្តែខ្ញុំដឹងថាអ្នកទោសដែលជាប់មករហូតដល់គេយកបញ្ចេញហ្នឹងគឺ សភាពគឺស្គម

ស្គមមែនទែន ។

**ស៖** ក្នុងការត្រួតពិនិត្យឈ្មោះ បញ្ជីឈ្មោះ ឬក៏ប្រវត្តិរូបសង្ខេប ដើម្បីផ្ទៀងផ្ទាត់ហ្នឹង សួរថា លោកដែលជួបករណីអ្នកទោសហ្នឹង ឈឺធ្ងន់ ឬក៏ស្គមបាក់កម្លាំងខ្លាំង គាត់និយាយមិនកើតទេ? ហើយករណីនេះ តើការផ្ទៀងផ្ទាត់ឈ្មោះ និងប្រវត្តិរូបដើម្បីចៀសវាងការភាន់ច្រឡំប្រព្រឹត្តទៅយ៉ាងដូចម្ដេច?

**ឆ៖** ចំពោះការពិនិត្យអ្នកទោសដែលស្គម គឺខ្ញុំជាទូទៅ ខ្ញុំមិនដែលបានជួបចំពោះអ្នកទោសណាដែលនិយាយមិនកើតទេ ។ គឺអាចនិយាយបានគ្រាន់តែប្រាប់ឈ្មោះ ហើយនិងតួនាទី ខ្ញុំដឹងហើយ គឺមិនបាច់សួរច្រើនទេ ។

**ស៖** តាមធម្មតា គេប្រព្រឹត្តទៅក្នុងការបញ្ចេញអ្នកទោសទៅកម្ទេចប្រព្រឹត្តនៅពេលប្រហែលជាម៉ោងប៉ុន្មាន ជាទូទៅធ្វើវណា?

**ឆ៖** ជាទូទៅ គឺក្នុងអំឡុងម៉ោងបួនល្ងាច ។

**ស៖** អ៊ីចឹងបានន័យថា ម៉ោងបួន ចាប់ផ្ដើមរៀបចំ ហើយអាចដំណើរការប្រព្រឹត្តិទៅ ហើយប្រហែលជាអស់រយៈពេលប៉ុន្មានទៅ បើច្រើនអស់រយៈពេលរហូតដល់ម៉ោងប៉ុន្មានទើបចេញទៅ ទើបរថយន្តចាប់ផ្ដើមបញ្ឆេះម៉ាស៊ីន ហើយចេញដំណើរ?

**ឆ៖** ការពិនិត្យនេះ គឺមិនយូរប៉ុន្មានទេ តែយ៉ាងយូរណាស់មួយម៉ោងគឺហើយៗ ។

**ស៖** ក្រុមអ្នកដែលដឹកជញ្ជូនមនុស្សយកទៅកម្ទេចហ្នឹង គេហៅថាក្រុមអ្វីទៅ? ហើយមានគ្នាប៉ុន្មាននាក់?

[០៩:៥៦:២០]

**ឆ៖** ចំពោះកម្លាំងដែលដឹកមនុស្សយកទៅកម្ទេចនោះ គឺខ្ញុំមិនបានដឹងពិតប្រាកដទេ ព្រោះការក្ដោបក្ដាប់កម្លាំងទាំងអស់ គឺនៅ ហ៊ វ ជាអ្នកក្ដោបក្ដាប់ទាំងអស់ ។ ហើយដូច្នេះ បញ្ហាដែលកម្លាំងដែលយកទៅកម្ទេចនោះ គឺមានតែ ហ៊ វ ទេដែលអ្នកបញ្ជា។ ហើយចំពោះកម្លាំងហ្នឹងគឺស្រេចតែ ហ៊ វ បញ្ជាទៅខាងកងពិសេសក៏មាន ទៅខាង-- អាហ្នឹងខាងផ្នែក ហ៊ុយ ហើយឬក៏ទៅខាង ប៉េង ដែលជាកងអនុសេនាធំនៅខាងក្នុងក៏មាន ឬក៏ផ្នែកខាង ស្រ៊ី ក៏មាន ។

**ស៖** ការសួរចម្លើយឈ្លើយសឹកវៀតណាម តើក្រុមណាអ្នកសួរចម្លើយ? ក្រុមណាអ្នកមកទទួលយកអ្នកទោស ជាឈ្លើយសឹកវៀតណាមយកទៅសួរចម្លើយ លោកដឹងដែរទេ?

**ឆ៖** ការសួរចម្លើយអ្នកទោសវៀតណាមគឺមានតែ តា ម៉ម ណៃ ហៅ ចាន់ ទេដែលគាត់មានភារកិច្ចសួរចម្លើយហ្នឹង ។

**ស៖** កាលពីអំឡុងពេលដែលលោកធ្វើការងារផ្នែកខាងឯកសារនៅទីនោះ សំណួរសួរថា តើលោកធ្វើការនោះក្នុងនាមជាកងទ័ព ឬក៏ជាមន្ត្រីជាបុគ្គលិកកម្មាភិបាលស៊ីវិល?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ការងារនេះគឺខ្ញុំមិនដឹងពិតប្រាកដទេ ប៉ុន្តែបើខ្ញុំសន្និដ្ឋានតាំងពីខ្ញុំចូលទៅគឺការងារនេះនៅក្នុង-- របស់កងទ័ពហើយ ពីព្រោះមន្ទីរសេនាធិការគឺជាអ្នកក្តាប់នៅស-២១ ទាំងស្រុង ។

**ស៖** ចុះលោកខ្លួនឯងផ្ទាល់ពេលដែលធ្វើការងារ តើលោកស្លៀកពាក់ឯកសណ្ឋានយ៉ាងម៉េច? ឯកសណ្ឋានកងទ័ព? ឬក៏ឯកសណ្ឋានស៊ីវិល? ហើយផ្នែកខាងផ្សេងទៀតដូចជា ផ្នែកខាងសួរចម្លើយ ឬក៏កងការពារ កងពិសេសជាដើម តើគេស្លៀកពាក់ឯកសណ្ឋានយ៉ាងម៉េច?

**ឆ៖** នៅក្នុងអំឡុងសម័យហ្នឹងគឺឯកសណ្ឋានគឺអត់មានទេ គឺច្រើនតែស្លៀកខ្មៅពាក់ខ្មៅតែប៉ុណ្ណឹងទេ ទាំងកងការពារក៏ដូចជាកងសួរចម្លើយ ។

**ស៖** មានពាក់ប៉ារេទេ? ពាក់អាកន្តិបប៉ារេ? គេហៅថា សម័យហ្នឹងគេហៅថា មួកកងទ័ពបដិវត្តន៍ហ្នឹងទេ?

**ឆ៖** ការធ្វើការងារនៅក្នុងមន្ទីរស-២១ ទាំងអស់ គឺគ្មានជាឯកសណ្ឋានអ្វីទាំងអស់ គឺគ្មានពាក់មួកពាក់អីទេ គឺស្លៀកតែខោខ្មៅ អាវខ្មៅ តែប៉ុណ្ណឹងទេ តាមដែលខ្ញុំដឹង ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំអស់សំណួរហើយ តើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វី ត្រូវសួរដល់សាក្សីរូបនេះដែរឬទេ? សូមអញ្ជើញលោកស្រីចៅក្រម ។

[១០:០០:១៥]

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៌៖**

សូមអរគុណ លោកប្រធាន ។

**ស៖** ដូចដែលលោកប្រធានបានសួរទៅកាន់លោកថា លោកមានតួនាទីជាទម្លាប់នៅពេលដែលលោកទទួលអ្នកទោសដែលចូលមកកន្លែងលោក ហើយនិងការដែលលោកសួរទៅកាន់អ្នកទោសទាំងអស់នោះ តើអ៊ីចឹងទេ លោកធ្វើការងារទាំងអស់នោះ?

**ឆ៖** ជាការទម្លាប់ គឺរបៀបរបបធ្វើការងារ គឺខ្ញុំធ្វើដូចដែលខ្ញុំបានរៀបរាប់អ៊ីចឹង ។

**ស៖** ដូច្នេះ អ្នកទោសជាច្រើនដែលចូលមកនោះ គឺនាំចេញមកពីឡានទៅកន្លែងលោកផ្ទាល់តែម្តង ហើយលោកបានធ្វើការរៀបចំប្រមូលផ្តុំប្រវត្តិរូបរបស់ពួកគេ ពួកគេត្រូវបានគេថតរូប ហើយបន្ទាប់មកដឹកទៅបន្ទប់ឃុំឃាំងដោយអ្នកយាម ហើយលោកបានដើរទៅកត់លេខបន្ទប់សម្រាប់អ្នកទោសនីមួយៗ ហើយបន្ទាប់មកផ្តល់ព័ត៌មានពិស្តារទាំងអស់នេះទៅកាន់អ្នកសួរចម្លើយ ។ តើទាំងអស់នេះ ជាការងារទម្លាប់ប្រចាំថ្ងៃរបស់លោក ឬក៏យ៉ាងម៉េច?

**ឆ៖** នេះគឺជាការងារប្រចាំថ្ងៃរបស់ខ្ញុំ។ ហើយចំពោះការងារផ្សេងទៀត គឺអត់មានទេ គឺក្រៅពីការងារនេះ គឺខ្ញុំមានតែបិទប្រវត្តិរូបបន្ថែមទៅលើ យករូបថតមកបិទបន្ថែមពីលើប្រវត្តិរូបហ្នឹងទេ ។

**ស៖** ដូច្នេះ អ្នកទោសមួយចំនួនដែលមិនបានឆ្លងកាត់តាមរបៀបនេះ ។ ឧទាហរណ៍ថា អ្នកទោសបរទេសនិងអ្នកទោសសំខាន់មួយចំនួន គឺត្រូវបានគេនាំទៅគុកដាក់គុកពិសេសតែម្តង ដោយមិនមានធ្វើការចុះប្រវត្តិរូបដោយលោក ហើយក៏មិនមានការថតរូបដែរ តើអ៊ីចឹងទេចំពោះអ្នកទោសប្រភេទទាំងអស់នោះ?

**ឆ៖** ចំពោះអ្នកទោសដែលមានតួនាទីខ្ពស់ៗគឺគេធ្វើទៅកន្លែងគុកពិសេសតែម្តងជាការពិតណាស់។

**ស៖** បញ្ជីឈ្មោះអ្នកទោសសំខាន់ទាំងអស់នោះគឺ ហ៊ី ជាអ្នកធ្វើ ដែលបន្ទាប់មកគាត់ផ្តល់ឲ្យលោក ហើយឲ្យលោកបានប្រមូលចងក្រងចូលក្នុងបញ្ជីរបស់លោក តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ពិតប្រាកដមែនហើយ ។

**ស៖** យើងឃើញមានក្រុមមួយទៀត ក្រុមអ្នកទោសមួយទៀតដែលមិនបានឆ្លងតាមកន្លែងលោក ហើយលោកបានបញ្ជាក់ទៅលើចំណុចហ្នឹងដែរថា កូនក្មេងទាំងឡាយគឺមិនត្រូវបានគេកត់ត្រាប្រវត្តិរូបសង្ខេបអីផ្សេងៗទេ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ត្រឹមត្រូវហើយ ។

**ស៖** កាលពីម្សិលមិញ ខ្ញុំគិតថា លោកបានធ្វើការសន្និដ្ឋាន ប្រហែលក្មេងមួយរយទៅពីររយនាក់ អាចធ្លាប់ជាប់នៅស-២១ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ចំពោះការសន្និដ្ឋាន ក្មេងដែលជាប់នៅស-២១ គឺខ្ញុំសន្និដ្ឋានវាមិនបានពិតប្រាកដទេ ប៉ុន្តែក្មេងនោះពិតជាបានចូលមកក្នុងមន្ទីរស-២១ ពិតប្រាកដមែន ។

**ស៖** កូនក្មេងទាំងនោះ គឺមកជាមួយឪពុកម្ដាយ។ បានន័យថា ម្ដងមកតែបីទៅបួននាក់ប៉ុណ្ណោះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ត្រឹមត្រូវហើយ ។

**ស៖** ក្មេងទាំងអស់នោះត្រូវបានគេយកចេញពីឪពុកម្ដាយ ហើយដាក់នៅកន្លែងមួយផ្សេងទៀត នៅក្នុងបរិវេណគុកដែលលោកសន្និដ្ឋានថា ត្រូវបានគេយកក្មេងទាំងអស់នោះយកទៅសម្លាប់ចោល តើត្រឹមត្រូវដែរឬទេ?

**ឆ៖** កាលដែលក្មេងយកមកជាប់ជាមួយនឹងឪពុកម្ដាយហ្នឹង ចំពោះរឿងនេះ គឺខ្ញុំមិនបានដឹងប្រាកដទេ ពេលដែលគេយកចូលទៅក្នុងគុក ។ មិនដឹងគេយកដាក់ដោយឡែក ឬក៏គេយកនៅជាមួយឪពុកម្ដាយទេ ។

**ស៖** ប៉ុន្តែក្មេងទាំងអស់នោះ គឺនៅក្នុងក្រុមតូចៗ ហើយលោកសន្និដ្ឋានថា នៅពេលមួយចំនួននោះ គេយកក្មេងទាំងអស់នោះយកទៅសម្លាប់ចោល អ៊ីចឹងទេ?

**ឆ៖** ចំពោះក្មេងៗដែលចូលមកក្នុងគុកហើយ គឺខ្ញុំមិនបានដឹងពិតប្រាកដពីរយៈពេលដែលគេយកចេញទេ គឺអាស្រ័យ ហ៊ី បញ្ជាទៅ ប៉េង ឱ្យដកចេញទេ ។

**ស៖** ថាតើគេដឹកក្មេងនៅលើឡានដែរឬទេ? ដែលគេដឹកទៅជាមួយនឹងមនុស្សធំៗយកទៅសម្លាប់ចោលនោះ?

**ឆ៖** ការយកមនុស្សទៅសម្លាប់ គឺក្មេងអត់មានទៅជាមួយមនុស្សធំៗទេ ។

**ស៖** តើលោកបានដឹងដែរឬទេថា តើក្មេងទាំងអស់នោះ គេយកទៅសម្លាប់ចោលនោះតាមរបៀបណា តើលោកដឹងទេ?

**ឆ៖** ចំពោះបញ្ហានេះ គឺខ្ញុំអត់បានដឹងទេ គឺអាហ្នឹងភារកិច្ចទៅលើ ហ៊ី គេជាអ្នកបញ្ជាទៅ ប៉េង ឬក៏ ហ៊ុយ ទេ ខ្ញុំអត់ដឹង ។

**ស៖** តើក្មេងទាំងអស់នោះ ប្រហែលជាគេសម្លាប់ចោលនៅជុំវិញស-២១ដែរឬទេ? តើលោកដឹងទេទៅលើករណីនេះ?

**ឆ៖** ចំពោះលើករណីនេះ គឺខ្ញុំមិនបានដឹងពិតប្រាកដទេ ពីព្រោះវាមិនទាក់ទងជាមួយនឹងបញ្ជីខ្ញុំទេដូច្នេះការដោះចេញ គឺគាត់មិនកំណត់ពេលទេ វាអាស្រ័យទៅលើការសម្រេចរបស់ ហ៊ី ឬបញ្ជាទៅ ប៉េង ទេ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។ សូមសោតទស្សន៍បញ្ចាំងឯកសារមួយនៅលើអេក្រង់ គឺលេខ 00006728 ។

សូមបង្អិលចុះក្រោមទៅដល់ចំណុចចុងក្រោយ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** យើងឃើញមានអក្សរនៅក្រោមហ្នឹង តើលោកអាចអានទេ លោកយល់ទេថាតើគេសរសេរអីគេនៅលើហ្នឹង? តើលោកចង់ឲ្យអ្នកផ្សេងអានឲ្យលោក ឬក៏លោកចង់អានខ្លួនឯង? ហើយលោកយល់ទេទៅលើសំណេរ ដែលគេសរសេរនៅខាងក្រោមនេះ?

[១០:០៩:៥៥]

**ឆ៖** ខ្ញុំចង់សួរបញ្ជាក់ពីសំណួរ ពីព្រោះខ្ញុំអត់ទាន់យល់សំណួរ ។

**ស៖** ការសន្និដ្ឋានរបស់ខ្ញុំនោះគឺថា ខ្មែរនៅខាងក្រោមនោះសរសេរ ដែលនោះជាសំណេរលាយលក្ខណ៍អក្សរ រួមនិងកុមារមួយរយហុកសិប ទាំងអស់ផ្នែកស្រែមួយរយចិតសិបប្រាំបី គឺនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៧៧ ហើយនេះ ជាហត្ថលេខារបស់ ហ៊ ។ តើអ៊ីចឹងទេ សរសេរនៅក្រោមហ្នឹង?

**ឆ៖** នេះគឺជាហត្ថលេខារបស់ ហ៊ ហើយ ។

**ស៖** តើចំណុចនេះ គេនិយាយអំពីចំនួនអ្នកទោសសរុប ដែលនៅក្នុងនោះមានអ្នកទោសដែលជាកុមារមួយរយហុកសិបផងដែរ ដែលកុមារទាំងអស់នោះត្រូវបានគេយកទៅសម្លាប់ចោល តើអ៊ីចឹងមែនទេ?

**ឆ៖** ចំពោះបញ្ហានេះ គឺខ្ញុំមិនបានឃើញកុមារទេ ចំពោះទាំងមួយរយហុកសិបនាក់នេះ ហើយការធ្វើបញ្ជីនេះគឺមានតែចំពោះអ្នកទោស ដែលដប់ប្រាំបីនាក់ អាហ្នឹងវា គឺទៅតាមបញ្ជីដែលខ្ញុំធ្វើហ្នឹង ។ ប៉ុន្តែចំពោះកុមារមិនដឹងជាគេយកពីកន្លែងណាមក ពីព្រោះ ហ៊ គេឲ្យសរសេរអ៊ីចឹង ។

**ស៖** សាក្សីមួយទៀតបានបញ្ជាក់ថា បញ្ជីនេះដែលមានកុមារមួយរយហុកសិប គឺកុមារដែលមកពីព្រៃស ។ ដូច្នេះ ខ្ញុំគ្រាន់តែចង់សួរលោកថា នេះគឺជាអ្វីដែលបាន-- ដែលឯកសារនេះបានសរសេរបញ្ជាក់អ៊ីចឹងមែនដែរឬទេ?

**ឆ៖** ឯកសារនេះពិតជាបញ្ជាក់អ៊ីចឹងមែនហើយ ប៉ុន្តែខ្ញុំសូមបញ្ជាក់បន្ថែម ។ ចំពោះកុមារមួយរយហុកសិបនាក់នេះ គឺខ្ញុំមិនបានឃើញយកមកក្នុងគុកនេះទេ ។

**ស៖** ខ្ញុំចង់សុំសួរលោកថា ថាតើវាអាចទេដែលថាកូនក្មេងដែលមកដល់ស-២១នោះ គឺត្រូវបានគេយកទៅព្រៃស ហើយក្រោយមក ក្រុមកុមារហ្នឹងច្រើន ហើយគេប្រមូលបានកុមារហ្នឹងច្រើនគេសម្លាប់ចោល ហើយដូចដែលគេបានកត់ត្រាបញ្ជាក់នៅក្នុងឯកសារហ្នឹងអ៊ីចឹង តើអ៊ីចឹងទេ?

**ឆ៖** ដូចខ្ញុំសូមបញ្ជាក់បន្ថែមអ៊ីចឹង គឺថាចំពោះកុមារមួយរយហុកសិបនាក់នេះ គឺមិនបានបញ្ជូនមកក្នុងមន្ទីរស-២១ទេ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។ សូមឲ្យធ្វើការដាក់អេក្រង់រូបភាព ជារូបភាពធម្មតាវិញ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** ដូចចំនួន និងឈ្មោះកុមារ លោកមិនបានកត់ទៅលើចំនួននិងឈ្មោះកុមារនោះទេ ។ ដូច្នេះយើងអាចសន្និដ្ឋានថា ចំនួនកុមារដែលសម្លាប់នៅជើងឯក ឬក៏នៅស-២១ គឺមានចំនួនច្រើនជាងការកត់ត្រាដែលលោកបានកត់នៅក្នុងបញ្ជីរបស់លោកទាក់ទងចំនួនអស់ហ្នឹង ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ដូចខ្ញុំសូមបញ្ជាក់អ៊ីចឹង គឺការដែលខ្ញុំបញ្ជាក់គឺថាខ្ញុំសន្និដ្ឋានៗដូច្នេះ ការពិតប្រាកដ គឺខ្ញុំមិនបានដឹងពិតប្រាកដទេ ទាល់តែឃើញបញ្ជី ទើបវាបានពិតប្រាកដ ។

**ស៖** ចំពោះទម្លាប់របស់លោកក្នុងការរៀបចំបញ្ជីសម្លាប់ ដូច្នេះខ្ញុំអាចសង្ខេបដូចតទៅ ដូច្នេះបានដែរឬទេថា ជនជាប់ចោទ គាត់ធ្វើចំណារនៅលើបញ្ជី ដែលបញ្ជាក់ថា តើអ្នកទោសមួយណាត្រូវយកទៅសម្លាប់ចោល ហើយបន្ទាប់មកបញ្ជីនោះបញ្ជូនទៅ ហ៊ី ដែល ហ៊ី ជាអ្នកបញ្ជូនបន្តមកឲ្យលោក តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជាការពិត ។

**ស៖** បន្ទាប់មកលោកធ្វើបញ្ជីដាច់ដោយឡែក ថាអ្នកណាខ្លះដែលត្រូវយកទៅសម្លាប់ចោល ហើយបញ្ជាក់អំពីចំនួនត្រូវសម្លាប់ ហើយកត់អគារ លេខអគារ លេខបន្ទប់ ហើយបន្ទាប់មកបញ្ជូនបញ្ជីដោយឡែកនោះទៅឲ្យ ហ៊ី តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ត្រឹមត្រូវហើយ ។

**ស៖** នៅពេលដែលធ្វើការផ្ទៀងផ្ទាត់ឈ្មោះចុងក្រោយនៅមាត់ទ្វារ លោកបានធ្វើការត្រួតពិនិត្យឈ្មោះចុងក្រោយទៀតនៅមុនពេលដែលអ្នកទោសនោះ ចាប់ដាក់លើឡាន តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ត្រឹមត្រូវហើយ ។

[១០:១៦:១១]

**ស៖** លោកធ្វើការកៀកជាមួយនិង ហ៊ី ឬក៏អត់ទេ? ហើយលោកបានធ្វើការនៅក្នុងបន្ទប់ការិយាល័យជាមួយគាត់ដែរឬទេ? ឬក៏យ៉ាងម៉េច?

**ឆ៖** ការិយាល័យដែលខ្ញុំធ្វើការហ្នឹង គឺជាការិយាល័យរបស់ ហ៊ី គេជាអ្នកបញ្ជាទូទៅទាំងអស់ ហើយឲ្យខ្ញុំអ្នកធ្វើបញ្ជីហ្នឹង គឺនៅក្នុងការិយាល័យហ្នឹង ជាងថតក៏នៅកន្លែងហ្នឹងដែរ ។

**ស៖** លោកបានជម្រាបជូនលោកប្រធានអម្បាញ់មិញហ្នឹងថា អ្នកទោសគឺស្គមស្គាំង ហើយមិនមានអាហារគ្រប់គ្រាន់ហូប តើលោកបាន ឬក៏មិនបាននិយាយជូនសហចៅក្រមស៊ើបអង្កេតថា អ្នកទោសមួយចំនួនស្លាប់ដោយសារអត់ឃ្លាន ហើយអ្នកទោសមួយចំនួនទៀតត្រូវបានគេធ្វើទារុណកម្មរហូតដល់ចំណុចមួយ ដែលស្ទើរស្លាប់ ឬក៏ស្លាប់ តើលោកបាននិយាយអ៊ីចឹងទេ?

**ឆ៖** សូមបញ្ជាក់សំណួរម្តងទៀត ។

**ស៖** តើលោកបានជម្រាបសហចៅក្រមស៊ើបអង្កេតថា អ្នកទោសមួយចំនួនស្លាប់ដោយសារការអត់ឃ្លាន ហើយមួយចំនួនទៀត គឺត្រូវបានគេធ្វើទារុណកម្មរហូតទៅដល់ស្លាប់ តើអ៊ីចឹងទេ លោកបានជម្រាបជូនសហចៅក្រមស៊ើបអង្កេត?

**ឆ៖** បាទ, ពិតប្រាកដមែន ។

**ស៖** យើងបានស្តាប់នូវការផ្តល់ភស្តុតាងនិងចម្លើយថា នៅក្នុងឆ្នាំ១៩៧៨ គឺជាឆ្នាំមួយដែលរវល់ខ្លះណាស់ ចំពោះមន្ទីរស-២១ ថាតើលោកចាំ លោកនឹកឃើញទេថា ពិតជាអ៊ីចឹងមែននៅពេលនុ៎ង?

**ឆ៖** ពិតប្រាកដមែន ។

**ស៖** តាមការសង្កេតរបស់លោក នៅក្នុងមន្ទីរការងាររបស់ ហ៊ី តើលោកដែលឃើញឡានចូលមកស-២១ ហើយបន្ទាប់មកគេដឹកចេញទៅវិញដោយសារតែលោកមិនមានពេលគ្រប់គ្រាន់ក្នុងការចាត់ចែងទៅលើបញ្ជី ឬក៏មិនមានកន្លែងដាក់អ្នកទោស?

**ឆ៖** ចំពោះបញ្ហានេះ សូមបញ្ជាក់ម្តងទៀត ។

**ស៖** តើលោកធ្លាប់ឃើញឡាន ដែលដឹកអ្នកទោសមកដល់ស-២១ ហើយបន្ទាប់មក គឺគេបើកទៅវិញ ដោយសារតែលោកមិនអាចដាក់អ្នកទោសនៅក្នុងបន្ទប់ផ្សេងៗទៀតវាពេញ តើលោកមានដែលឃើញអ៊ីចឹងដែរឬទេ ឡានហ្នឹងបើកទៅវិញ?

**ឆ៖** ចំពោះឡានអ្នកទោសដែលបញ្ជូនមក គឺឥតមានឡានក្រៅពីខាង ហ៊ុយ ហ្នឹង គេបើកមកទេ គឺកាលណាខាងក្រៅ គេអត់មានសិទ្ធិបើកចូលទេ ។

**ស៖** លោកបានជម្រាបជូនលោកប្រធានមុនហ្នឹងថា លោកមិនបានរក្សាបញ្ជីរួមអំពីអ្នកទោសនៅស-២១នោះទេ ហើយអ្នកទាំងអស់នោះត្រូវបានគេយកទៅសម្លាប់ចោលទាំងអស់។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ ចំពោះបញ្ជីរួម គឺខ្ញុំមិនបានសរុបទាំងអស់ទេ ប៉ុន្តែដូចខ្ញុំសូមបញ្ជាក់អ៊ីចឹង គឺថានៅចុងឆ្នាំ៧៨ ដើមឆ្នាំ៧៩ហ្នឹង គឺគេដកចេញអស់ហើយ គេយកទៅកម្ទេចអស់ហើយ ។ ហើយអ្នកដែលនៅសល់ គឺនៅតែអ្នកធ្វើការខាងក្រៅ ហើយនិងក្នុងគុកពិសេស ប៉ុន្តែចំនួនពិតប្រាកដ គឺខ្ញុំមិនបានដឹងទេ ។

**ស៖** ដូច្នេះ បញ្ជីដែលយើងរកឃើញនៅស-២១ គឺមិនមែនជាបញ្ជីសរុបនោះទេ ដោយសារតែលោកមិនបានដាក់ឈ្មោះគ្រប់ឈ្មោះទាំងអស់ទេនៅក្នុងបញ្ជីដែលរកឃើញហ្នឹង អ៊ីចឹងដែរឬទេ?

**ឆ៖** បញ្ជីនៅក្នុងមន្ទីរស-២១ គឺមិនបានសរុបទេ មិនដឹងចំនួនពិតប្រាកដប៉ុន្មានទេ ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់បន្តិចពីរឿងបញ្ជាហ្នឹង ទោះបីមិនបានសរុបក៏បញ្ជីអ្នកទោស គឺមានចំនួនប៉ុន្មាន គឺទោះបីនៅខាងក្នុងគុកពិសេស ឬក៏គេហាមឃាត់មិនឲ្យខ្ញុំទៅហ្នឹង ក៏ហ៊ា គេបញ្ជូនឈ្មោះហ្នឹងមកឲ្យខ្ញុំវ៉ៃ ដើម្បីឲ្យគ្រប់ចំនួនវិញដែរ ។

**ស៖** ចំណុចចុងក្រោយ តើលោកធ្លាប់ធ្វើការចងក្រងបញ្ជីនូវចំនួនបុគ្គលិកទាំងអស់នៅស-២១ដែរឬទេ?

**ឆ៖** ចំពោះបញ្ជីបុគ្គលិកនៅក្នុងមន្ទីរស-២១ គឺខ្ញុំមិនបានចងក្រងទេ គឺខ្ញុំនៅផ្នែកខាងកងការពារ។ នៅក្នុងកងការពារនេះ គឺខ្ញុំដឹងក្រោយមក គឺមិនដឹងច្បាស់ពិតប្រាកដទេ ពីព្រោះគេមិនដែលធ្វើបញ្ជីកម្មាភិបាលយុទ្ធជននៅក្នុងកងការពារទេ ពីព្រោះការងារនេះ ជាការងារជាក់ស្តែង ។ សម្រាប់កងអនុសេនាតូច អនុសេនាធំ គឺហ៊ា គេក្តាប់ផ្ទាល់ ។ ដូច្នេះ ការធ្វើបញ្ជីគេមិនបានឲ្យខ្ញុំធ្វើបញ្ជីទេ រឿងចំនួនកម្មាភិបាល និងយុទ្ធជន បុគ្គលិកកងការពារទាំងមូល ។ ហើយចំនួនផ្នែកខាងស-- និយាយរួមនៅក្នុងស-២១ គឺគេមានអ្នកធ្វើបញ្ជីដាច់ដោយឡែកគ្នាទាំងអស់ ហើយអ្នកធ្វើបញ្ជីដែលសរុបរួម គឺមានតែនៅក្នុងកងការពារ ដែលអតីតពីមុន គឺជា ម៉េង ជាអ្នកធ្វើបញ្ជីនៅក្នុង-- (អត់ទោស) កងសួរចម្លើយៗ ។ ហើយដូចខ្ញុំសូមបញ្ជាក់អ៊ីចឹង គឺ ម៉េង គេសរុប ព្រោះ ម៉េងហ្នឹង ជាអ្នកធ្វើបញ្ជីរបស់កងពល អតីត

កងពល៧០៣នោះ ។

ដូច្នេះហើយគឺថា បញ្ជីសរុបទាំងអស់នៅក្នុងបញ្ជីកម្មាភិបាលយុទ្ធជន ទាំងអ្នកទោស គឺនៅក្នុងម៉េង ជាអ្នកសរុបទាំងអស់ ។ ហើយខ្ញុំសូមបញ្ជាក់បន្ថែមទៀតថា ដើម្បីឲ្យងាយយល់ គឺថានៅក្នុងផ្នែកកងការពារ គឺមិនមានដូចនៅក្នុងសង្គ្រាមទេ វាមានរបួស មានពលី វាមានចេញ មានចូល ដល់ទៅក្នុងយើងវាអត់មានសង្គ្រាម ដូច្នេះកម្មាភិបាលដែលគេដឹកបញ្ជាផ្ទាល់នោះ គេបានក្ដាប់ខ្លួនគេបានដឹងហើយ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកច្រើន ខ្ញុំពុំមានសំណួរផ្សេងទៀតទេលោកប្រធាន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងសម្រាក អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំពីរនាទី រហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចពិភាក្សា ស្ដាប់សក្ខីកម្មសាក្សីរូបនេះបន្តទៀត ។ មន្ត្រីតុលាការសម្របសម្រួល រកផ្ដល់កន្លែងសមរម្យសម្រាប់សាក្សីហ្នឹងសម្រាក ហើយនិងឲ្យនាំគាត់ត្រលប់មកវិញឲ្យបានមុនម៉ោងកំណត់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១០:២៥នាទី ដល់ម៉ោង ១០:៤៤នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោល ។ អស់លោកចៅក្រម តើមានសំណួរត្រូវសួរដល់សាក្សីរូបនេះដែរឬទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោក ស្ទួស ធី ខ្ញុំចៅក្រម ឡាវែន៍ ខ្ញុំសូមសួរលោកសំណួរមួយចំនួន ។ លោកបានពន្យល់យើងអំពីរបៀបដែលលោកធ្វើការងារ អំពីការរៀបចំបញ្ជីអ្នកទោសដែលចូលហើយនិងចេញ ខ្ញុំសូមឲ្យលោកប្រាប់ខ្ញុំតទៅទៀត នៅក្នុងការងារហ្នឹង ហើយក្រៅពីហ្នឹងតើលោកមានការទទួលខុសត្រូវផ្សេង

ទៀតទេ អំពីការចងក្រងជាបណ្ណសារនៅក្នុងស-២១ ឬក៏ជាមានឯកសារនីមួយៗដែលត្រូវរៀបចំសម្រាប់អ្នកទោសម្នាក់ៗដែរឬទេ?

**ឆ៖** ចំពោះបញ្ជីអ្នកទោស គឺខ្ញុំគ្មានភារកិច្ចអ្វីក្រៅពីធ្វើបញ្ជីរបៀបរបបហ្នឹងទេ គឺអត់មានរបៀបរបបធ្វើក្រៅពីហ្នឹងទេ គឺមានតែរបៀបរបបដូចដែលខ្ញុំធ្វើមកអ៊ីចឹង ។

**ស៖** ប្រហែលគឺមានការបញ្ហាក្នុងការបកប្រែ អ្វីដែលខ្ញុំសួរលោកនុ៎ង ក្រៅពីបញ្ជីអ្នកទោសដែលយើងនិយាយនោះ ថាតើមានថាអ្នកទោសម្នាក់ៗនោះ តើមានឯកសារមួយៗសម្រាប់អ្នកទោសម្នាក់ឧទាហរណ៍ចម្លើយសារភាព ឬក៏ព័ត៌មានអ្វីផ្សេងទៀតជាក់លាក់សម្រាប់អ្នកទោសម្នាក់ហ្នឹង គេយកមកដាក់ម្ដុំសម្រាប់អ្នកទោសម្នាក់មួយៗហ្នឹង មួយសំណុំមែនឬទេ? តើលោកជាអ្នកទទួលខុសត្រូវក្នុងការរៀបចំឯកសារបែបហ្នឹង ដូចខ្ញុំសួរហ្នឹងដែរឬទេ?

**ឆ៖** ដូចខ្ញុំសូមបញ្ជាក់ចំពោះឯកសារអ្នកទោស គឺខ្ញុំគ្មានធ្វើអ្វីក្រៅពីរបៀបរបបហ្នឹងទេ គឺមានតែក្រៅពីធ្វើរបៀបរបបអ្នកទោសដែលខ្ញុំជួបប្រវត្តិរូបសង្ខេប គឺឈ្មោះផ្ទាល់ខ្លួន ឪពុកម្ដាយ ហើយនិងភូមិឃុំ ឬក៏មកពីក្រសួងណា ឬក៏មកពីកងអង្គភាពណា គឺតែប៉ុណ្ណឹងទេ គឺអត់មានរៀបចំធ្វើបញ្ជីអ្នកទោសមួយម្នាក់ៗអំពីបញ្ហាអីៗទេ ។

[១០:៤៧:៤៨]

**ស៖** ដូច្នេះ លោកមិនដែលបានដំណើរការចងក្រងចំពោះអ្នកទោសម្នាក់ ដែលថាមានចម្លើយសារភាព ហើយមានចំណារចម្លើយសារភាពហ្នឹងយកមកបញ្ចូលក្នុងសំណុំរឿងមួយរបស់អ្នកទោសម្នាក់ហ្នឹង តើលោកបានធ្វើការជាមួយឯកសារហ្នឹង តើលោកបានផ្ទៀងផ្ទាត់ឯកសារបែបហ្នឹងដែរឬទេ?

**ឆ៖** ចំពោះឯកសារអ្នកទោស គឺខ្ញុំមិនដែលធ្វើក្រៅពីភារកិច្ចខ្ញុំទេ គឺយកពីឯកសារដែលផ្ទៀងផ្ទាត់ គេសួរចម្លើយផ្នែកត្រង់កងសួរចម្លើយទេ គឺខ្ញុំមិនបានជាយកមកបញ្ចូលនៅក្នុងបញ្ជីខ្ញុំទេ ។

**ស៖** ដូច្នេះ តាមដែលលោកដឹង តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការចងក្រងឯកសារទាំងហ្នឹង? ថាតើឯកសារទាំងអស់នោះគេទុកនៅកន្លែងណា?

**ឆ៖** ចំពោះឯកសារទាំងមូលរបស់ស-២១ ដែលគេចងក្រងសរុបទាំងអស់ គឺមានតែនៅផ្នែកខាងមន្ទីរកងសួរចម្លើយ ដែលមាន ម៉េង ជាអ្នកកាន់កាប់ ។ ប៉ុន្តែ ខ្ញុំបញ្ជាក់ ម៉េង ក្រោយមកគេចាប់ហើយ ។

**ស៖** ក្នុងចំណោមឯកសារមួយចំនួនច្រើនដែលយើងរកឃើញនោះ ដែលស្ថិតនៅក្នុងសារមន្ទីរប្រល័យពូជសាសន៍បច្ចុប្បន្ននេះ មានឯកសារមួយចំនួនដែលចេញមកពីស-២៤ ដែលលោកនិយាយទៅរក ហៅថាជា ស-២១ “ឃ” នៅពេលដែលលោកធ្វើការនៅកន្លែងនោះ តើលោកក៏ត្រូវយកបញ្ជីអ្នកទោសមកពីស-២១ មករៀបចំដំណើរការដែរឬទេ? ថាតើមានសេចក្តីសម្រេចអ្វីជាក់លាក់ដើម្បីធ្វើឲ្យឯកសារហ្នឹង វាមានភាពរួមប្រមូលផ្តុំទាំងអស់នៅស-២១ ដែរឬទេ?

**ឆ៖** ដូចខ្ញុំសូមបញ្ជាក់អ៊ីចឹង ចំពោះបញ្ជីផ្នែកស-២៤ គឺខ្ញុំមិនបានប្រមូលសរុបមកចូលនៅក្នុងបញ្ជីកងការពារទេក្នុងគុកធំនេះទេ គឺមានតែខាង ម៉េង ដែលជាមន្ទីររួមសរុបរបស់ស-២១ ដែលគេទទួលបញ្ជីពីស-២៤ ។

**ស៖** ប៉ុន្តែ បញ្ជីទាំងអស់ដែលលោកបានរៀបចំធ្វើនោះ មានប្រវត្តិរូបដែលលោកបានចងក្រង តើលោករក្សាទុកនៅកន្លែងណាមួយ ឬក៏ឯកសារហ្នឹងក៏ត្រូវផ្តល់ទៅឲ្យអ្នកសួរចម្លើយ? តើក្នុងការពិតធ្វើដូចម្តេច? តើលោកអ្នកទទួលខុសត្រូវក្នុងការរក្សាទុកបញ្ជី ហើយនិងប្រវត្តិរូបហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំសូមលោកបញ្ជាក់ម្តងទៀត ពីព្រោះខ្ញុំស្តាប់សំណួរអត់ទាន់បានច្បាស់ ។

**ស៖** ខ្ញុំនិយាយអំពីបញ្ជីដែលលោករៀបចំ គឺបញ្ជីអ្នកទោសចូល ហើយនិងអ្នកទោសដែលចេញយកទៅសម្លាប់នោះ បញ្ចេញយកទៅសម្លាប់ យើងនិយាយអំពីប្រវត្តិរូបដែលលោកបានធ្វើនៅពេលដែលអ្នកទោសមកដល់ ដែលលោកបានបិតរូបថតទៅលើហ្នឹងទៀត ។ អ៊ីចឹងសំណួរខ្ញុំ ថាតើលោកជាអ្នកទទួលខុសត្រូវក្នុងការរក្សាទុកឯកសារហ្នឹងដែរឬទេ? ឬដោយជាក់ស្តែងនោះ តើឯកសារហ្នឹងគេយកទៅទុកកន្លែងណា? ហើយអ្នកណាជាអ្នកទទួលភារៈខាងទុកឯកសារទាំងហ្នឹង?

[១០:៥២:៣៧]

**ឆ៖** ចំពោះឯកសារដែលខ្ញុំធ្វើ គឺវាមានពីរផ្នែក ទោះបីប្រវត្តិរូប ក៏ខ្ញុំធ្វើពីរច្បាប់ដែរ ។ ទីមួយឯកសារគឺនៅតម្កល់កន្លែងខាងកងការពារហ្នឹង ។ ទីពីរ គឺត្រូវបញ្ជូនទៅឲ្យ ម៉េង ជាអ្នកទុកដាក់ ។

**ស៖** ហើយឯកសារផ្សេងៗទៀតនិងបញ្ជី តើអ្នកណាជាទុកបញ្ជី? តើបញ្ជីនៅក្នុងកន្លែងលោកធ្វើការ ឬក៏នៅក្នុងបន្ទប់ណាផ្សេងទេ?

**ឆ៖** បើនិយាយជារួម គឺបញ្ជីរបស់ ស-២១ គឺនៅកន្លែង ម៉េង ។ ដោយឡែក បញ្ជីដែលខ្ញុំធ្វើនៅក្នុងកងការពារ គឺនៅក្នុងកន្លែងដែលខ្ញុំនៅសព្វថ្ងៃហ្នឹង-- មិនមែននៅសព្វថ្ងៃសុំទោស គឺនៅកន្លែងដែលខ្ញុំធ្វើការកាលនៅសម័យនោះ ។

**ស៖** ដូច្នេះ គឺនៅក្នុងកន្លែងដែលលោកធ្វើការហ្នឹង ដែលលោកធ្វើការកន្លែងធ្វើការជាមួយ ម៉េង ហើយជាមួយអ្នកផ្សេង ហើយនៅក្នុងបន្ទប់តែមួយ ដែលថាឯកសារទាំងអស់នៅស-២១ គេរក្សាទុកកន្លែងហ្នឹង តើអ៊ីចឹងមែនឬទេ?

**ឆ៖** ចំពោះឯកសារផ្នែកខាងមន្ទីររបស់ ម៉េង គឺគេនៅខាងក្រៅឯណោះ ។ ចំពោះឯកសារនោះខាងផ្នែកកងការពារចំពោះអ្នកទោសដែលនៅគុក គឺនៅខាងក្នុង ពីព្រោះខ្ញុំសូមបញ្ជាក់បន្ថែមថា មន្ទីររបស់ ម៉េង ហ្នឹង គឺគេទុកឯកសារទាំងអស់ ទាំងផ្នែកកងសួរចម្លើយ ទាំងផ្នែកសួរចម្លើយ ទាំងផ្នែកសរុបអ្នកទោសក្នុងមន្ទីរស-២១ រួមទាំងអស់ គឺគេនៅខាងក្រៅ ។

**ស៖** នៅពេលដែលអ្នកទោសមកដល់ស-២១ តើគេអនុញ្ញាតឲ្យយករបស់របរមកតាមខ្លួនទេ ដូចជារបស់អ្វីមួយចំនួន ដូចជារបស់ដែលគេយកមកជាមួយហ្នឹង គេដកហូតចេញ ឬក៏មានបញ្ជីចុះពីរបស់ដែលគេដកហូតពីអ្នកទោសហ្នឹងដែរឬទេ?

**ឆ៖** ជាធម្មតាចំពោះអ្នកទោសដែលចូលមកក្នុង ដល់ក្នុងគុកធំ ជាទូទៅគឺអ្នកទោស គឺគេចាត់តាំងពីក្រោមកហើយ ឬក៏គេ អ្នកទោសនោះច្រើនបញ្ជូនពីគ្រប់ក្រសួង គ្រប់ភូមិភាគទាំងអស់ ។ ដូច្នេះ គឺអត់មានសម្ភារៈអ្វីមកតាមជាមួយអ្នកទោសទេ ។

**ស៖** ដូច្នេះ មិនមានអ្នកទោសណាម្នាក់ដែលគេបញ្ជូនមកស-២១ ដោយមាននាឡិកាដៃ ឬក៏គ្រឿងអលង្ការ ឬក៏របស់អីអនុស្សាវរីយមកជាមួយ តាមដែលលោកជួបហ្នឹង គឺមិនដែលមានឃើញទេ តើមែនទេ?

[១០:៥៦:៣៥]

**ឆ៖** ពីព្រោះអ្នកទោសតែចូលមកដល់កន្លែងខ្ញុំ គឺមានតែខោខ្លីហើយ ពីព្រោះគេដោះចេញអស់ហើយពីខាងក្រៅ ។ តែចំពោះខាងក្រៅមិនដឹងគេដកពីត្រឹមណា គឺខ្ញុំមិនបានច្បាស់ទេ ។

**ស៖** ហើយប្រសិនបើវាមានគ្រឿងអលង្ការផ្ទាល់ខ្លួនមកជាមួយ ថាតើគេធ្វើដូចម្តេចមកដល់ស-២១ នោះ?

**ឆ៖** តាំងពីខ្ញុំនៅកាន់កន្លែងបញ្ជីខាងក្នុងចំពោះអ្នកទោសទាំងអស់ គឺមិនដែលយកមកនៅក្នុងមន្ទីរស-២១ ទេ គេច្រើនតែចាប់ពីក្រោមកទាំងអស់ ។ ដូច្នេះ គឺអត់មានអលង្ការ ឬក៏អត់មានសម្ភារៈអីមកតាមខ្លួនទេ ពីព្រោះក្នុងគុកហ្នឹង គឺតែចូលគុក គឺកន្លែងហ្នឹងគេដោះចេញពីនោះអស់ហើយ ។

**ស៖** លោកធ្វើការនៅស-២១ ចាប់តាំងពីចាប់ផ្តើមដំបូងរហូតដល់ពេលបញ្ចប់នៃស-២១ តើលោកនៅចាំឈ្មោះ ហ៊ឹម ហ៊ុយ ដែលជាអ្នកទទួលខុសត្រូវក្នុងកងពិសេស លោកនៅចាំគាត់ទេ?

**ឆ៖** បាទ, ខ្ញុំនៅចាំ ។

**ស៖** តើលោកនៅចាំដែរឬទេ ដែលថា ហ៊ឹម ហ៊ុយ នៅក្នុងឆ្នាំ១៩៧៨ ថា ហ៊ឹម ហ៊ុយ ដែលថាគាត់ត្រូវចេញពីស-២១ ឆ្នាំ១៩៧៨ ឬក៏តាមលោកចាំ គាត់នៅស-២១ រហូតដល់ចប់?

**ឆ៖** ដែលខ្ញុំចាំមិនបានច្បាស់ពីបញ្ហាអស់នេះ ពីព្រោះ ហ៊ុយ គេនៅខាងក្រៅ ហើយដល់ចុងឆ្នាំ៧៨ ហ្នឹងក៏ខ្ញុំមិនបានជាឃើញ ហ៊ុយ ហ្នឹងមកកន្លែងគុកហ្នឹងដែរ ពីព្រោះអ្នកទោសវាកាន់តែរយាលហើយចុងឆ្នាំ៧៨ហ្នឹង ។ ប៉ុន្តែជាការពិត គឺខ្ញុំមិនអាចសន្និដ្ឋានបានទេ គឺខ្ញុំមិនបានដឹងទេ ។

**ស៖** តើទំនាក់ទំនង លោកមានទំនាក់ទំនងដូចម្តេចជាមួយជនជាប់ចោទ? ថាតើជនជាប់ចោទជាអ្នកមកត្រួតពិនិត្យការងាររៀបចំត្រៀមបញ្ជីរបស់លោកដែរឬទេ? តើលោកអាចប្រាប់យើងបានទេអំពីការងារទំនាក់ទំនងទាំងនោះ?

[១១:០០:០៤]

**ឆ៖** ចំពោះជនជាប់ចោទ គឺការទំនាក់ទំនង គឺគេធ្វើតាមខ្សែរយៈ គេមិនដែលទំនាក់ទំនងមកផ្ទាល់ជាមួយខ្ញុំទេ គេច្រើនតាមរយៈ ហ៊ី ពីព្រោះអង្គភាពដាច់ផ្សេងពីគ្នា ។ ហើយចំពោះការណែនាំអ្វី គឺគេណែនាំទៅ ហ៊ី ហើយបាន ហ៊ី បញ្ជាឲ្យខ្ញុំទៅធ្វើ ។

**ស៖** តើលោកមានលទ្ធភាពឬមានឱកាសដែលធ្លាប់ជួបជនជាប់ចោទដែរឬទេ? ដែលលោកជួបនៅក្នុងទីតាំងបរិវេណស-២១ ។ តើលោកធ្លាប់បានឃើញគាត់ដែរឬទេ ក្នុងពេលដែលលោកធ្វើការងារនៅកន្លែងរបស់លោក? តើលោកធ្លាប់ឃើញគាត់ចូលអគារណាមួយនៅស-២១ ដែរឬទេ?

**ឆ៖** ការដែលគាត់ចូលមកនៅក្នុងគុកនេះ គឺខ្ញុំច្រើនឃើញគាត់ខ្លះដែរ ប៉ុន្តែគាត់ច្រើនតែមកកន្លែងគូររូប កន្លែងជាងឆ្លាក់ ហើយនឹងជួប ហ៊ី តែប៉ុណ្ណោះ ។ ប៉ុន្តែ ចំពោះការដែលគាត់ឡើងទៅតាមអគារគឺខ្ញុំមិនបានជាចាប់អារម្មណ៍ឡើងទៅ ឬអត់ទេ ពីព្រោះបញ្ហានេះ ខ្ញុំគ្មានភារកិច្ចទៅតាមដានគាត់ទេ ។

**ស៖** ដូច្នេះ អ្វីដែលលោកកំពុងតែជម្រាបជូនយើងខ្ញុំ លោកបានឃើញគាត់នៅក្នុងបរិវេណស-២១ ។ នៅទីកន្លែងនានា គឺក្រៅពីកន្លែងគូររូប កន្លែងឆ្លាក់ ឬក៏យ៉ាងម៉េច? តើត្រឹមត្រូវដែរឬទេ ចំណុចនេះ?

**ឆ៖** ខ្ញុំច្រើនតែឃើញគាត់នៅកន្លែងគូររូប កន្លែងឆ្លាក់ កន្លែងនានា គឺច្រើនតែជួប ហ៊ា នៅខាងក្រៅ-- នៅខាង-- អង្គុយខាងមុខ ផ្ទះខាងមុខនោះ ។

**ស៖** តើលោកធ្លាប់ឃើញគាត់នៅកន្លែងណាផ្សេងទៀតទេ នៅក្នុងបរិវេណស-២១?

**ឆ៖** ក្រៅពីហ្នឹង គឺខ្ញុំច្រើនតែឃើញកន្លែងគាត់មកហូបបាយម្តងៗ ។

**ស៖** ក្នុងការយល់ឃើញរបស់លោក ការចូលមកនៃអ្នកទោសទាហានវៀតណាមនោះ គឺជាការដែលលោកមានការភ្ញាក់ផ្អើល ឬក៏ចំណុចនេះគេបានពិភាក្សារួចហើយ នៅក្នុងជួរថ្នាក់ដឹកនាំ និងមេៗរបស់លោក?

**ឆ៖** ចំពោះបញ្ហាអ្នកទោសវៀតណាម គឺខ្ញុំមិនបានដឹងពីបញ្ហាអ្វី គឺដឹងតែអ្នកទោសថាចូលមក គឺខ្ញុំកត់តែប៉ុណ្ណឹង ។ ការពិភាក្សាមុនៗអ្វី គឺខ្ញុំអត់បានដឹងទេ ។

[១១:០៤:៣៧]

**ស៖** ប៉ុន្តែខ្ញុំមិនសួរជាក់លាក់ទៅលើបញ្ហានោះទេ ។ ខ្ញុំសួរនិយាយអំពីការចូលមកដល់នៃទ័ពវៀតណាម នៅក្នុងឆ្នាំ១៩៧៩ ថាតើនៅពេលដែលទ័ពវៀតណាម មកដល់នៅឆ្នាំ៧៩ នោះ ធ្វើឲ្យលោកភ្ញាក់ផ្អើល ឬក៏បញ្ហានេះ គេយកទៅពិភាក្សាមុនរួចហើយ? ហើយតើមានការពិចារណាទៅលើវិធានការណាមួយដែរឬទេ? ឧទាហរណ៍ថា មានផែនការកម្ទេច កន្លែងរក្សាឯកសារនៅស-២១ ដែរឬទេ? ឬក៏មានការបំផ្លាញឯកសារផ្សេងៗរួចទៅហើយ មុនពេលដែលវៀតណាមហ្នឹង ចូលមកដល់?

**ឆ៖** នេះខ្ញុំសូមបញ្ជាក់ ចំពោះការដែលកងទ័ពវៀតណាមចូលមកក្នុងឆ្នាំ៧៩ ភ្នំពេញនេះ គឺមិនដឹងផែនការអីមុនទេ មិនដឹងជាវៀតណាមចូលមកដល់ណាដល់ណីទេ ពីព្រោះនៅក្នុងគុកហ្នឹង គ្មានអ្នកណាសិទ្ធិដើរទៅណាដើរទៅណីទេ ដូច្នេះជានៅក្នុងអណ្តូងអ៊ីចឹង គឺអត់មានដឹងថាសភាពការណ៍អីខាងក្រៅយ៉ាងម៉េចយ៉ាងម៉ា ហើយចំពោះផែនការកម្ទេចឯកសារ គឺក៏អត់មានផែនការអីដែរ ពីព្រោះគ្មានដឹងអីទាំងអស់ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណច្រើន ។ លោកប្រធាន ខ្ញុំពុំមានសំណួរផ្សេងទៀត សម្រាប់សាក្សីរូបនេះទេ ។
សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

បន្តនេះ សូមអង្គជំនុំជម្រះប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរ

ដល់សាក្សីរូបនេះ ។ តំណាងសហព្រះរាជអាជ្ញា មានពេលសែសិបប្រាំនាទី ចាប់ពីពេលនេះទៅ គឺដប់មួយប្រាំនាទី ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

អរគុណ លោកប្រធាន អង្គជំនុំជម្រះ និងសូមស្វាគមន៍ លោក សួស ធី ។

**ស៖** សំណួរទីមួយជូនលោក កាលពីម្សិលមិញលោកបានជម្រាបជូនអង្គជំនុំជម្រះរួចមកហើយថាលោកស្ថិតនៅក្រុមកងការពាររបស់មន្ទីរស-២១ ហើយទទួលបន្ទុកជាអ្នកធ្វើបញ្ជី ។ សំណួរសួរថាតើនៅក្នុងក្រុមរបស់លោកនុ៎ង ដែលជាក្រុមការពារនុ៎ង តើលោកអាចចាំបានទេ មានគ្នាប៉ុន្មាននាក់? ហើយក្នុងនោះដែលអាចមានឈ្មោះ គក ស្រស់ ដែរទេ? ហើយលោកមានដែលស្គាល់គាត់ទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ ចំពោះផ្នែកកងការពារ ការក្តាប់ចំនួនគឺខ្ញុំមិនបានដឹងពិតប្រាកដទេ ។ ហើយចំពោះឈ្មោះ គា ស្រស់ នេះ កាលពីមុនរហូតដល់បច្ចុប្បន្ននេះ គាត់-- គឺខ្ញុំចំពោះតែខ្លួនខ្ញុំ ក៏អត់បានដឹងគាត់នៅក្នុងកងការពារដែរ ។ នេះនិយាយដោយត្រង់ ប៉ុន្តែដល់គាត់រៀបរាប់ គាត់យាមនៅក្រុមនេះៗទៅបានទើបខ្ញុំចាប់អារម្មណ៍ ។ ប៉ុន្តែ ការដែលខ្ញុំស្គាល់ ពីព្រោះស្គាល់ច្បាស់ពិតប្រាកដទាំងអស់ គឺសូម្បីតែខ្លួនខ្ញុំ ក៏អត់ជាចាប់អារម្មណ៍ដែរ ចំពោះរឿងកងការពារ ។

[១១:០៨:៣០]

**ស៖** អរគុណលោក សួស ធី ។ សំណួរទីពីរ កាលពីម្សិលមិញ លោកក៏បានបញ្ជាក់ជូនអង្គជំនុំជម្រះផងដែរថា នៅរាល់អគារនីមួយៗវាមានពេទ្យព្យាបាលម្នាក់ ថាតើលោកមានការចងចាំឈ្មោះពេទ្យព្យាបាលនៅមន្ទីរសន្តិសុខនោះ មានចាំឈ្មោះណាមួយទេ? ហើយក្នុងនោះមានគ្រូពេទ្យជាស្ត្រីទេ? ហើយប្រធានពេទ្យនោះ មានឈ្មោះអ្វីដែរ នៅក្នុងមន្ទីរសន្តិសុខហ្នឹង?

**ឆ៖** ចំពោះពេទ្យនៅក្នុងមន្ទីរស-២១ ចំពោះការចងចាំរបស់ខ្ញុំ គឺខ្ញុំដឹងថាពេទ្យមាន មិនបានដឹងពិតប្រាកដ ប៉ុន្តែវាយូរឆ្នាំហើយ ដូច្នេះការចងចាំគឺវាភ្លេច ។ ប៉ុន្តែ ខ្ញុំនៅចាំច្បាស់ៗ គឺនៅបីនាក់--ពីរនាក់ ប៉ុន្តែបើតាមពិតពេទ្យវាមានដល់បួននាក់ឯណោះ ប៉ុន្តែខ្ញុំភ្លេចពីរនាក់ទៅទៀតហើយ ។ ហើយការចងចាំដែលនៅសល់ពីរនាក់នោះ គឺពេទ្យ រិន និងពេទ្យ ទ្រី ។ ពេទ្យ រិន និងពេទ្យ ទ្រី ហើយចំពោះអ្នកដែលក្តាប់រួមពេទ្យពីមុនៗមក គឺមាន ប៉ុន្តែខ្ញុំភ្លេចហើយ ។ ប៉ុន្តែក្រោយពីចាប់អ្នកមុនមក គឺអ្នកក្រោយឡើងពេទ្យ រិន ជាប្រធាន ។ ប៉ុន្តែក្រោយពីចាប់ពេទ្យ រិន, ពេទ្យ ទ្រី ទៀតទៅ គឺនៅតែពេទ្យ

កុមារ ប៉ុន្តែខ្ញុំចាំមិនច្បាស់ ពីព្រោះពេទ្យកុមារហ្នឹង គឺមកពីខាងផ្នែកអមលាំង ពីខាងពេទ្យកង៧០៣ អស់ហើយ ។ ដូច្នេះ វានៅតែពេទ្យកុមារ ដែលមកខាងអមលាំង ដូច្នេះខ្ញុំចាំមិនច្បាស់ ។ ប៉ុន្តែ ចំពោះការដែលខ្ញុំដឹងជាទូទៅនៅមន្ទីរស-២១ ផ្នែកខាងពេទ្យ អានេះខ្ញុំមិនច្បាស់ជាអ្វីទេ ប៉ុន្តែ ខ្ញុំនិយាយជាការពិត គឺពេទ្យស្ត្រីអត់មានទេ ។

**ស៖** អរគុណលោក ។ សំណួរទីបីជូនចំពោះលោក នៅក្នុងកំណត់ហេតុចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ដែលចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលមានលេខ ERN00181328 D86/16 នុ៎ង លោកបានបញ្ជាក់ថា អគារ “A” ដែលហៅថា អក្សរ “ក” នោះ គឺទុកសម្រាប់ដាក់តែអ្នកទោសសំខាន់ ឬពិសេស អាចជាកម្មាភិបាល ។ តើអគារនុ៎ងជាអគារដូចលោកបានអះអាងនៅក្នុងកំណត់ហេតុនុ៎ងមែនទេលោក?

**ឆ៖** ដូចខ្ញុំសូមបញ្ជាក់ ចំពោះអគារ “A” គឺសម្រាប់ដាក់តែអ្នកទោស គេហៅថាគុកពិសេស ។ គុកពិសេសនេះគឺ បន្ទាប់ពីគុកពិសេសខាងក្រៅ គេប្រមូលយកមកដាក់ខាងក្នុងវិញ ។ ដូច្នេះ អគារ “A” គឺសម្រាប់អ្នកទោសខាងក្រៅ ប៉ុន្តែពីមុនដែលគេមិនទាន់យកដាក់អ្នកទោសពិសេសនោះ គឺអគារ “A” នេះ គឺដាក់អ្នកទោសជាទូទៅ ។ ប៉ុន្តែអគារ “A” នេះ គឺអត់មានបន្ទប់តូចទេ គឺបន្ទប់ធំទាំងអស់ ។

[១១:១២:១៥]

**ស៖** អរគុណ លោក សួស ធី ។ សំណួរបន្ទាប់ នៅក្នុងកំណត់ហេតុ ចុះថ្ងៃទី២៧ ខែ៨ ឆ្នាំ២០០៨ ដែរនោះ ដែលមានលេខ ERN លេខ 00181395 នុ៎ង នៅក្នុងនោះ វាមានដើមបណ្ដឹងលេខ B80, D48-2 រូបថតលេខ៣៤ ។ តើនៅក្នុងរូបថតនេះ លោកពិតជាបានផ្ដល់គំនិតថា ថានេះគឺជាអ្នកជំងឺម្នាក់ ដែលស្លាប់នៅក្នុងបន្ទប់ឃុំឃាំង មែនឬទេលោក?

សូមអនុញ្ញាតពីលោកប្រធានអង្គជំនុំជម្រះដើម្បីបង្ហាញរូបថតលេខ៣៤ ស្ថិតនៅក្នុងD48-2/2។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងផ្នែកខាងសោតទស្សន៍បង្ហាញនូវរូបថតនៅលើកញ្ចក់អេក្រង់ទូរទស្សន៍តាមស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា ។

**លោក តាន់ សេណារ៉ុង៖**

សុំៗការអនុញ្ញាតខាងសោតទស្សន៍ហ្នឹងភ្ជាប់មកកុំព្យូទ័ររបស់--

**ប្រធានអង្គជំនុំ៖**

ប្តូរវិធីវិញ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** នេះគឺជារូបថត ដែលលោកបានអះអាងនៅក្នុងកំណត់ហេតុ ចុះថ្ងៃទី២៧ ខែ៨ ហ្នឹង ។ តើរូបថតនេះ ដែលតាមការអះអាងរបស់លោកនោះ ថាធ្វើឡើងសម្រាប់ទុកជាភស្តុតាង ដើម្បីបញ្ជាក់ពីករណីមានការបាត់ខ្លួនរបស់អ្នកទោស ដូចការអះអាងរបស់លោកនៅក្នុងកំណត់ហេតុនុ៎ង អ៊ីចឹងទេឬ?

**ឆ៖** ដូចខ្ញុំសូមបញ្ជាក់អ៊ីចឹង។ ចំពោះអ្នកទោសដែលស្លាប់នេះ គឺខ្ញុំមិនបានដឹងជាផ្ទាល់ ឬឃើញជាក់ស្តែងទេ ពីព្រោះការស្លាប់របស់អ្នកទោសនៅក្នុងគុក ជាអ្នកជំងឺ គឺពេទ្យគេរាយការណ៍ទៅ ហ៊ី ហើយខ្ញុំគ្រាន់តែចុះបញ្ជីទេ ទៅតាមឈ្មោះនោះ ។ ដូច្នេះ ការដែលឃើញនេះ គឺខ្ញុំគ្រាន់តែជាការសន្និដ្ឋាន វាមិនបានពិតប្រាកដទេ ។

**ស៖** អរគុណលោក សួស ធី ។ នៅក្នុងនោះដែរ សំណួរបន្ទាប់ ថាតើមានអ្នកទោសដែលបានស្លាប់នៅមន្ទីរសន្តិសុខស-២១ ហ្នឹងភាគច្រើនស្លាប់ដោយសារជំងឺ ឬក៏ស្លាប់ដោយសារធ្វើទារុណកម្មភាគច្រើន? ឬក៏មានការស្លាប់ដោយសារអត់អាហារផងដែរ? ជាការបញ្ជាក់បន្ថែម ។

**ឆ៖** ការរាយការណ៍ចំពោះអ្នកជំងឺដែលឈឺស្លាប់គឺពេទ្យគេបញ្ជាក់មក ។ ដូច្នេះ បញ្ហាការឈឺស្លាប់នេះ ខ្ញុំសន្និដ្ឋានមិនបានច្បាស់លាស់ទេ ប៉ុន្តែ ជាពិសេសគឺដោយសារតែការធ្វើទារុណកម្មរួមនឹងការអាហារជីវជាតិមិនដល់ គឺអត់មានបានហូបគ្រប់គ្រាន់ ។

**ស៖** អរគុណលោក សួស ធី ។ សំណួរបន្ទាប់ កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ នៅក្នុងកំណត់ហេតុយកចម្លើយរបស់ជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច នោះដែលមានD42 ERN 00159560 ហ្នឹងបានបញ្ជាក់ថា ចំពោះការសម្លាប់នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៨ ខ្ញុំសូមបញ្ជាក់ថា ហ៊ី បានផ្តល់ការណែនាំទៅ ប៉េង ប្រធានកងការពារមុនការចាកចេញរបស់គាត់ ។ ប៉ុន្តែ ដោយសារតែ សួស ធី ជាអ្នកទទួលខុសត្រូវបញ្ជីនិងឯកសារមើលអង្គការលេខដែលមានជាប់នៅក្នុងកំណត់ហេតុចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧ មិនយល់ព្រម ។ សួស ធី បានទាមទារឲ្យមានចំណារជាលាយលក្ខណ៍អក្សរពីខ្ញុំ ហេតុដូច្នេះបានជាមានហត្ថលេខារបស់ខ្ញុំ ។

អ៊ីចឹង សុំមានការអនុញ្ញាតពីលោកប្រធានអង្គជំនុំជម្រះដើម្បីឲ្យខាងសោតទស្សន៍បង្ហាញឯកសារមួយដែលមានលេខ 00159571 ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍បង្ហាញឯកសារនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ តាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញា។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** នៅក្នុងនោះសំណួរសួរថា តើក្នុងខ្លឹមសារខាងលើនេះ លោកពិតជាបានស្នើទៅ ប៉េង ឲ្យមានចំណាររបស់ជនជាប់ចោទហៅ ឌុច អ៊ីចឹងមែនទេ?

**ឆ៖** ចំណារនេះគឺមិនមែនអក្សរខ្ញុំទេ ។ ខ្ញុំមិនដែលមានសិទ្ធិដើម្បីស្នើអីទេ ។ អក្សរនេះគឺអក្សរ ឌុច ទេ ។

**ស៖** អរគុណលោក អក្សរនេះគឺជាអក្សរ ឌុច។ ប៉ុន្តែ ជនជាប់ចោទនៅក្នុងកំណត់ហេតុយកចម្លើយ សួរចម្លើយរបស់គាត់នោះគាត់បានឆ្លើយថា វាមានការទាមទារពីលោកឲ្យធ្វើអ៊ីចឹង បានជាគាត់ដែលជាជនជាប់ចោទនោះ ចារទៅជូនលោកថាឲ្យ ប៉េង វាយចោលឲ្យហ្មត់ហ្នឹង ។ នេះគឺជាចម្លើយនិងជាចំណាររបស់ជនជាប់ចោទឈ្មោះ ឌុច ។ ប៉ុន្តែ មុននឹងចារនេះ ឌុច គាត់បានឆ្លើយនៅក្នុងកំណត់ហេតុហ្នឹងថា លោកទាមទារឲ្យធ្វើអ៊ីចឹង។ អ៊ីចឹងបានជាសំណួរសួរថា តើលោកពិតជាបានសុំឲ្យ ឌុច ហ្នឹងចារអ៊ីចឹងមែនទេ?

**ឆ៖** គឺខ្ញុំគ្មានសិទ្ធិអីទៅសុំរឿងបញ្ហាចំណារអីទេ ពីព្រោះការអ្វីៗគឺនៅលើ ហ៊ា ដែលជាមេខ្ញុំទេ ដែលជាអ្នកសុំ ប៉ុន្តែខ្ញុំគឺគ្មានសិទ្ធិអីទៅជាមួយ ឌុច នោះទេ ។

**ស៖** អរគុណលោក។ សំណួរបន្ទាប់ ជាទូទៅនៅពេលដែលយកអ្នកទោសទៅសម្លាប់ម្តងៗនោះ តើក្រុមរបស់ប៉េង ហើយមាន ផល, មាន ហ៊ឹម ហ៊ុយ ហ្នឹង ត្រូវតែមានការអនុញ្ញាតពីជនជាប់ចោទជាមុនសិនដែរឬ ដើម្បីយកអ្នកទោសចេញទាំងនុំង?

**ឆ៖** ជារួម ឬជាគោលការណ៍គឺចំពោះការដែលយកអ្នកទោសចេញគឺអ្នកទោសចូលគឺទាល់តែមានការអនុញ្ញាតពី ឌុច ដែលជាប្រធានរបស់ស-២១ ។ គឺអ្វីៗទាំងអស់អ្នកដែលធ្វើគឺគ្មានសិទ្ធិអ្វីទាំងអស់ ទាល់តែមានបញ្ជាពី ឌុច បានអ្វីៗបានធ្វើទៅកើត ។

**ស៖** អរគុណលោក នេះជាសំណួរបន្ទាប់ជាមួយនឹងសំណួរទាំងនោះ។ ចុះនៅពេលដែលផ្ទៀងផ្ទាត់បញ្ជីអ្នកទោសនោះ និងចំនួនអ្នកទោសជាក់ស្តែងនោះនៅពេលដែលយកសម្លាប់ម្តងៗតើលោកមានធ្លាប់ឃើញជនជាប់ ឌុច ហ្នឹងទៅឈរមើលហើយបញ្ជាដែរឬទេ?

**ឆ៖** ចំពោះការផ្ទៀងផ្ទាត់បញ្ជីអ្នកទោសដែលយកចេញនោះ ជាទូទៅគឺគ្មានដែល ឌុច យកទៅបញ្ហាទេ គឺការនេះផ្នែកខាងកងការពារ គឺភារកិច្ចមួយៗដាច់ដោយឡែកពីគ្នា ។ គ្រាន់តែបញ្ជាគេគឺថាឲ្យយកចេញគឺយើងធ្វើយ៉ាងម៉េចឲ្យបានត្រឹមត្រូវ គឺយើងខ្លាចគ្រោះថ្នាក់ខ្លួនឯង ។

[១១:២២:១៥]

**ស៖** សំណួរបន្ទាប់។ នៅក្នុងកំណត់ហេតុយកចម្លើយចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ របស់ជនជាប់ចោទឈ្មោះកាំង ហ្គេកអ៊ាវ ហៅ ឌុច ហ្នឹង ដែលមានលេខ ERN00166588, D54 នៅក្នុងនោះលោក ចៅក្រម ម៉ាសែល ឡឺម៉ុងដ៍ បានសួរលោកថា លោក សួស ធី តើលោកនៅតែបញ្ជាក់អះអាងចម្លើយរបស់លោកដែលលោកបានឆ្លើយនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧ ទាក់ទងទៅនឹងការបូមឈាមរបស់ជនរងគ្រោះ ដែលត្រូវបានដាក់បញ្ចូលក្នុងបញ្ជីនៃអ្នកទោសត្រូវយកទៅកម្ទេចដែរឬទេ? ហើយចម្លើយរបស់លោកហ្នឹង ដែលមានទាក់ទងទៅនឹងការបូមឈាមរបស់ជនរងគ្រោះដែលត្រូវបានដាក់បញ្ចូលក្នុងបញ្ជីនៃអ្នកទោសត្រូវយកទៅកម្ទេចដែរឬទេ? ហើយចម្លើយរបស់លោកហ្នឹង នៅថ្ងៃដែលមានERN162594 ត្រង់ចំណុចERNលេខ 162604 តើលោកនៅតែទទួលស្គាល់ដូចលោកបានអះអាងនៅក្នុងកំណត់ហេតុនុ៎ងអ៊ីចឹងឬ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ចំពោះកំណត់ហេតុដែលខ្ញុំបាន កាលពីលើកមុន គឺខ្ញុំសុំទទួលចំពោះការបូមឈាមនេះពីព្រោះការបូមឈាមនេះ គឺ ហ៊ី ជាអ្នកបញ្ជាឲ្យខ្ញុំដាក់ឈ្មោះ អ្នកបូមឈាមនៅក្នុងបញ្ជីកម្ទេច ប៉ុន្តែចំពោះការយកអ្នកទោសទៅបូមឈាមនេះ គឺពេទ្យគេស្នើទៅ ហ៊ីៗ គេស្នើទៅ ឌុច បានគេប៊ានធ្វើ។ ដូច្នេះ អ្វីៗទាំងអស់ទាល់តែពីលើអនុញ្ញាតបានគេប៊ានធ្វើក្នុងការបូមឈាមនេះ ។

**លោក តាន់ សេណារ៉ុង៖**

សំណួរបន្ទាប់ជូនលោក។ សុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញឯកសារដែលមានលេខ ERN00177943 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍បង្ហាញឯកសារនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។ ឯកសារដែលមានលេខERN 00177943 ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** លោក សួស ធី ថាតើលោកស្គាល់និងចាំបានទេ ថាតើប្រវត្តិរូបនេះលោកពិតជាអ្នកបាន

ធ្វើទៅលើអ្នកទោសម្នាក់ដែលមានឈ្មោះថា ភឹង តុន ហ្នឹងមែនទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ចំពោះប្រវត្តិរូបនេះ គឺពិតជាខ្ញុំបានធ្វើចំពោះអ្នកទោស ភឹង តុន មែន ។

**ស៖** អរគុណលោក ។ តើលោកអាចចាំបានទេថា នូវវាសនារបស់អ្នកទោសម្នាក់នេះ ថាតើគាត់ហ្នឹង បានស្លាប់ដោយសារជំងឺ ឬក៏បានស្លាប់ដោយសារការយកទៅកម្ទេចនៅទីណាមួយនៅជើងឯក ឬក៏នៅក្នុងបរិវេណណាមួយនៃមជ្ឈមណ្ឌលស-២១ ហ្នឹង? តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេ?

**ឆ៖** ដូចខ្ញុំសូមបញ្ជាក់អ៊ីចឹង ។ ចំពោះអ្នកទោសជាទូទៅគឺខ្ញុំម្នាក់ឯងមិនអាចជាប្រាកដប្រជាថាអ្នកទោសណាជាអ្នកទោសណាទេ ។ ដូច្នេះ ការសន្និដ្ឋានរបស់ខ្ញុំចំពោះអ្នកទោសនេះ មិនដឹងជាស្លាប់ដោយជំងឺ ឬក៏គេយកទៅកម្ទេចទេ ប៉ុន្តែខ្ញុំមិនបានដឹងពិតប្រាកដទេ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោក។ សំណួរចុងក្រោយរបស់ខ្ញុំជូនអង្គជំនុំជម្រះសូមឲ្យខាងសោតទស្សន៍ហ្នឹងបង្ហាញឯកសារលេខ ERN00188853 ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍បង្ហាញនូវឯកសារដែលមានលេខ ERN តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញាជាតិនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** សំណួរសួរថា តើបញ្ជីអ្នកទោសចូលថ្ងៃទី១២ ខែ១២ ឆ្នាំ១៩៧៦ ហ្នឹងលោកជាអ្នកបានធ្វើលើបញ្ជីហ្នឹងមែនទេ លោកចងចាំទេ? ហើយក្នុងហ្នឹងមានឈ្មោះអ្នកទោសដែលជាអតីតសាស្ត្រាចារ្យឈ្មោះ ភឹង តុន នៅក្នុងនោះដែរ ។

**ឆ៖** ដូចខ្ញុំសូមបញ្ជាក់អ៊ីចឹង គឺចំពោះបញ្ជីនេះ ខ្ញុំធ្វើពិតប្រាកដមែន ។ ប៉ុន្តែចំពោះការចងចាំ គឺខ្ញុំមិនបានចងចាំច្បាស់ទេ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណអង្គជំនុំជម្រះ និងលោក សួស ធី ដែលបានឆ្លើយនឹងសំណួររបស់ខ្ញុំ ។ ខ្ញុំនឹងជូននាទីបន្ទាប់ទៅសហការីរបស់ខ្ញុំ ។

**សួរដោយ លោក អានីស អះមេដ៖**

**ស៖** លោក សួស ធី លោកមានការងារជាអ្នកប្រមូលស្ថិតិថាតើនៅក្នុងពេលណាមួយ តើចំនួនអ្នកទោសសរុបនៅស-២១ មានចំនួនប៉ុន្មាន? ប៉ុន្មាន?

[១១:២៨:០៥]

**ឆ៖** ដូចខ្ញុំសូមបញ្ជាក់អ៊ីចឹង គឺថាចំនួនអ្នកទោសសរុបសូម្បីកុំថាប្រចាំឆ្នាំ ប្រចាំខែក៏អត់បានធ្វើសរុបដែរ ។ ពីព្រោះការងាររាល់ថ្ងៃវាដេញជើងការងារធ្វើមិនទាន់ផងម្នាក់ឯង ។

**ស៖** ខ្ញុំសូមសួរឡើងវិញនៅក្នុងពេលមួយ ថាតើសមត្ថភាពស-២១ អាចទទួលអ្នកទោសបានច្រើនបំផុតហ្នឹងចំនួនប៉ុន្មាន?

**ឆ៖** ចំពោះស-២១ ចំពោះអ្នកទោសដែលសមត្ថភាពអាចចូលក្នុងស-២១ គឺខ្ញុំមិនដឹងមិនប្រាកដជាសមត្ថភាពប៉ុន្មានទេ ប៉ុន្តែបើចូលមកគេចេះតែដាក់ចូលទៅ ចូលក្នុងគុកហ្នឹង មិនដឹងសមត្ថភាពយ៉ាងម៉េច ដឹងចំនួនពិតប្រាកដដែលអាចប៉ុន្មាននោះ ខ្ញុំសន្និដ្ឋានមិនបានទេ ។

**ស៖** តើមានពេលណាមួយទេ ដែលស-២១ មានអ្នកទោសពេញទាំងអស់ហើយយើងអត់មានពេល មានកន្លែងណាសម្រាប់ដាក់អ្នកទោសថ្មីមកទៀតទេ តើធ្លាប់មានអ៊ីចឹងទេ?

**ឆ៖** ស-២១ គឺមិនអាចពេញទាំងអស់ទេ ពីព្រោះអ្នកទោសមានចូលមានចេញរហូត ។ ដូច្នេះបញ្ហាហ្នឹងគឺវាអត់ចេះពេញទេ ។

**ស៖** លោកបានប្រាប់តុលាការថ្ងៃនេះ ហើយនិងពីម្សិលមិញថា គេបានថតរូបអ្នកទោសកាលណាអ្នកទោសនោះគេនាំចូលមក។ ហ្នឹងជាពេលតែមួយគត់ដែលគេថតតែពេលហ្នឹង ឬក៏ពេលណាផ្សេងពីហ្នឹងដែលគេអាចថតរូបអ្នកទោសបានដែរនោះ?

[១១:៣០:០៧]

**ឆ៖** ចំពោះថតរូបអ្នកទោស គឺគេថតតែចំពោះពេលហ្នឹង ឬជាការចាំបាច់ចំពោះអ្នកទោសដែលសំខាន់ ដែលគេយកមកមិនឲ្យដឹង ទើប ហ៊ិ គេបញ្ជាឲ្យអ្នកថត ទៅថតនៅតាមបន្ទប់ ។

**ស៖** ជាពិសេស ថាតើគេថតរូបអ្នកទោសដែរឬទេ ពេលអ្នកទោសនោះស្លាប់នោះ?

**ឆ៖** សូមបញ្ជាក់សំណួរម្តងទៀត ចំពោះអ្នកទោសស្លាប់ដោយសារឈឺ ឬក៏អ្នកទោសស្លាប់ដោយសារកម្មេច?

**ស៖** នៅពេលដែលអ្នកទោសណាស្លាប់ ទោះជាស្លាប់ដោយសារអ្វីក៏ដោយ ថាតើគេថតសាកសពនោះដែរឬទេ?

**ឆ៖** ចំពោះអ្នកទោសដែលស្លាប់ គឺខ្ញុំសូមបញ្ជាក់សាជាថ្មីថា ខ្ញុំមិនបានដឹងពិតប្រាកដ គេថត ឬមិនថតទេ ប៉ុន្តែ ខ្ញុំទទួលតែសេចក្តីរាយការណ៍តែចំពោះអ្នកទោសដែលស្លាប់ ជាឈ្មោះ ។

**លោក អានីស អះមេដ៖**

សូមអនុញ្ញាតពីលោកប្រធានដើម្បីឲ្យខាង AV ខាងសោតទស្សន៍បង្ហាញ P0005342 សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍បង្ហាញឯកសារនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ តាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក អានីស អះមេដ៖**

**ស៖** លោក សួស ធី តើលោកមើលរូបថតនេះ តើលោកចាំទេថា រូបទាំងនេះគេថតនៅ ស-២១ នោះ?

**ឆ៖** ចំពោះរូបថតនេះ គឺខ្ញុំមិនបានចាំទេ ទាក់ទងទៅលើជាងថតទេ ។

[១១:៣២:៣៩]

**ស៖** អ្នកថតរូបនោះ គឺធ្វើការនៅកន្លែងបន្ទប់ជាមួយលោក តើមែនឬទេ?

**ឆ៖** អ្នកថតរូបនោះ គឺគេថតនៅកន្លែងក្បែរគ្នានឹងដែរ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា ចំពោះការថតនេះ គឺខ្ញុំមិនបានដឹងពិតប្រាកដទេ ពីព្រោះមិនមែនថតនៅកន្លែងបន្ទប់ខ្ញុំទេ ឬក៏កន្លែងជាងថតទេ ។

**លោក អានីស អះមេដ៖**

សូមការអនុញ្ញាតពីលោកប្រធាន សូមអនុញ្ញាតសួរទៅជនជាប់ចោទ ថាតើគាត់ស្គាល់រូបថតទាំងនេះទេ? ហើយថាតើរូបថតហ្នឹងគេថតនៅស-២១ មែន ឬក៏មិនមែន?

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតឲ្យជនជាប់ចោទ អាចឆ្លើយនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាដែលបានសួរនេះ ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! រូបថតមនុស្សដែលក្រោយស្លាប់ ទោះបីស្លាប់ប្រភេទណាក៏ដោយ ខ្ញុំទទួលតែរូបថតណាដែលជាកម្មាភិបាលសំខាន់ ដែលមានបញ្ជាពីខាងលើឲ្យថត ហើយឲ្យខ្ញុំប្រគល់ទៅឲ្យគេ ដូចជា រូបថត វន វ៉េត, រូបថត ឆាយ គឹមហ៊ា ហើយនិងរូបថត លី ផែល ហៅ ផែន គាស់យកពីផ្នូរមក យកមកថតបីថ្ងៃក្រោយស្លាប់ ហើយនិងអ្នកផ្សេងទៀតខ្ញុំមិនចាំឈ្មោះទេ តែរូបថតប្រភេទនេះខ្ញុំអត់ដែលឃើញទេ ។

**លោក អានីស អះមេដ៖**

តើលោកអាចស្គាល់រូបថតណាមួយទេ ថាតើរូបថតណាមួយអាចជារូបថតនៃកម្មាភិបាលដែលសំខាន់នោះ បើសិនជាអាចធ្វើបាន?

**ជនជាប់ចោទ៖**

កម្មាភិបាលដែលសំខាន់ ដូចខ្ញុំរាប់អ៊ីចឹង ខ្ញុំស្គាល់ឈ្មោះ ខ្ញុំស្គាល់មុខ ក្នុងចំណោមរូបថតទាំងអស់នេះអត់មានមុខកម្មាភិបាលសំខាន់ដែលខ្ញុំទទួលបញ្ជាមក ហើយខ្ញុំប្រើឲ្យគេថតតាមបញ្ជានោះទេ អត់មានទេ ។

**សួរដោយលោក អានីស អះុមេដ៖**

**ស៖** ខ្ញុំក៏សូមបង្វែរសំណួររបស់ខ្ញុំមកសាក្សី លោក សួស ធី លោកបានប្រាប់អ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតថាអ្នកទោសនៅស-២១ មកពីភូមិភាគតំបន់ផ្សេងៗទូទាំងប្រទេស ហើយព្រឹកមិញនេះលោកក៏បាននិយាយថា គេមកពីតំបន់ ហើយនិងអង្គភាពនានា តើលោកអាចបញ្ជាក់ថាហ្នឹងពិតដែរទេជូនតុលាការនោះ?

[១១:៣៥:៥៣]

**ឆ៖** ពិតប្រាកដមែនហើយ គឺអ្នកទោសមកពីគ្រប់តំបន់ ភូមិភាគ គ្រប់មន្ទីរក្រសួង គ្រប់អង្គភាព ។

**ស៖** លោកក៏បានជម្រាបអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតថា សុន សេន បានមកវត្តមានក្នុងកិច្ចប្រជុំមួយនៅស-២១ ហើយគេបានណែនាំថា គាត់ជាមេបញ្ជាការកងទ័ព ។ តើលោកអាចបញ្ជាក់បានទេព័ត៌មាននេះ?

**ឆ៖** ចំពោះព័ត៌មាននេះ គឺខ្ញុំកាលហ្នឹងវាមិនចាប់អារម្មណ៍អ្នកណាអ្នកណីទេ ប៉ុន្តែចំពោះ សុន សេន ដែលមកនៅក្នុងមន្ទីរស-២១ គឺមិនមែនមកនៅក្នុងគុកនេះទេ គឺគេមកមានតែផ្នែកទៅរៀនខាងនយោបាយនៅសាលាខាងក្រៅជិតផ្ទះ ឌុច នោះទេ ។

**ស៖** តើនៅក្នុងការប្រជុំនោះគេធ្វើអ្វីខ្លះ? តើជនជាប់ចោទបាននៅកន្លែងអង្គប្រជុំនោះឬទេ?

**ឆ៖** នេះមិនមែនជាប្រជុំទេ គឺជាការរៀនសូត្រជាទូទៅទាំងអស់ក្នុងមន្ទីរស-២១ ធម្មតាតែអ្នកធំមកហើយ គឺជនជាប់ចោទត្រូវតែមក ។

**ស៖** លោកក៏បានជម្រាបសហចៅក្រមស៊ើបអង្កេតថា កុមារៗត្រូវបានគេបំបែកចេញពីឪពុកម្តាយ ហើយគេបញ្ជូនយកទៅសម្លាប់ក្នុងរយៈពេលពីរថ្ងៃក្រោយពីនោះ តើលោកនៅបញ្ជាក់ថាការហ្នឹងពិតដែរឬទេ?

**ឆ៖** ចំពោះកុមារៗដែលបញ្ជូនមកស-២១ គឺរយៈពេល គឺវាមិនទៀងទេ អានេះអាស្រ័យទៅលើ ហ៊ី ជាអ្នកបញ្ជា ប៉េង ជាអ្នកដកចេញ ហើយការងារដកចេញនេះ គឺខ្ញុំមិនបានជាដឹងពិតប្រាកដទេ ពីព្រោះវាខុសការងាររបស់ខ្ញុំ ។

**ស៖** លោកបានជម្រាបតុលាការព្រឹកមិញនេះថា អ្នកទោសសំខាន់ៗត្រូវបានគេបញ្ជូនផ្ទាល់ទៅគុកពិសេស តើលោកអាចបញ្ជាក់ទៀតទេថា ប្រវត្តិរូបរបស់គេមិនត្រូវបានកត់ត្រាយក ហើយគេមិនថតរូបអ្នកទោសសំខាន់នោះទេ?

[១១:៣៨:៥៤]

**ឆ៖** ចំពោះអ្នកទោសសំខាន់ៗ ចំពោះប្រវត្តិរូប ខ្ញុំដូចអត់បានធ្វើទេ គឺធ្វើតែបញ្ជីដែល ហ៊ី គេឱ្យយកមក គឺតែដាក់ឈ្មោះអី ដើម្បីឱ្យដឹងចំនួន ឈ្មោះ តួនាទី និងយកមកពីណា ហើយបើអ្នកទោសខ្លះទៀតដែលសំខាន់ៗពីលើកមុនគឺអត់បានធ្វើបញ្ជីទេ គឺខ្ញុំមិនបានដឹង ។ ប៉ុន្តែ វាមានភាគតិចដូចអ្នកទោសធំៗ គឺគេមិនប្រាប់យើងទេ ពីព្រោះគេធ្វើបញ្ជីខ្លួនគេហើយ ។

**ស៖** លោកបានជម្រាបទៅតុលាការ ហើយលោកប្រធាន នេះជាសំណួរចុងក្រោយរបស់ខ្ញុំ ។ លោកជម្រាបតុលាការថា លោកមានការទាក់ទងជិតស្និទ្ធជាមួយក្រុមអ្នកសួរចម្លើយ តើលោកប្រាប់តុលាការបានទេ តើក្នុងចន្លោះពេលនៃការសួរចម្លើយនីមួយៗនោះ ពេលណាចប់ហើយ កាលណាចប់ការសួរចម្លើយហើយ តើគេទុករយៈពេលប៉ុន្មានបានគេបញ្ជូនទៅជើងឯកដើម្បីកម្ទេចនោះ?

**ឆ៖** ចំពោះខ្ញុំជាមួយកងសួរចម្លើយ និយាយឲ្យខ្លី គឺពុំមានការជិតដិតទេ គឺគ្រាន់តែ ដើម្បីឲ្យងាយស្តាប់ គឺគេគ្រាន់តែមកយកឈ្មោះអ្នកទោស ឲ្យដឹងនៅអគារណា១ ហើយគេម្ចាស់ការខ្លួនគេ គឺគេយកទៅ ចំពោះសួរចម្លើយនៅពេលណាចប់មិនចប់ គឺខ្ញុំក៏អត់បានដឹងដែរ គឺភារកិច្ចវាខុសគ្នា ហើយការជិតដិតស្និទ្ធជាមួយកងសួរចម្លើយ គឺខ្ញុំគ្មានមានភារកិច្ចជិតដិតទេ គ្រាន់តែមានការប្រចាំការដើម្បីឲ្យដឹងអ្នកទោសនៅកន្លែងណា១តែប៉ុណ្ណឹងទេ ហើយការដែលគេយកបញ្ជីហ្នឹង គឺគេយកតែឈ្មោះ ហើយនិងមកពីក្រសួង គឺគេស្រណុកខ្ញុំឲ្យដឹង លេខផ្ទះ លេខបន្ទប់ តែប៉ុណ្ណឹងទេ ។

**ស៖** លោកក៏បានប្រាប់តុលាការដែរថា ពួកឈ្លើយសឹកវៀតណាមក៏ត្រូវគេបញ្ជូនមក ស-២១ ដែរ។ តើលោកគិតថា តើគេនាំអ្នកឈ្លើយសឹកហ្នឹងមកពេលណា? ថាតើចំនួនសរុបហ្នឹងប្រហែលប៉ុន្មានពេលនោះ?

**ឆ៖** ដូចខ្ញុំបានបញ្ជាក់លើកមុនអ៊ីចឹង ចំពោះឈ្លើយសឹកវៀតណាម ការមកគឺវាមិនទៀង ដូចខ្ញុំបញ្ជាក់អ៊ីចឹង មិនចាប់អារម្មណ៍ថា អ្នកទោសជាទូទៅ គឺឲ្យតែមកគឹកត់ហើយ អ្នកទោសវៀតណាមអ៊ីចឹងក៏ដែរ ឲ្យតែមកថ្មើរម៉ានក៏ខ្ញុំកត់ដែរ ហើយចំពោះចំនួនដូចខ្ញុំបានបញ្ជាក់ហើយ អ៊ីចឹងគឺថាខ្ញុំក្តាប់មិនបានជាពិតប្រាកដទេ ពីព្រោះបញ្ហាអស់នេះដូចខ្ញុំបញ្ជាក់ហើយ បញ្ជាក់ទៀតថា ការងារម្នាក់ឯង ។ ដូច្នេះ ការសរុប ការដឹងចំនួនអី គឺធ្វើយ៉ាងម៉េច របាយការណ៍ប្រចាំថ្ងៃ គឺឲ្យបានទាន់ពេលវេលាតែប៉ុណ្ណឹងឯង ។

**ស៖** ដូច្នេះ អ្នកទោសដែលជាឈ្លើយសឹកវៀតណាមខ្លះអាចមកក្នុងឆ្នាំ១៩៧៦, ១៩៧៧ ឬក៏ ១៧៨ *(ស៊ីក)* មួយចំនួនខ្លះ១នោះ តើអ៊ីចឹងមែនឬទេ?

[១១:៤២:២៦]

**ឆ៖** ចំពោះអ្នកទោសឈ្លើយសឹកវៀតណាម គឺ ៧៦, ៧៧ អី គឺអត់មានទេ គឺនៅពេលដែលសង្គ្រាមផ្ទុះខ្លាំងជាមួយគេបានទើបមាន ។

**លោក អានីស អះមេដ៖**

លោកប្រធានខ្ញុំអស់សំណួរហើយ ។ ប៉ុន្តែ ដើម្បីកត់ត្រាត្រឹមត្រូវហ្នឹង គឺថាចម្លើយទាំងអស់ដែលសាក្សីបានផ្តល់ទៅឲ្យសហចៅក្រមស៊ើបអង្កេត ហើយនិងសហព្រះរាជអាជ្ញា អាចនឹងត្រូវបានអានបញ្ជាក់នៅក្នុងសវនាការ ដើម្បីបំពេញបន្ថែមព័ត៌មានទាំងស្រុង ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ ប្រគល់វេទិកាទៅមេធាវីអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។ សូមអញ្ជើញមេធាវីអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលមានឱកាសនៅក្នុងមួយក្រុម១៥នាទី ។

**សួរដោយលោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំបាទក៏សូមគោរពលោកប្រធាន លោកស្រី លោកចៅក្រមអង្គជំនុំជម្រះជាទីគោរព ។ សូមជម្រាបសួរលោក សួស ធី ខ្ញុំឈ្មោះ ហុង គឹមសួន ជាមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្រុមទីបួន សូមសួរសំណួរខ្លះដល់លោក បន្ទាប់ពីសំណួររបស់លោកប្រធាន និងសហព្រះរាជអាជ្ញា ។

**ស៖** សំណួរជាដំបូងសួរទៅលោកអំពី បញ្ជាក់ឡើងវិញបន្តិចថា លោកបានមានប្រសាសន៍អំពីនៅថ្ងៃចុងក្រោយនៃការបែកទីក្រុងភ្នំពេញ គឺមុនថ្ងៃ៧ មករា ១៩៧៩ លោកបានជម្រាបអង្គសវនាការអម្បាញ់មិញថា មាននៅសល់ពួកអ្នកទោសនៅតាមគុកពិសេស និងសល់អ្នកទោសខាងក្រៅ ។ អ៊ីចឹងសំណួរខ្ញុំសួរពីរចំណុចនេះ ថាតើពាក្យថា សល់អ្នកទោសនៅតាមគុកពិសេសនោះ លោកដឹងដោយរបៀបណា? និងសល់អ្នកទោសនៅខាងក្រៅនោះលោកបានដឹងដោយរបៀបណា?

**ឆ៖** ខ្ញុំសូមបញ្ជាក់ ចំពោះសល់អ្នកទោសដែលនៅខាងក្រៅ គឺចំពោះអ្នកទោសដែលសល់ខាងក្រៅ គឺអត់មានយកចេញទៅណាទេ គឺខ្ញុំដឹងដោយសារអត់មានធ្វើបញ្ជី គឺនៅសល់ទាំងអស់ហើយ ។ ហើយចំពោះអ្នកទោសដែលនៅសល់ក្នុងគុកពិសេសនេះ ពីព្រោះបានថា ខ្ញុំសល់ នៅសល់ហ្នឹងពីព្រោះក្នុងបញ្ជីដែលយកចេញនោះគឺ បោសសម្អាតតែអ្នកទោសដែលនៅក្នុងគុកទាំងអស់ លើកលែងតែគុកពិសេស ។

**ស៖** អ៊ីចឹងមានន័យថា ក្រៅពីបញ្ជីដែលយកទៅសម្លាប់ចោល គឺមាននៅសល់ លោកសន្និដ្ឋានថា គឺអ្នកនោះនៅសល់ ឬនៅរស់អ៊ីចឹងមែនទេ?

**ឆ៖** ពិតប្រាកដមែន ។

**ស៖** សូមអរគុណ ។ នៅក្នុងកំណត់ហេតុយកចម្លើយរបស់សហចៅក្រមស៊ើបអង្កេត លោកបានបញ្ជាក់ថា នៅក្នុងបញ្ជីបុគ្គលិកនៃមន្ទីរស-២១ ឬដែលសព្វថ្ងៃគេហៅជាទូទៅថា គុកទួលស្លែងនោះចែកចេញជាបីក្រុមធំៗ មានមន្ទីរស-២១ , ស-២១(ក) , ស-២១(ខ) និងស-២១(គ) ។ ដែលមានស-

២១(ក) សម្រាប់កងសួរចម្លើយ ក្រោមការត្រួតត្រារបស់ ឌុច ។ មន្ទីរស-២១(ខ) សម្រាប់កងសន្តិសុខ ក្រោមការត្រួតត្រារបស់ ហ៊ឹម ហ៊ុយ និង ស-២១(គ) សម្រាប់ធ្វើស្រែនៅព្រៃស ក្រោមការត្រួតត្រារបស់ ហ៊ុយ ស្រែ ។ អ៊ីចឹងកន្លែងនេះ អំមិញលោកចៅក្រម លោកប្រធាន លោកបានសួរហើយ ប៉ុន្តែខ្ញុំគ្រាន់តែបញ្ជាក់ថា ការដែលលោកដឹងពីក្រុមធំៗទាំងបីនោះ តើបញ្ជីទាំងអស់នោះក្រុមធំៗផ្សេងៗគេប្រគល់មកឲ្យលោកសរុបចំនួនដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ចំពោះក្រុមធំៗទាំងបីហ្នឹង គឺបញ្ជី គឺខ្ញុំមិនបានសរុបទេ ចំពោះក្រុមទាំងបីហ្នឹង គឺយើងខ្ញុំផ្នែកខាងការពារ គឺទៅរាយការណ៍ទៅឲ្យខាងផ្នែកមន្ទីរខាងកងសួរចម្លើយគឺ ម៉េង ជាអ្នកសរុបទាំងអស់ ។

**ស៖** សូមអរគុណ ។ អ៊ីចឹងការបែងចែកជាដប់ប្រាំបីក្រុម នៃក្រុមទាំងបីធំៗឲ្យទៅជាដប់ប្រាំបីក្រុមនោះ តើលោកបានដឹង ឬក៏លោកកាន់បញ្ជីចំនួននោះផងដែរទេ?

[១១:៤៨:០៥]

**ឆ៖** ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង គឺថាចំពោះបញ្ជីកម្មាភិបាលយុទ្ធជនពីមុនមានច្រើន មិនមែនត្រឹមតែដប់ប្រាំបីក្រុមទេ។ ប៉ុន្តែ ដល់ក្រោយមកចាប់អស់នៅសល់ អានេះខ្ញុំសន្និដ្ឋានប្រហែលជានៅដប់ប្រាំបីក្រុម គឺមិនមែនដប់ប្រាំបីក្រុមហ្នឹង គឺមិនមែនជាបុគ្គលិករបស់មន្ទីរស-២១ ទាំងអស់ទេ គឺនិយាយដោយឡែក គឺខាងផ្នែកកងការពារ គឺមានដប់ប្រាំបីក្រុម ។

**ស៖** សូមអរគុណ ។ សូមសួរបន្តទៅទៀត លោកបានជម្រាបជូនអង្គសវនាការ ខ្ញុំសូមបញ្ជាក់បន្តិចថា នៅពេលដែលដឹកក្រុមអ្នកយកទៅ អ្នកទោសទៅសម្លាប់នោះ គឺលោកត្រូវបានត្រួតពិនិត្យមើលបញ្ជីឈ្មោះ ។ ហើយជាសំណួររបស់ខ្ញុំឲ្យច្បាស់ឡើងវិញ លោកប្រធានលោកសួរអំពីថា ការរាប់ឈ្មោះ ឬពិនិត្យឈ្មោះ ដែលមនុស្សច្រើនៗយកទៅសម្លាប់នោះ តើលោកពិនិត្យបញ្ជាក់ដូចម្តេច? ដូច្នេះសំណួរដែលខ្ញុំសូមបញ្ជាក់ឡើងវិញថា លោកអះអាងថា អ្នកដែលទោសយកទៅសម្លាប់នោះ ច្រើនតែស្គមៗ មិនមាននរណាមួយថា និយាយមិនបានទេ គឺគ្រាន់តែនិយាយអំពីឈ្មោះបាន អ៊ីចឹងតើការត្រួតពិនិត្យសម្គាល់ជាមួយនឹងឈ្មោះ តើបានប្រៀបធៀបជាមួយនឹងរូបថត ដែលកាលថត ហើយនិងពេលយកចេញនេះដែរឬទេ មុននឹងយកទៅសម្លាប់?

**ឆ៖** គឺថា សូមបញ្ជាក់សំណួរសាជាថ្មី ខ្ញុំស្តាប់សំណួរនេះគឺមិនទាន់បានច្បាស់លាស់ ។

**ស៖** សូមអរគុណ ។ អ៊ីចឹង ខ្ញុំសួរឲ្យខ្លីបន្តិច ។ ក្នុងនាមលោកជាអ្នកត្រួតពិនិត្យលើបញ្ជីឈ្មោះអ្នកទោសដែលត្រូវយកទៅសម្លាប់ អ៊ីចឹងអ្នកទោសទាំងអស់ដែលចូលមកក្នុងមន្ទីរស-២១ នៃបរិវេណពីដើមហៅថា “វិទ្យាល័យពញាយ៉ាត”នេះណ៎ា ឬសព្វថ្ងៃហៅថា “គុកទួលស្លែង”នេះ គឺត្រូវតែកត់ឈ្មោះមានបញ្ជីឈ្មោះ មានថតរូបទុកជាមុន ហើយមុននឹងយកទៅសម្លាប់ចោល លោកថាបានត្រួតពិនិត្យទោះច្រើនក៏ដោយ ក៏ត្រួតពិនិត្យប្រហែលតែមួយម៉ោងទេ ។ អ៊ីចឹង សំណួរសួរថា រូបថតកាលចូលមកជាមួយនឹងពេលយកចេញនេះវាស្គម លោកថា អ្នកហ្នឹងអាចនិយាយបានត្រឹមឈ្មោះដែរ តើការត្រួតពិនិត្យមើលតើវាដូចគ្នា តែមួយម៉ោងហ្នឹង តើវាមានការច្រឡំ វាផ្ទៀងផ្ទាត់គ្នាយ៉ាងម៉េច កន្លែងហ្នឹងសូមពន្យល់បន្តិច?

**ឆ៖** ខ្ញុំសូមបញ្ជាក់ ចំពោះការផ្ទៀងផ្ទាត់ចំពោះអ្នកទោសដែលថតរូបពេលចូលមកដល់ ហើយចំពោះអ្នកទោសដែលចេញ ការផ្ទៀងផ្ទាត់យ៉ាងម៉េច វាខុសគ្នាយ៉ាងម៉េច ។ ចំពោះការពិតជាក់ស្ដែងយើងមិនមែនផ្ទៀងផ្ទាត់ជារូបភាពប៉ុន្មានទេ គឺយើងផ្ទៀងផ្ទាត់ចំពោះតែឈ្មោះពិតប្រាកដ និងតួនាទីតែប៉ុណ្ណឹង គឺឬមកពីអង្គភាពណា គឺវាអាចច្បាស់ហើយ ខ្ញុំសូមបញ្ជាក់តែប៉ុណ្ណឹង ។

[១១:៥១:៥០]

**ស៖** សូមអរគុណ ។ នៅក្នុងចម្លើយរបស់លោកដោយសហចៅក្រមស៊ើបអង្កេតផងដែរ ទាក់ទងអំពីអ្នកទោសឈឺធ្ងន់រហូតដល់ស្លាប់ និងអ្នកត្រូវបានសួរធ្វើទារុណកម្មរហូតដល់ស្លាប់ តើពាក្យនេះលោកនៅទទួលស្គាល់អ៊ីចឹងដែរទេ?

**ឆ៖** ពាក្យនេះ គឺខ្ញុំនៅទទួលស្គាល់ដដែល ។

**ស៖** សូមអរគុណ ។ កំណត់ហេតុយកចម្លើយដដែល លោកបានធ្វើការជាអ្នកកត់បញ្ជីឈ្មោះអ្នកទោសតាំងពីនៅជាមួយ ណាត ដែលជាប្រធាននៅមន្ទីរសន្តិសុខជិតផ្សារថ្មី ។ ហើយមានចម្លើយរបស់លោកថា មានអ្នកទោសត្រូវបានដោះលែង តើន័យនេះ តើពាក្យនេះលោកមានការដូរផ្លាស់ដែរឬទេ?

**ឆ៖** ចាប់តាំងពីខ្ញុំនៅមន្ទីរស-២១ ជាមួយ ណាត មន្ទីរស-២១ គុកទួលស្លែងនេះ ក៏ដូចជានៅមន្ទីររបស់ ណាត គឺខ្ញុំមិនដែលបញ្ជាក់អំពី មិនទាន់ដែលបញ្ជាក់អំពីការដោះលែងអ្នកទោសទេ គ្រាន់តែថា អ្នកទោសសម័យ ណាត កាន់កាប់ គឺជំនាន់ ណាត កាន់កាប់គឺមិនទាន់មានការដកចេញយកទៅកម្ទេច ។

**ស៖** ខ្ញុំសូមបញ្ជាក់ពីលេខ ERN បន្តិច ពាក្យសម្តីរបស់លោកដែលស្រង់ចូលមកក្នុងឯកសារ E21.1 ស្តីពីការវិភាគសម្តីសាក្សីរស់សម្រាប់សវនាការនៅក្នុង ERN00288997 នៅក្នុងចំណុចលេខ ២០ ឬយើងនិយាយថា អង្គហេតុតូចៗនៃវគ្គរបស់សាក្សីឈ្មោះ សួស ធី លេខ២០ ។ អ៊ីចឹង នេះជាសម្តីដែលខ្ញុំដកស្រង់ពីឯកសារនេះតែប៉ុណ្ណោះ ។ សំណួរខ្ញុំសួរបន្ថែមទៀត សម្តីរបស់លោកដដែលនៅក្នុងឯកសារដែល ដែលការកត់ត្រាមកថា អ្នកទោសសំខាន់ដែលធ្លាក់ខ្លួនឈឺ ត្រូវធ្វើទៅ ឌុច តែម្តង ។ អ៊ីចឹងតើសម្តីនេះ ឬក៏ពាក្យពេចន៍ដែលលោកនិយាយនេះអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ចំពោះរឿងនេះ ចំពោះអ្នកទោសសំខាន់ដែលឈឺ គឺ ឌុច គេបញ្ជាមកឲ្យ ហ៊ី ហើយដើម្បីឲ្យពេទ្យមើល មនុស្សច្រើនដែលសំខាន់ៗ ។

**ស៖** សូមអរគុណ ។ សំណួរខ្ញុំសួរបន្ថែមទៀត ទាក់ទងជាមួយនឹងកម្មាភិបាលនៅក្នុងមន្ទីរ ស-២១ លោកនៅចាំបានទេចម្លើយរបស់លោកនៅក្នុង ERN អម្បាញ់មិញដដែល ចំនួនមិនតិចជាងមួយរយនាក់ទេដែលត្រូវបានចាប់យកទៅសម្លាប់ចោល តើបញ្ជីឈ្មោះនៃកម្មាភិបាលទាំងអស់នោះ លោកជាអ្នកកាន់កាប់ និងទទួលស្គាល់ដដែលឬទេ?

**ឆ៖** ចំពោះបញ្ជីបុគ្គលិកមន្ទីរស-២១ គឺខ្ញុំបានធ្វើ គឺខ្ញុំនៅតែទទួលស្គាល់ដដែល ។

**ស៖** ជាសំណួរចុងក្រោយ សួរទាក់ទងជាមួយនឹងការធ្វើការទារុណកម្មដល់ស្លាប់ តើលោកនៅចងចាំទេថា ចំពោះអ្នកដែលត្រូវបានយកទៅសួរចម្លើយ និងធ្វើទារុណកម្មរហូតដល់ស្លាប់ ប្រហែលជាប៉ុន្មាននាក់ដែរ?

**ឆ៖** បញ្ហាចំពោះអ្នកទោសដែលធ្វើទារុណកម្មដល់ស្លាប់ ចំពោះខ្ញុំ គឺអត់បានដឹងពិតប្រាកដទេ។ ហើយចំពោះអ្នកទោសដែលស្លាប់នៅក្នុងអគារ គឺពេទ្យគេរាយការណ៍មកឲ្យ ហ៊ី គេដាក់សុទ្ធតែអ្នកទោសឈឺទាំងអស់ ។ ដូច្នេះ ការស្លាប់នៅក្នុងអគារ គឺមិនបញ្ជាក់ថា ដោយធ្វើទារុណកម្ម ឬដោយស្លាប់ ដោយជំងឺ ឬអីទេ គឺតែស្លាប់ក្នុងអគារ គឺខ្ញុំរាយការណ៍ថា ដាក់ជាអ្នកជំងឺឈឺស្លាប់ ។

**លោក ហុង គឹមសួន៖**

សូមអរគុណ ។ ខ្ញុំសូមបញ្ជាក់លេខ ERN ដដែល នូវសម្តី ឬក៏នូវពាក្យដែលខ្ញុំបាទបាន សួរអម្បាញ់មិញ គឺនៅក្នុង ERN លេខ 00288997 នៅក្នុងកថាខណ្ឌលេខ១៩ ដដែល ។ សូមអរគុណលោក សួស ធី ដែលខ្ញុំបាន លោកបានបង្ហាញបំភ្លឺអំពីសំណួររបស់ខ្ញុំ ។ សូមអរគុណ លោកចៅក្រម ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**លោក តាន់ សេណារ៉ុង៖**

តំណាងសហព្រះរាជអាជ្ញាជាតិមានសំណូមពរមួយជូនលោកប្រធានអង្គជំនុំជម្រះ កាលពីម្សិលមិញលោកប្រធានអង្គជំនុំជម្រះបានបង្ហាញរូបភាព ដែលមានលេខ ERN00189137 ដែលបង្ហាញពីទីតាំងដែលលោក សួស ធី ហ្នឹង បានសួរចម្លើយនៅក្នុងចន្លោះអគារ “E” និងអគារខាងមុខ ។ ក្នុងនេះតំណាងសហព្រះរាជអាជ្ញាសុំឲ្យ សុំការអនុញ្ញាតពីលោកប្រធានដើម្បីឲ្យលោក សួស ធី គាត់ធ្វើកំណត់សម្គាល់នៅក្នុងនេះ ហើយផ្តិតមេដៃ ឬចុះហត្ថលេខាដើម្បីដាក់ទុកបញ្ចូលក្នុងសំណុំរឿង ។

បញ្ហាមួយទៀត នៅពេលដែលខ្ញុំបានសាកសួរលោក សួស ធី អម្បាញ់មិញ លោក សួស ធី គាត់បានបញ្ជាក់ថា ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំងឈ្មោះ ភឹង តុន ដែលមានលេខ ERN188857 ហ្នឹង ក៏គាត់ជាអ្នកបានធ្វើដែរ ហើយតំណាងសហព្រះរាជអាជ្ញាសុំឲ្យគាត់ហ្នឹងធ្វើការចុះហត្ថលេខាដើម្បីបញ្ជាក់ទុកនៅលើប្រវត្តិរូបនេះ ថាគាត់ជាអ្នកបានធ្វើបញ្ជីចូលនូវអ្នកទោសរូបនេះ ។

ហើយទីបី បញ្ជីអ្នកទោសចូលថ្ងៃទី១២ ខែ១២ ឆ្នាំ១៩៧៦ ក៏គាត់បានបញ្ជាក់ដែរ ដែលមានលេខ ERN លេខ 00188853 ហ្នឹង គាត់ក៏បានបញ្ជាក់ថា គាត់ហ្នឹងបានជាអ្នកធ្វើបញ្ជីនេះ ហើយសុំឲ្យគាត់ហ្នឹងចុះហត្ថលេខា ដើម្បីបញ្ជាក់ថាឯកសារទាំងបីនេះ គឺគាត់បានធ្វើដោយផ្ទាល់ដៃរបស់គាត់ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ស្តាប់សំណូមពររបស់តំណាងសហព្រះរាជអាជ្ញាជាតិមានចំណុចទីមួយជាការសមរម្យ ដែលត្រូវធ្វើ គប្បីធ្វើដូច្នេះ ហើយក្រឡាបញ្ជីសូមរៀបចំការងារដូចលើកមុនអ៊ីចឹង ដើម្បីកំណត់សម្គាល់លើចំណុចនៃទីតាំង ដែលលោក សួស ធី ធ្វើការងារនៅក្នុងអគារ “E” ហើយផ្នែកខាងមុខ ។ ដោយឡែកឯកសារផ្សេងទៀត គឺបានបញ្ជាក់ច្បាស់លាស់នៅក្នុងប្រតិចារឹករួចហើយ ក្នុងការបង្ហាញលេខ ERN និងបង្ហាញអំពីសាវតារជាតិ អ៊ីចឹងមិនចាំបាច់ធ្វើលក្ខណៈពិសេសឯណានោះទេ ពីព្រោះវាមានទម្រង់ទូទៅដែលធ្វើការកត់ត្រាជាក់លាក់នៅក្នុងប្រតិចារឹកហើយ បញ្ហាដែលពិសេសដោយឡែកនោះ គឺការប្តូរទីតាំងទេ ដែលមានលក្ខណៈចង្អុលបង្ហាញ ហើយវាមានការលំបាកនៅក្នុងការកំណត់ ប្រសិនបើ

យើងមិនធ្វើការដៅនូវចំណុចជាក់លាក់ដែលសាក្សីបានចង្អុលនោះទេ ។ ដូច្នេះ ធ្វើតែប្ដូរទីតាំងនៃការិយាល័យ ឬក៏ទីកន្លែងដែលសាក្សីរូបនេះធ្វើការជាការត្រឹមត្រូវហើយ ជាការសមរម្យ ។

ឥឡូវនេះ ដល់ម៉ោងត្រូវពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះមុននឹងប្រកាសផ្អាកហ្នឹង គឺទីមួយសូមអរគុណលោក សួស ធី ដែលបានអញ្ជើញចូលរួម ហើយផ្ដល់សក្ខីកម្ម ។ ប៉ុន្តែ អង្គជំនុំជម្រះសូមជម្រាបថា ដំណើរការសវនាការដេញដោលចំពោះលោកអំពីអង្គហេតុ ពាក់ព័ន្ធនឹងការចោទប្រកាន់បន្ទុកលើជនជាប់ចោទ មិនទាន់ចប់សព្វគ្រប់ទេ ទើបតែបានអង្គជំនុំជម្រះភាគី តំណាងសហព្រះរាជអាជ្ញា ហើយនិងមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបួន ។ នៅពីរក្រុម នៅបីក្រុមទៀត មេធាវីអ្នកតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី និងភាគី មេធាវីការពារក្ដី ។

ដូច្នេះ គឺអង្គជំនុំជម្រះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅរសៀលនេះ ចាប់ពីម៉ោងមួយសាមសិបនាទី ហើយអង្គជំនុំជម្រះប្រកាសសម្រាកត្រឹមនេះ ដើម្បីពិសាអាហារថ្ងៃត្រង់ ហើយអង្គជំនុំជម្រះលើកបន្តទៅរសៀលនេះចាប់ពីម៉ោងមួយសាមសិបនាទី ។ មន្ត្រីតុលាការសម្របសម្រួលដល់សាក្សីរូបនេះដើម្បីបានកន្លែងសម្រាកសមរម្យ ហើយនិងឲ្យនាំគាត់មកកាន់សាលសវនាការមុនម៉ោងមួយសាមសិបនាទីរសៀលនេះ ។ អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំជនជាប់ចោទមកកាន់សាលសវនាការនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១២:០២នាទី ដល់ម៉ោង ១៣:៣៣នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្ដាប់សក្ខីកម្មសាក្សីឈ្មោះ សួស ធី ហើយជាបន្តនេះ សូមប្រគល់វេទិកាទៅមេធាវីអ្នកតំណាងឲ្យមេធាវីរដ្ឋប្បវេណីក្រុមបី ប្រសិនបើមានសំណួរត្រូវសួរដល់សាក្សីរូបនេះ សូមអញ្ជើញ ។

**លោក គឹម ម៉េងឃី៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម ។ ជម្រាមសួរលោក សួស ធី ។ ខ្ញុំបាទមេធាវី គឹម ម៉េងឃី តំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី មានសំណួរសួរទៅកាន់លោកជាក់លាក់ អំពីជនរងគ្រោះដែលត្រូវបានគេសម្លាប់នៅមន្ទីរស-២១ នោះ ។

ជាបឋម ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ឲ្យបញ្ចាំងឯកសារដែលមានលេខ ERN00198659 ជាភាសាខ្មែរ ដែលឯកសារហ្នឹងស្ថិតនៅក្នុង D25/8/2 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងផ្នែកសោតទស្សន៍ ចាត់ការដាក់បញ្ចាំងនូវឯកសារដែលមានលេខ ERN និង លេខ D ដូចតាមសំណើសុំ របស់មេធាវីអ្នកតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ។

**សួរដោយលោក គីម ម៉េងឃី៖**

**ស៖** លោក សួស ធី, នៅក្នុងនេះគឺមានប្រវត្តិរូបរបស់អ្នកទោសជាប់ឃុំឃាំង ដែលមានឈ្មោះថា ជូឡុង វ៉ាំងស៊ី លោកស្រី ជូឡុង វ៉ាំងស៊ី ហ្នឹង គឺនៅក្នុងប្រវត្តិរូប គឺគាត់ជាបុគ្គលិកនៃវិទ្យុនិយាយជាភាសាបារាំង ហើយគាត់ជាបុត្ររបស់សម្ដេច ញ៉ឹក ជូឡុង ។ តើលោកស្គាល់ប្រវត្តិរូបរបស់អ្នកទោសនេះដែរឬទេ?

**ឆ៖** ចំពោះប្រវត្តិរូបអ្នកទោសនេះ ខ្ញុំចាំមិនច្បាស់ទេ ហើយអក្សរនេះក៏មិនមែនជាអក្សរខ្ញុំដែរ។

**លោក គីម ម៉េងឃី៖**

សូមអរគុណ ។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតឲ្យលោកប្រធាន បង្គាប់ទៅខាងសោតទស្សន៍ បញ្ចាំងនូវឯកសារមួយទៀតដែលមានលេខ ERN00088813 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍ ដាក់បង្ហាញនូវឯកសារលើអេក្រង់ទូរទស្សន៍នូវឯកសារលេខ ដូចមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី បានស្នើសុំ ។

**លោក គីម ម៉េងឃី៖**

**ស៖** លោក សួស ធី, នៅក្នុងនេះគឺជាប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំងដដែល ដែលមានឈ្មោះថា លឹម គឹមម៉ារី ហើយគាត់គឺជាស្វាមីរបស់លោកស្រី ជូឡុងំ វ៉ាំងស៊ី ដែលត្រូវចាប់មកពេលជាមួយគ្នា ហើយមុខងាររបស់គាត់គឺអគ្គនាយកនៃធនាគារខ្មែរសម្រាប់ពាណិជ្ជកម្ម ។ តើលោកស្គាល់រូបនេះទេ? ហើយតើអាចចងចាំបានទេថាអំពីអ្នកទោសនេះ ដែលជាប់ឃុំឃាំងឈ្មោះនេះដែរទេ?

**ឆ៖** ដូចខ្ញុំបានបញ្ជាក់អ៊ីចឹងគឺចំពោះឈ្មោះនិងរូប ចំពោះអ្នកទោសជាទូទៅទាំងអស់គឺ ខ្ញុំមិនអាចចាំបានទាំងអស់ទេ ។

**លោក គឹម ម៉េងឃី៖**

សូមអរគុណ ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធាន បញ្ចាំងនូវឯកសារបន្តទៀត គឺមានលេខ 00281254 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ បញ្ចាំងនូវឯកសារនៅលើអេក្រង់ទូរទស្សន៍ តាមសំណើសុំរបស់មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ។

**សួរដោយលោក គឹម ម៉េងឃី៖**

**ស៖** លោក ស្ងួស ធី, រូបនេះគឺគាត់ក៏ជាជនរងគ្រោះនៅមន្ទីរស-២១ ដែរ ក៏ប៉ុន្តែរូបនេះមិនមែនដកស្រង់ពីមន្ទីរស-២១ ទេ គាត់មានឈ្មោះថា អ៊ុក កេត ហើយគាត់បម្រើការនៅក្រសួងការបរទេសឋានៈជាលេខាទី៣នៃក្រសួងការបរទេស ។ សំណួរសួរថា តើលោកធ្លាប់ឃើញបុគ្គលដែលមានភិនភាគបែបហ្នឹងដែរឬទេ? ហើយអាចសម្គាល់ឈ្មោះ ឬក៏ចំណាំឈ្មោះនេះបានដែរឬទេ? គឺឈ្មោះ អ៊ុក កេត ។

[១៣:៤១:០២]

**ឆ៖** ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង គឺថាចំពោះអ្នកទោសមក គឺខ្ញុំមិនអាចចំណាំបានទេ ពីព្រោះការធ្វើការនោះគឺវាម្នាក់ឯង ហើយអត់មានចាប់អារម្មណ៍រឿងអ្នកទោសណា? ឈ្មោះណា? មុខយ៉ាងម៉េច? អីយ៉ាងម៉េចទេ? គឺធ្វើយ៉ាងម៉េចឲ្យទាន់តែសភាពការណ៍ទេ ដូច្នេះការណ៍នេះគឺខ្ញុំអត់បានចាំច្បាស់ទេ ។

**លោក គឹម ម៉េងឃី៖**

សូមអរគុណ ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបន្តទៀតលោកប្រធាន គឺសូមអនុញ្ញាតឲ្យបញ្ចាំងនូវឯកសារដែលមានលេខ ERN00281230 ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ បង្ហាញនូវឯកសារដែលមានលេខ ERN ដូចទៅតាមសំណើសុំរបស់តំណាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**សួរដោយលោក គឹម ម៉េងឃី៖**

**ស៖** លោក ស្ងួស ធី, នេះគឺជាឯកសារដដែលពាក់ព័ន្ធទៅនឹងលោក អ៊ុក កេត គឺគេដាក់ចំណងជើងថា ឈ្មោះអ្នកទោសកម្ទេចថ្ងៃទី៩ ខែ១២ ឆ្នាំ១៩៧៧ ។ លេខរៀងរបស់លោក អ៊ុក កេត គឺនៅលេខរៀងទី៣៣ (សូមទោស) គឺ៤៣ ហើយនៅក្នុងនោះគឺមានអាយុ៣១ឆ្នាំ មកពីក្រសួងការបរទេស ហើយ

នាទីរបស់គាត់គឺជាលេខាទី៣ស្ថានទូត ហើយថ្ងៃខែកម្មេចនោះ គឺមានដាក់នៅក្នុងហើយសំណួររបស់ខ្ញុំសួរថា តើឯកសារនេះគឺលោកជាអ្នករៀបចំ ឬក៏ខាងអង្គភាពផ្សេងទៀតជាអ្នករៀបចំ?

**ឆ៖** នេះបើតាមខ្ញុំចំណាំ ចំពោះឈ្មោះអ្នកទោសដែលខ្ញុំរៀបចំកម្មេចនោះគឺ អានេះឯកសារនេះមិនមែនជារបស់ខ្ញុំទេ ពីព្រោះឯកសាររបស់ខ្ញុំអត់មានដាក់ថ្ងៃចូលខាងក្រៅទៀតទេ ។ អានេះបែបខាងក្រុម ម៉េង នោះគេធ្វើក៏មិនដឹងដែរ ។

**ស៖** សំណួរសួរថា ហេតុអ្វីបានជាឯកសារហ្នឹងគេមិនមែនក្រុមលោកអ្នកធ្វើ ហើយធ្វើដោយក្រុម ម៉េង វិញ?

**ឆ៖** ចំពោះឯកសារដែលខ្ញុំធ្វើ គឺធ្វើលំនាំទៅតាមហ្នឹងទាំងអស់ ប៉ុន្តែចំពោះចុងក្រោយ អាចុងខាង-- បន្ទាប់ពីនាទី មានថ្ងៃចូលគឺអត់មានដែលដាក់ទេ អត់មានសរសេរថ្ងៃចូល ចូលក្នុងហ្នឹងទេ ។

**ស៖** សូមអរគុណ ។ អ៊ីចឹង នៅពេលឯកសារដែលហ្នឹងធ្វើដោយ ម៉េង តើអ្នកទោសហ្នឹង គេចាត់ទុកថា ជាអ្នកទោសសំខាន់ដែរឬទេ? ឬក៏អ្នកទោសធម្មតាទេ?

[១៣:៤៤:៥៥]

**ឆ៖** អ្នកទោសអស់ទាំងនេះ គឺមិនសំខាន់ទេ គឺថាជាអ្នកទោសធម្មតាទេ ។

**លោក គីម ម៉េងឃី៖**

សូមអរគុណ ។ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីបញ្ចាំងនូវឯកសារមួយទៀត ដែលមានលេខ 00281210 ឬឯកសារ E2/84.3 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីផ្នែកខាងសោតទស្សន៍ដាក់បញ្ចាំងនូវឯកសារដែលស្នើសុំ ដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**សួរដោយលោក គីម ម៉េងឃី៖**

សុំៗខិតចុះក្រោមបន្តិច ។

**ស៖** ឯកសារនេះ គឺពាក់ព័ន្ធទៅនឹងអ្នកទោសផ្នែករដ្ឋការនៅក្នុងរបបសង្គមចាស់ ហើយដែលមានលេខ-- នៅក្នុងនោះគឺលេខរៀងទី៣៧ គឺឈ្មោះលោក អ៊ុក ជី ។ លោក អ៊ុក ជី គឺជាអ្នកតំណាងរាស្ត្រនៅក្នុងសម័យ លន់ នល់ ដែលត្រូវគេចាប់ខ្លួនយកមកមន្ទីរស-២១ហ្នឹងដែរ ហើយនៅក្នុងនោះគេដាក់ថា ត្រូវចាប់ខ្លួននៅតំបន់៣៣ គឺនៅក្នុងខេត្តកំពង់ស្ពឺ ។ ហើយមានថ្ងៃចូល ថ្ងៃចាប់ខ្លួន និងថ្ងៃកម្មេច

តើឯកសារហ្នឹងចេញដោយខាងលោក ឬក៏ដោយក្រុមផ្សេងទៀតនៅក្នុងស-២១?

**ឆ៖** ចំពោះឯកសារនេះ គឺមិនមែនជាចេញពីខាងខ្ញុំទេ ពីព្រោះឯកសារនេះគ្រាន់តែមើលតែដែលអក្សរនោះគឺ អក្សរមិនមែនអក្សរអង្គុលីលេខផង ។

**ស៖** តើលោកអាចបញ្ជាក់បានទេថា តើឯកសារហ្នឹងគឺអង្គភាពណាអ្នកចេញ? ហើយគេយកទម្រង់យ៉ាងម៉េចបានជាមានដាក់ចំណងជើង ដាក់ថ្ងៃចាប់ខ្លួន និងថ្ងៃកម្ទេចហ្នឹង? តើលោកអាចពន្យល់បានទេ តើគោលបំណងនៅក្នុងការធ្វើឯកសារហ្នឹង គឺដើម្បីអ្វី?

**ឆ៖** ចំពោះឯកសារនេះ គឺដូចជាមិនច្បាស់ វាមិនច្បាស់ថាក្នុងកន្លែងខ្ញុំធ្វើឯកសារ ពីព្រោះវាខុសៗ ខុសទាំងភិនភាគទាំងអស់ ខុសតាំងពីអក្សរទៅ ។ ហើយឯកសារនេះ បើតាមមើលដូចបោះដូចជាវ៉ៃពុម្ពរោងពុម្ពអ៊ីចឹងឯង ។ ដូច្នេះ ខ្ញុំមិនអាចសន្និដ្ឋានបានច្បាស់លាស់ចេញពីខាងណាទេ ។

[១៣:៤៨:៣៥]

**លោក គីម ម៉េងឃី៖**

បាទ សូមអរគុណ ។ លោកប្រធានសុំបង្វិលទៅរូបភាពដើមវិញ ។

**សួរដោយលោក គីម ម៉េងឃី៖**

**ស៖** សំណួរបន្តទៀត ដែលខ្ញុំសួរទៅលោកពាក់ព័ន្ធទៅនឹងថា បើសិនជាអ្នកទោសមិនសំខាន់ ឬក៏អ្នកទោសសំខាន់ហ្នឹង តើគេត្រូវចុះបញ្ជី ហើយនិងគេកំណត់ឲ្យទៅឃុំខ្លួននៅបន្ទប់ណាមួយជាក់លាក់ឬទេ? ឬក៏យកទៅដាក់នៅក្នុងបន្ទប់តែមួយដូចគ្នាទាំងអស់ ឬក៏យ៉ាងម៉េច?

**ឆ៖** ចំពោះអ្នកទោសជាទូទៅ គឺមុនដំបូងគឺបើបន្ទប់តូចទំនេរគេដាក់ក្នុងបន្ទប់តូចទាំងអស់ ប៉ុន្តែបើបន្ទប់តូចពេញគេយកឡើងលើ ។ ប៉ុន្តែ ដល់ពេលគេយកទៅសួរចម្លើយ គេអាចដកអ្នកណាដែលចេញយកមកដាក់ក្នុងបន្ទប់តូច ទៅឡើងលើវិញ ។

**ស៖** អរគុណ ។ សំណួរចុងក្រោយ សួរទៅកាន់លោក គឺថាចាប់តាំងពីការចូលបម្រើនៅក្នុងមន្ទីរស-២១ ចាប់ពីពេលចាប់ផ្ដើមរហូតដល់ស-២១ ត្រូវបានរំលាយដោយកងទ័ពវៀតណាម តើលោកមានដែលប្រព្រឹត្តកំហុស ឬក៏ទទួលរងទណ្ឌកម្មដោយសារការធ្វេសប្រហែស ឬក៏ខុសអ្វីដែរឬទេ នៅក្នុងការអនុវត្តមុខងាររបស់លោកនៅក្នុងសម័យនោះ? សូមអរគុណ ។

**ឆ៖** កាលក្នុងសម័យនោះ ខ្ញុំនិយាយឲ្យត្រង់គឺថា ដោយឃើញការចាប់នៅក្នុងបុគ្គលិករបស់មន្ទីរស-២១ ជាបន្តបន្ទាប់ ដូច្នេះការងាររបស់ខ្ញុំ គឺខ្ញុំខំប្រឹងធ្វើ គឺខ្លាចខុសណាស់ ។ ជាពិសេសនៅពេល

ដែលចាប់បុគ្គលិកមន្ទីរស-២១ ហើយបន្តទៀតចាប់អ្នកធ្វើបញ្ជីនៅកងសួរចម្លើយ ពេលហ្នឹងហើយដែលខ្ញុំចាប់ភ័យ ។ ហើយដល់ចុងក្រោយចាប់ នុន ហ៊ុយ-- ហ៊ុយ ស្រែ នោះទៀតដែលជាមេបញ្ជាការផ្ទាល់របស់ខ្ញុំនៅសមរភូមិ ខ្ញុំនៅជាមួយរហូតហ្នឹងគឺអារម្មណ៍ខ្ញុំកាន់តែភ័យទៅៗ ។ ដូច្នេះ ការងារអ្វីក៏ដោយគឺខ្ញុំប្រុងប្រយ័ត្នណាស់ខ្លាចតែគេថា ខ្ញុំខុសហ្នឹងគឺខ្ញុំអាចមានទោសឆាប់ណាស់ ។

**ប្រធានអង្គជំនុំ៖**

ជាតទៅនេះ ប្រគល់វេទិកាអ្នកតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមពីរ ។ សូមអញ្ជើញ ចាប់ផ្ដើមពីម៉ោងមួយហាសិបនាទី ក្រុមនេះមានពេលវេលាដប់ប្រាំនាទី ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ។

**ស៖** សូមជម្រាបសួរលោក ស្ទួស ធី! ខ្ញុំឈ្មោះ ស៊ីលឃីស្ទួត ហ្សីនស្គី ។ ខ្ញុំជាមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ។ ខ្ញុំនឹងសួរសំណួរមួយចំនួនទៅលោក ។ សំណួរទីមួយ តើលោកនៅចាំទេថា តើរយៈពេលវែងបំផុតសម្រាប់អ្នកទោសដែលថា គេដាក់យូរជាងគេបំផុតហ្នឹងរយៈពេលប៉ុន្មាននៅស-២១?

[១៣:៥២:២៣]

**ឆ៖** ចំពោះរឿងនេះ គឺថាខ្ញុំមិនអាចដឹងច្បាស់ពិតប្រាកដទេ ។ ប៉ុន្តែ ចំពោះដែលខ្ញុំសន្និដ្ឋាន អ្នកទោសយូរបំផុតត្រឹមពីរខែ អស់ហើយ ។

**ស៖** តើលោកធ្លាប់ជួបប្រទះរឿងមួយ ឬក៏អ្នកទោសណាម្នាក់ត្រូវបានគេឃុំខ្លួននៅស-២១ ដប់ប្រាំបួនខែដែរឬទេ?

**ឆ៖** ចំពោះអ្នកទោសដែលគេឃុំខ្លួននៅស-២១ ១៩ខែ គឺខ្ញុំចាំមិនច្បាស់ទេ ប៉ុន្តែដូចជាខ្ញុំសន្និដ្ឋានដូចជាអត់មានទេ ។ប៉ុន្តែ ខ្លាចក្រែងលោដែលអ្នកធ្វើការខាងក្រៅក៏មិនដឹង ឬក៏អី ប៉ុន្តែខ្ញុំមិនអាចសន្និដ្ឋានបាន ។ ដូច្នេះ ខ្ញុំចាំមិនច្បាស់ទេ ។

**ស៖** សូមអរគុណ ។ ឥឡូវនេះ ខ្ញុំចូលទៅដល់បញ្ជីដែលលោកបានរៀបចំធ្វើ អំពីកាលបរិច្ឆេទដែលអ្នកទោសចូលមកដល់ ដែលលោកបានកត់សម្គាល់នោះ កត់ត្រានោះ តើត្រឹមត្រូវទេដែលខ្ញុំនិយាយថាលោកធ្វើការមិនឲ្យមានកំហុស? ហើយកាលបរិច្ឆេទដែលលោកកត់នោះត្រឹមត្រូវទាំងអស់ តើអ៊ីចឹង-- គឺថ្ងៃខែឆ្នាំដែលអ្នកទោសចូលនោះ តើអ៊ីចឹងឬទេ?

**ឆ៖** ចំពោះថ្ងៃខែឆ្នាំដែលអ្នកទោសចូលនោះ គឺខ្ញុំកត់ត្រឹមត្រូវទៅតាមថ្ងៃដែលចូល ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

សូមលោកប្រធានមេត្តាបង្គាប់ឲ្យខាងសោតទស្សន៍ បង្ហាញឯកសារដែលមានលេខ ERN0018 8853 នៅលើកញ្ចក់ទូរទស្សន៍ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍បង្ហាញឯកសារ ដែលមានលេខ ERN00188853 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍តាមសំណើសុំរបស់មេធាវី អ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

**ស៖** លោកបានទទួលស្គាល់ហើយថា លោកបានរៀបចំឯកសារនេះ បើសិនជាលោកមើលបញ្ជីអ្នកទោសចូលថ្ងៃទី១២ ខែ១២ ឆ្នាំ១៩៧៦ នូវលេខទី៩ ហើយលោកមើលឃើញថា តើលោកអាចរៀបរាប់ទេថាតើនៅក្នុង ជ៤ ហ្នឹង ជ០៤ ហ្នឹង តើអគារហ្នឹង បន្ទប់ហ្នឹងដូចម្តេចដែរ?

[១៣:៥៦:៣០]

**ឆ៖** ខ្ញុំសូមបញ្ជាក់ លេខ ជ០៤/១៨ ដូច្នេះលេខ-- មិនលេខ “ជ” អាហ្នឹងដូចលេខ “ថ” ទេ តាម មើល-- អ្ហ៎! “ជ” អ៊ីចឹងហើយ “ជ” ប៉ុន្តែខ្ញុំភ្លេចអស់ហើយអារឿង-- អានេះលេខផ្ទះ លេខបន្ទប់ទេ បើចង់បញ្ជាក់គឺថា ខ្ញុំចង់បញ្ជាក់ថា ហ្នឹងហើយជាលេខផ្ទះលេខបន្ទប់ ។ ប៉ុន្តែ ដល់វាយូរពេកខ្ញុំវាភ្លេចមិនអាចចងចាំបាន ។

**ស៖** មានន័យថា លោកមិននៅចាំទេថា ជ០៤ និង១៨ ហ្នឹងមិនដឹងថានៅកន្លែងណា នៅអគារត្រង់ណា តើលោកភ្លេច? ឬក៏លោកអាចនៅនឹកឃើញទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ដោយត្រង់ ដូចភ្លេចនឹកមិនឃើញ ពីព្រោះ ០៤ វាមានបន្ទប់តូចបន្ទប់ធំ និងអគារ ដូច្នេះដល់មកឃើញឥឡូវហ្នឹង គឺខ្ញុំវាមិនអាចចែកនឹងបន្ទប់តូចលេខ០៤ ឬក៏-- “ជ” ហ្នឹងក៏លេខប៉ុន្មាន គឺខ្ញុំពិបាកសន្និដ្ឋានណាស់ ព្រោះខ្ញុំភ្លេចទៅអាហ្នឹង ។ អាហ្នឹងប៉ុន្តែជាការកំណត់គឺលេខផ្ទះ លេខបន្ទប់ហើយអាហ្នឹង ។

**ស៖** សូមអរគុណលោក សួស ធី នេះជាចំណងជើងនៃអ្នកទោសម្នាក់ត្រង់លេខ៩នេះ តើលោកនៅចាំទេអំពីប្រវត្តិរូបរបស់លោក ភឹង តុន ដែលសហព្រះរាជអាជ្ញាបានប្រាប់ទៅលោក បង្ហាញទៅលោកហើយ អំពីប្រវត្តិរូបរបស់គាត់នោះ តើលោកនៅចាំទេ?

**ឆ៖** ដូចខ្ញុំបានបញ្ជាក់ជូនពីមុនមកហើយ ពីព្រោះការធ្វើបញ្ជីនេះគឺធ្វើម្នាក់ឯង គឺធ្វើយ៉ាងម៉េចឱ្យតែហើយដើម្បីធ្វើទៅមុខទៅទៀត ។ ដូច្នេះ ការចងចាំរបស់ខ្ញុំគឺ ដូចថាអត់បានច្បាស់លាស់ទេ អត់បានដឹងទេ គឺគេ គឺធ្វើថ្ងៃហ្នឹង គឺឱ្យទាន់ហើយចប់ទុកមួយឡែក ស្អែកធ្វើទៀត ធ្វើអ្នកបន្តៗមកទៀត ។ ដូច្នេះ គឺខ្ញុំមិនបានជាចាប់អារម្មណ៍ឱ្យបានច្បាស់លាស់ ។

**លោកស្រី ស៊ីលឃីស្វូត ហ្សីនស្គី៖**

ខ្ញុំគិតថា លោកមិនទាន់យល់សំណួរទេ។ អ៊ីចឹង សូមឱ្យលោកប្រធានសួរ-- សូមឱ្យបង្គាប់ខាង *អេវី(AV)* តាំងឯកសារហ្នឹង ឯកសារលេខ 00188857 ម្តងទៀតនៅលើអេក្រង់ ។

[១៣:៥៩:៥០]

**ប្រធានអង្គជំនុំ៖**

មេធាវីអានលេខERN ម្តងទៀត ។ ឯកសារដែលប៉ុនប៉ងសូមឱ្យដាក់បង្ហាញលើកញ្ចក់អេក្រង់ទូរទស្សន៍ហ្នឹង ឯកសារលេខERN យ៉ាងដូចម្តេច?

**លោកស្រី ស៊ីលឃីស្វូត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ERN លេខ00188857 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍បង្ហាញឯកសារដែលមានលេខERN00188857 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍តាមសំណើសុំរបស់មេធាវី អ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ។

**សួរដោយលោកស្រី ស៊ីលឃីស្វូត ហ្សីនស្គី៖**

សូមអរគុណ ។ សូមឱ្យលោកធ្វើការពិនិត្យទៅលើប្រវត្តិរូបនេះ ដែលលោកបានស្គាល់ហើយថាលោកបានរៀបចំប្រវត្តិរូបរូបនេះ ។ សូមឱ្យខាងសោតទស្សន៍ទាញចុះក្រោមបន្តិច ។

**ស៖** នៅក្នុងនេះ នៅចំណុចចុងក្រោយ លោកបានពិនិត្យឃើញបន្ទប់ តាមដែលខ្ញុំយល់ ដែលអ្នកទោស ភឹង តុន នេះ គាត់ត្រូវបានគេបញ្ជូនទៅឱ្យទុកក្នុងបន្ទប់ហ្នឹង គឺបន្ទប់ធំ លេខបី តូចបី ផ្ទះមួយនេះគឺជាកន្លែងដែលគេឃុំគាត់ ឬក៏វាជាកន្លែងដែលគេឃាត់ខ្លួនគាត់ តើវាមានន័យយ៉ាងម៉េចនៅពេលដែលដាក់លេខដូច្នេះ តើលោកអាចជួយពន្យល់ទេ?

**ឆ៖** នេះ គឺជាកន្លែងឃុំរបស់គាត់ហើយ ។ គឺផ្ទះមួយ បន្ទប់ធំបី តូចបី ។

**ស៖** តើលោកជាអ្នករៀបចំប្រវត្តិរូបនេះ គឺនៅពេលដែលស្របគ្នា ។ បានន័យថា លោកបង្កើតប្រវត្តិរូបនេះ រួមគ្នាទៅនឹងបញ្ជីអ្នកទោស ដែលចូលមកដល់ថ្ងៃ១២ ឆ្នាំ៧៦ហ្នឹង ឬយ៉ាងម៉េច? បានន័យឯកសារមួយហ្នឹង ហើយនិងឯកសារអម្បាញ់មិញនោះ គឺបានរៀបចំនៅពេលតែមួយ នៅពេលដែលលោក ភីង តុន បានចូលមកដល់ការិយាល័យរបស់លោក ឬក៏យ៉ាងម៉េច?

**ឆ៖** អានេះចំពោះ-- ខ្ញុំសូមឲ្យបញ្ជាក់សំណួរម្តងទៀត ។

**ស៖** ខ្ញុំនឹងបញ្ជាក់ជូនលោក ។ លោកបានពិនិត្យឃើញប្រវត្តិរូបមួយនេះ ហើយខ្ញុំសង្ឃឹមថាលោកចាំអំពីបញ្ជីអ្នកទោស ដែលខ្ញុំបានបញ្ចាំងលោកអម្បាញ់មិញនោះ គឺអ្នកទោសដែលបានចូលនៅថ្ងៃទី១២ ខែ១២ ឆ្នាំ៧៦ ។ ដូច្នេះនៅពេលនេះ ខ្ញុំចង់សួរថា តើឯកសារទាំងពីរនេះ គឺប្រវត្តិរូបមួយនេះ និងបញ្ជីអ្នកទោសនុ៎ង តើវាបានរៀបចំនៅថ្ងៃតែមួយរួមគ្នាតែម្តង ឬក៏យ៉ាងម៉េច?

[១៤:០៤:០១]

**ឆ៖** ចំពោះបញ្ជីនេះ ចំពោះថ្ងៃប្រវត្តិរូប ហើយនិងបញ្ជីចូលនោះ គឺចំពោះបញ្ជីប្រវត្តិរូបនេះគេធ្វើពេលអ្នកទោសចូលមកដល់ភ្លាម ។ ប៉ុន្តែ អាហ្នឹងជាក្រោយពីបន្ទាប់ពីការយើងកត់អាបញ្ជីវែងទេ អាបញ្ជីវែងដែលជា វ៉ៃគេនោះ បានកត់ចូល ហើយអានេះធ្វើបន្ទាប់ពីថ្ងៃហ្នឹងមក បានយើងមានពេល បានគេចាប់សរសេរចូលក្នុងប្រវត្តិរូបនេះ ។

**ស៖** ខ្ញុំសង្កេតឃើញថា បន្ទប់ដែលគេយកអ្នកទោសនេះទៅឃុំ បន្ទប់នោះ គឺយើងឃើញថាសរសេរខុសគ្នានៅក្នុងឯកសារពីរផ្សេងគ្នាហ្នឹង គឺនៅក្នុងប្រវត្តិរូប ហើយនិងបញ្ជីហ្នឹង គឺមានលេខបន្ទប់ខុសគ្នា តើលោកអាចជួយពន្យល់ទេ ហេតុអ្វីបានជាខុសគ្នាអ៊ីចឹង?

**ឆ៖** ខ្ញុំសូមបញ្ជាក់ចំពោះបន្ទប់ខុសគ្នា នេះអាស្រ័យទៅលើការដូរដេញរបស់អ្នកកងការពារនៅខាងក្នុងទេ បើសិនជាកន្លែងណាដែលគេដូរ គឺគេប្រាប់ឲ្យដូរបន្ទប់ ដូច្នេះខ្ញុំត្រូវតែដូរលេខបន្ទប់ហ្នឹងទៅតាមដែលគេប្រាប់មកពីក្នុង ។ ពីព្រោះអ្នកទោសអ្នកទាំងអស់ គេមិនអាចនៅក្នុងបន្ទប់ហ្នឹងរហូតទេ ជួនកាលនៅបន្ទប់នេះ ជួនកាលនៅបន្ទប់នោះ ស្រេចតែលើកងការពារដែលគេដូរចេញចូល ។ ប៉ុន្តែទោះបីជាគេដូរចេញចូលយ៉ាងណា ក៏គេត្រូវមកប្រាប់ខ្ញុំដែរ ដើម្បីឲ្យខ្ញុំដឹងពីបន្ទប់នោះ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

ខ្ញុំមើលថា ខ្ញុំដូចជាជិតអស់មើលហើយ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំសូមជម្រាបអង្គជំនុំជម្រះថាខ្ញុំមានបំណងចង់ដាក់ជូនឯកសារនេះ គឺឯកសារលេខ D25/5/7 ហើយចង់សួរទៅលើសាក្សីថាតើ

គាត់ស្គាល់ឯកសារនេះដែរឬទេ? គឺឯកសារ D25/5/5 ហើយនិងឯកសារ D25/5/13 ហើយនិងឯកសារលេខ 00018853 ឯកសារនេះ គឺមានរូបភាពលោក ភឹង តុន ។ ដូច្នេះហើយ គឺស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការសួរសំណួរទាំងអស់នេះ សួរសំណួរនេះ ថាតើសាក្សីគាត់បានស្គាល់ទៅលើបញ្ជីដែលខ្ញុំរៀបរាប់ទាំងអស់នោះដែរឬទេ? ហើយខ្ញុំសូមថ្លែងអំណរគុណលោក សួស ធី ដែលបានឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំ ។ សូមអរគុណអង្គជំនុំជម្រះទាំងមូល ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអ្នកតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមមួយ ។ ចាប់ផ្ដើមពីម៉ោងពីរប្រាំមួយនាទី ។

**សួរដោយកញ្ញា ទី ស្រ៊ុនណា៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល ។ ជម្រាបសួរលោកសាក្សី! នាងខ្ញុំឈ្មោះ ទី ស្រ៊ុនណា ជាមេធាវីជាតិ និងមេធាវី អាឡាំង វ៉ែនណឺ ជាមេធាវីអន្តរ-ជាតិនៅក្នុងក្រុមមួយរបស់នាងខ្ញុំ ។ យើងជាមេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមមួយ ។ សូមតាំងសំណួរដូចតទៅ៖

**ស៖** មុននឹងខ្ញុំធ្វើការតាំងសំណួរ ខ្ញុំសូមធ្វើការបញ្ជាក់ដែលទៅនឹងឯកសារមួយដែលលោកបានឆ្លើយនៅក្នុងដំណាក់ចៅក្រមស៊ើបអង្កេត កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧ ដែលមានលេខ D22/9 និងលេខ ERN ជាភាសាខ្មែរមានលេខ 00162606 និង ERN ជាភាសាអង់គ្លេសមានលេខ 00162621 ។ នៅពេលនុ៎ះ មានមន្ត្រីតុលាការបានសួរលោកថា “គាត់នៅរស់ទេ ឡាញ់--ឡាន់” លោកក៏បានឆ្លើយថា “អត់ដឹង ពួកហ្នឹង ពួកអមលាំង ឌុច គេយកមក កាលហ្នឹងគេចាប់៧០៣ជិតអស់ហើយបាន ឌុច គេយកពីខាងអមលាំងមកវិញ” តើលោកពិតជាបាននិយាយអ៊ីចឹងមែនទេ? លោកមានបានឆ្លើយចំណុចហ្នឹងទៅការិយាល័យសហចៅក្រមអង្កេតដែរឬទេ?

**ឆ៖** កាលហ្នឹង គឺខ្ញុំបានឆ្លើយពិតជាអ៊ីចឹងមែន ។

**ស៖** តើលោកមានបានដឹងថា ហេតុអីបានជាគេចាប់កង៧០៣ជិតអស់? តើមូលហេតុអីតើលោកមានបានដឹងទេ?

**ឆ៖** រឿងមូលហេតុអស់ទាំងនេះ គឺខ្ញុំដឹងមិនច្បាស់ទេ ប៉ុន្តែឃើញការដាក់ស្លែង កងពល៧០៣ដែលមកនៅក្នុងកន្លែងគុកតាំងពីផ្សារថ្មីមក គឺមនុស្សច្រើនណាស់ ។ ដល់ក្រោយមក គឺអស់ទៅៗ យូរៗអស់ទៅ បានឃើញកម្លាំងខាងអមលាំងចូលមកបន្ថែមទាំងខាងសួរចម្លើយ ទាំងផ្នែកការពារ ទាំងក្នុង

មន្ទីរខ្ញុំ ក៏គេដាក់ម្នាក់មកទៀតដែរ ។ ដូច្នេះ ខ្ញុំឆ្លើយនេះ ឆ្លើយទៅតាមការជាក់ស្តែងពិត ប៉ុន្តែចំពោះរឿងផ្ទៃក្នុងពីមូលហេតុ គឺខ្ញុំមិនបានដឹងច្បាស់លាស់ទេ ។

**ស៖** ចុះលោកមានដឹងថា តើនរណាជាអ្នកបញ្ជាឲ្យចាប់ក្រុមកងពល៧០៣?

**ឆ៖** អ្នកដែលមានសិទ្ធិ ដើម្បីចាប់មនុស្ស គឺមានតែថ្នាក់ ឌុច ទេ ដែលមានសិទ្ធិសម្រេច ក្រៅពីហ្នឹង គឺគ្មានសិទ្ធិទេ ។

**ស៖** ចុះលោកដែលបានដឹងពីទំនាក់ទំនងរវាង ហ៊ី ហើយនិង ឌុច តើយ៉ាងដូចម្តេចដែរ?

**ឆ៖** ការទំនាក់ទំនងរវាង ហ៊ី និង ឌុច ដែលនេះគឺខ្ញុំមិនបានដឹងច្បាស់ទេ ប៉ុន្តែបើតាមសភាពជាក់ស្តែងដែលខ្ញុំឃើញ គឺ ហ៊ី នោះ គឺខ្លាច ឌុច នោះជាងអ្វីទាំងអស់ កុំឲ្យតែឮសូរនីរសារហៅ ទោះបីនៅកន្លែងណា ក៏ត្រូវតែរូតរះប្រញាប់ដែរ គឺខ្លាចណាស់ អាហ្នឹងខ្ញុំឃើញការជាក់ស្តែង ។ ប៉ុន្តែ ចំពោះការទំនាក់ទំនងយ៉ាងម៉េច គឺខ្ញុំមិនដឹងទេ ។

[១៤:១២:០២]

**ស៖** តើបុគ្គលិកមន្ទីរ ស-២១ទាំងអស់ សុទ្ធតែខ្លាច ឌុច ដូច ហ៊ី ដែរ ឬមួយក៏តែករណី ហ៊ី ដែលខ្លាចឌុចហ្នឹងតែម្នាក់ឯង?

**ឆ៖** ខ្ញុំសូមបញ្ជាក់ឲ្យត្រង់ កុំថាឡើយនេះ គ្រាន់តែ ហ៊ី ហៅខ្ញុំ ក៏ខ្ញុំខ្លាចដូចខ្លាដែរ ហើយបើ ឌុច ទៀត ខ្ញុំលែង១ប៊ានមើលមុខ និយាយឲ្យត្រង់តែម្តង ។ ពីព្រោះដល់ថ្នាក់កម្មាភិបាលនៅខាងហ្នឹង ដូចថាខាង ឌុច អត់ប៊ានហៅឈ្មោះ ឌុច ទេ ហ៊ី ក៏អត់ប៊ានហៅឈ្មោះ ហ៊ី ដែរ គឺហៅតែបងខាងកើត បងខាងលិចទេ ។ ដូច្នេះ គឺអំណាចសម័យនោះ គឺខ្លាំងណាស់ ។ ខ្ញុំនិយាយនេះ មិនមែនដើម្បីអ្វីទេ គឺខ្ញុំនិយាយប្រាប់ការពិតជាក់ស្តែង ។

**ស៖** ខ្ញុំសូមលើនៅឯកសារមួយទៀត ដែលមានលេខ D61/I ឯកសារហ្នឹង គឺជាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលលោកបានធ្វើកិច្ចសម្ភាសន៍កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៤ នៅត្រង់ទំព័រដែលមានលេខ ERN ជាភាសាខ្មែរ 000052028 និង ERN ជាភាសាអង់គ្លេស ដែលមានលេខ00337982 ។ នៅពេលហ្នឹង គឺបុគ្គលិករបស់មជ្ឈមណ្ឌលបានសួរលោកថា "តាណាត ខ្លាច ឌុច" ។ ហើយលោកក៏បានឆ្លើយថា "ហ្នឹងហើយក៏ខ្លាច ឌុច ដែរ គាត់ថ្នាក់កងពលមិនធម្មតាទេ ហើយខ្លាចឌុច ខ្ញុំគ្រាន់តែឃើញអត្តចរិត ដែលនេះអីទេ ហើយ ហ៊ី នេះ ខ្លាច តាណាត ជាងអីទៀត ព្រោះអ្នកកងពល អ្នកវរសេនាតូច វាតួនាទីវាខុសគ្នាឆ្ងាយណាស់ ព្រោះគេអ្នកកងពល គេមានសិទ្ធិដក គេមាន

សិទ្ធិអីទាំងមួយចប់ ។ ហើយទម្រាំតែ តាណាត ចង់ខ្លាចណា ឌុច ទៀតហើយ មិនដឹងយើងមួយថ្ងៃៗ បន់កុំឱ្យតែ តាហ៊ី ខ្ញុំនិយាយត្រង់ កុំឱ្យតែឮសូរគាត់ហៅទេ ចេះតែខំធ្វើៗទៅ ខ្លាចតែហៅ មានការអីទេ" តើលោកពិតជាបាននិយាយបែបហ្នឹង ប្រាប់ទៅបុគ្គលិកអីចឹង ទៅឯកសារកម្ពុជាដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់សាជាថ្មី ចំពោះ តាណាត និង តាឌុច គឺខ្ញុំមិនបានដឹងច្បាស់ពិតប្រាកដទេ ការនិយាយនេះ ។ ប៉ុន្តែ បើនិយាយចំពោះ ហ៊ី និង ឌុច គឺពិតប្រាកដមែន គឺថាហ៊ី គឺខ្លាច ឌុច មែនទែន ហើយចំពោះថ្នាក់ក្រោម គឺខាងលើគឺខ្លាចណាស់ ខ្លាចតែគេហៅទៅខ្លាចមានការអីៗ គឺខ្លាចណាស់ ។ គ្រាន់តែឃើញមុខគេមិនចង់ប៉ានជួបមុខផង មើលមុខគេអត់ប៉ានមើលមុខផង ។

**ស៖** ចុះនៅក្នុងដំណាក់ហ្នឹង គេបានប្រើពាក្យ ហ៊ី និង ហោ តើ ហ៊ី និង ហោ ជាមនុស្សតែម្នាក់ ឬក៏មនុស្សពីរនាក់ផ្សេង?

**ឆ៖** អត់មានឈ្មោះ ហោ ទេ គឺមានតែឈ្មោះ ហ៊ី ។

**ស៖** ខ្ញុំសូមបន្តសំណួរខ្ញុំទៀត គេបានសួរលោកថា ចុះ ហ៊ី អីមានសិទ្ធិចាប់ទេ? ប៉ុន អី? ដោយសារតែសំណួរដែលខ្ញុំបម្រុងលើកអម្បាញ់មិញនេះ លោកបានឆ្លើយហើយៗ អីចឹងខ្ញុំសូមបន្តសំណួរមួយទៀត ។ គេបានសួរលោកថា "ចុះពូអាចបញ្ជាក់ពីរឿងការដក ការចម្រាញ់អ្នកធ្វើការចាស់ៗ ដែលមកពីកងពល១២ ត្រូវបានគេដកចេញទៅពេលក្រោយមកទៀត អាហ្នឹងវាដោយសារមូលហេតុអី? ពូបានដឹងទេ?" លោកបានឆ្លើយថា "ខ្ញុំវាមិនបានដឹងច្បាស់លាស់ទេ ព្រោះអាហ្នឹងវាពិបាកណាស់ ព្រោះអានេះវាផ្សេងគ្នា ។ អានេះ បើតាមពិតទៅ ឧបមាថា អ្នកទោសរត់រួចត្រូវយុទ្ធជនការពារនៅហ្នឹងហើយ ហើយដល់ពេលវែគ្នាឃើទៅ ចេះតែឆ្លើយ ឆ្លើយទៅចេះតែចាប់ ។ អានេះថា វាពិបាករឿងនេះ វារកយុត្តិធម៌អត់ឃើញ ហើយដល់នេះ ចេះតែចាប់អីចឹងពិបាកណាស់ អានេះខ្ញុំនិយាយមែន ចេះតែនិយាយ--មិនមែនចេះតែនិយាយទេ និយាយទៅតាមការដែលខ្ញុំដឹង" ។ តើលោកពិតជាបាននិយាយបែបនេះមែនទេ?

**ឆ៖** ចំពោះការនិយាយនេះ គឺខ្ញុំបាននិយាយមែន គឺថា--

**ស៖** តើការដែលគេចាប់ៗអ្នកយាមដែលគាត់បានធ្វើឱ្យគេរួចខ្លួន ហើយគេវៃសួរចម្លើយបែបហ្នឹង ហើយអ្នកដែលគេឆ្លើយដាក់ហ្នឹងត្រូវបានគេចាប់ ។ តើករណីហ្នឹងកើតមានចំពោះអ្នកទោសទូទៅ ឬមួយក៏កើតមានចំពោះតែអ្នកដែលជាបុគ្គលិកមន្ទីរស-២១ ដែលគាត់មានថ្លោះធ្លោយបែបនេះ? សូមលោកជួយបំភ្លឺ ។

[១៤:១៩:២៤]

**ឆ៖** ចំពោះការណ៍នេះ គឺខ្ញុំមិនបានដឹងច្បាស់ទេ ប៉ុន្តែខ្ញុំសូមបញ្ជាក់ការជាក់ស្តែង គឺនៅពេលដែលអ្នកទោសរត់រួចម្នាក់ គឺនៅអគារហ្នឹងបីនាក់ គឺចាប់ទាំងបីនាក់ ព្រមទាំងចាប់កងហា ដែលជាអ្នកទទួលនៅអគារហ្នឹងទៀត ហើយបានចាប់កងរយម្នាក់ទៀត ។ អានេះខ្ញុំឃើញជាក់ស្តែង ។

**ស៖** ខ្ញុំសូមបន្តសំណួរខ្ញុំទៀត ។ ពីព្រឹកមិញលោកបានជម្រាបជូនអង្គសវនាការ ក៏ដូចជាជម្រាបលោកចៅក្រម ឡាវែន៍ ទាក់ទងទៅនឹងចំណុចមួយដែលលោកនិយាយថា លោកបានឃើញជនជាប់ចោទ គឺ ឌុច បានដើរទៅម្តុំបន្ទប់គូរគំនូរ ។ តើការដែលលោកឃើញសកម្មភាពបែបហ្នឹង លោកអាចចាំបានទេប្រហែលជានៅក្នុងឆ្នាំណាដែរ?

**ឆ៖** ការដែលគាត់កន្លែងហ្នឹង គឺគាត់ច្រើនទៅ-- នេះគឺការ-- បើនិយាយពីការចងចាំរឿងឆ្នាំរឿងអី គឺខ្ញុំមិនបានជាចាំទេឥឡូវនេះ ។

**ស៖** ចុះលោកអាចចាំបានទេថា ពេលលោកឃើញគាត់នៅក្នុងស្ថានភាពពេលនោះៗ តើគាត់អត្តចរិតរបស់គាត់យ៉ាងម៉េចដែរ? គឺខ្ញុំចង់សំដៅថា តើគាត់មានភាពរីករាយធម្មតា ឬមួយក៏មានភាពភ័យខ្លាច ឬក៏ព្រួយបារម្ភអ្វីមួយបានជាគាត់ទៅក្នុងបន្ទប់នោះ? តើលោកអាចចងចាំចំណុចនេះបានទេសូមលោកជួយបំភ្លឺ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ចំពោះអ្នកធំដែលមកកន្លែងក្នុងគុកហ្នឹង គឺខ្ញុំមិនបានជាសង្កេតអីជិតដល់ទេ ពីព្រោះខ្ញុំខ្លាចណាស់ ខ្លាចណាស់អ្នកធំ គឺមកគឺខ្ញុំសឹងតែនៅកន្លែងខ្ញុំធ្វើការ គ្រាន់តែឃើញមួយភ្លែតគាត់ដើរចូលមក គាត់ចូលៗទៅ អត់ចាប់អារម្មណ៍តែ ។ គឺនៅកន្លែងធ្វើការហ្នឹង ។

**ស៖** អ៊ីចឹង ខ្ញុំសូមបន្តសំណួរខ្ញុំទៀត។ ទាក់ទងទៅនឹងពេលដែលអ្នកទោសនៅមន្ទីរស-២១ ត្រូវបានបញ្ជូនទៅកម្ទេចអស់ ពេលនុំងគឺបុគ្គលិកមន្ទីរស-២១ សុទ្ធតែនៅទំនេរទាំងអស់ ។ អ៊ីចឹង នៅក្នុងអំឡុងពេលដែលនៅទំនេរហ្នឹង តើថ្នាក់លើមានដែលប្រាប់ដល់បុគ្គលិកទាំងអស់ថាឲ្យត្រៀមលក្ខណៈអ្វីដែរឬទេ? ឬមួយក៏បានប្រាប់ថា ឲ្យត្រឡប់ទៅផ្ទះវិញ ឬមួយក៏បានប្រាប់ថាឲ្យត្រៀមលក្ខណៈទទួលអ្នកទោសថ្មី? តើលោកអាចចងចាំចំណុចនេះបានដែរឬទេ?

**ឆ៖** ចំណុចនេះ គឺខ្ញុំនៅកន្លែងហ្នឹង ក្រោយពីអ្នកទោសនេះអស់ទៅ គឺគេអត់មានបានបញ្ជាថាឲ្យត្រៀមអីៗទេ គឺអ្នកនៅកន្លែងណា នៅកន្លែងហ្នឹង ពីព្រោះការងារដែលយើងធ្វើអី គឺនៅកន្លែងណាកន្លែងហ្នឹងការពារដឹងការពារ អ្នកថតដឹងអ្នកថតទៅ គឺអត់មានគេប្រាប់អីឲ្យត្រៀមអីៗទេគឺអត់បានដឹង។

[១៤:២២:៤៤]

**ស៖** សំណួរចុងក្រោយរបស់នាងខ្ញុំ ។ នាងខ្ញុំចង់សួរថា ចាប់តាំងពីលោកធ្វើការនៅមន្ទីរស-២១ ពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ តើលោកមានដែលទទួលបាននូវផលប្រយោជន៍ពីការងាររបស់លោក ឬក៏ពីថ្នាក់លើដែរឬទេ? សូមអរគុណ ។

**ឆ៖** ខ្ញុំសូមបញ្ជាក់ ចាប់តាំងពីខ្ញុំចូលមកបម្រើការងារនៅគុករបស់កង៧០៣ រហូតមកនៅមន្ទីរ ស-២១ ចំពោះការដែលខ្ញុំបានពីផលប្រយោជន៍របស់នោះ គឺខ្ញុំគ្មានបានអី គឺបានតែការភ័យខ្លាច និងបានការខ្លាចតែជាប់គុកតែមួយមុខនិងស្លាប់តែប៉ុណ្ណឹងទេ ។ ខ្ញុំនិយាយៗដោយត្រង់ ការធ្វើការងារសម័យនោះ គឺខ្ញុំមួយថ្ងៃៗសឹងអត់វិញ្ញាណអ៊ីចឹង ។ ខ្លាចតែខុសៗ គេចាប់ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះអង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការសួរតាំងសំណួរដល់សាក្សីរូបនេះប្រសិនបើមាន ។ សូមអញ្ជើញមេធាវី មេធាវីមានរយៈហុកសិបនាទីក្នុងការសួរនេះ ។

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន សូមគោរពលោកប្រធាន និងគោរពលោកចៅក្រមជាតិ និងអន្តរជាតិ សូមគោរពអង្គសវនាការទាំងមូល ។

**ស៖** លោក សួស ធី ក្នុងឋានៈលោកជាអ្នកកាន់បញ្ជីនៅស-២១ តើមានអ្នកទោសនៅស-២១ ក្រុងភ្នំពេញយើងនេះ ដែលបញ្ជូនទៅព្រៃសឬទេ?

**ឆ៖** ចំពោះស-២១ អ្នកទោសដែលនៅក្នុងមន្ទីរស-២១ គឺមិនដែលបញ្ជូនអ្នកទោសទៅស្រែទេ ឲ្យតែចូលក្នុងគុកហើយ គឺអត់មានបញ្ជូនទៅស្រែទេ ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់បើសិន អានេះការងារហ្នឹង គឺខ្ញុំមិនដឹងក្រែងលោគេបញ្ជូនមកខាងក្រៅ ហើយបានគេបញ្ជូនទៅខាងព្រៃស ខ្ញុំមិនដឹងច្បាស់ទេ ។ ប៉ុន្តែ អ្នកទោសដែលទៅចូលក្នុងគុកហើយ គឺគ្មានបញ្ជូនទៅណាទៀតទេ ។

**ស៖** សូមអរគុណ ។ នៅស-២១ លោកបានជម្រាបអង្គសវនាការថា គ្មានពេទ្យស្រីទេ អ៊ីចឹងមែនទេ?

**ឆ៖** ជាការពិតដែលខ្ញុំនៅកន្លែងនោះ គឺអត់មានពេទ្យទេ ។

[១៤:២៦:០៥]

**ស៖** សូមអរគុណ ។ ពីម្សិលមិញលោកជម្រាបលោកប្រធានថា នៅតាមអគារនីមួយៗមានពេទ្យសម្រាប់ព្យាបាលអ្នកទោស តើលោកមានបានចាំឈ្មោះពេទ្យណាខ្លះដែលនៅយាមតាមអគារហ្នឹងទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ ចំពោះពេទ្យកាលពីមុនខ្ញុំដឹងច្បាស់ មិននេះទេ ។ ប៉ុន្តែ ខ្ញុំចាំច្បាស់តែពីរនាក់ដែលខ្ញុំចាំឈ្មោះ ។ ប៉ុន្តែ ពីមុនមានដល់បួននាក់ ប៉ុន្តែខ្ញុំចាំច្បាស់តែពីរនាក់ គឺពេទ្យ អ៊ុន និង ទ្រី ហើយពីរនាក់នោះទៀត គឺខ្ញុំភ្លេចឈ្មោះទៅ ។

**ស៖** សូមអរគុណ ។ លោកបានជម្រាបប្រាប់អង្គសវនាការថា អ្នកទោសជាបុគ្គលិកស-២១ម្នាក់រត់រួច តើលោកចាំបានទេអ្នកទោសរត់រួចនោះឈ្មោះអី?

**ឆ៖** ខ្ញុំចាំបាន គឺអ្នកទោសរត់រួចនោះដែលជាបុគ្គលិកមន្ទីរស-២១ គឺឈ្មោះ ចយ ។

**ស៖** សូមអរគុណ ។ តើស-២១ មានផ្ញើររូបថតទៅគ្រប់មូលដ្ឋាន ដើម្បីចាប់អ្នកទោសនោះមកវិញនោះទេ?

**ឆ៖** ចំពោះរឿងនេះ គឺខ្ញុំអត់បានដឹងទេ ។ អានេះលើចំណាត់ការទៅលើថ្នាក់លើឯណោះទេ ។

**ស៖** សូមអរគុណ ។ លោកជម្រាបប្រាប់លោកប្រធានពីម្សិលមិញថា មានស-២១ “ក” ស-២១
“ខ” និងស-២១ “ឃ” លោកថាអត់មាន លោកអត់ស្គាល់ស-២១ “គ” ទេ ។ អ៊ីចឹងមែនទេ?

**ឆ៖** អានេះ ខាងដែលខ្ញុំបានដឹងតែស-២១ (ក) ស-២១ (ខ) និងស-២១ (ឃ) ប៉ុន្តែចំពោះផ្នែក (គ) គឺខ្ញុំមិនបានជាចាប់អារម្មណ៍ ឬក៏ (គ) នៅត្រង់ណាទេ កន្លែងណាទេ ប៉ុន្តែបើតាមការដែលនាំគ្នាហៅ គឺតែ ស-២១ (ក) (ខ) និង (ឃ) ពីព្រោះ-- ខ្ញុំសូមបញ្ជាក់កន្លែងហ្នឹងបន្តិច ការដាក់ស-២១ (ក) ស-២១ (ខ) និងស-២១ (ឃ) នេះ គឺដើម្បីងាយស្រួលគេហៅកាត់ កុំឲ្យថា ស-២១ (ក) ហ្នឹង កងសួរចម្លើយ ។ យើងអាឡូងតែសួរស-២១ (ក) ហ្នឹងខាងកងសួរចម្លើយ ហ្នឹងគេហៅកាត់ ២១ (ក) ទៅដើម្បីឲ្យងាយយល់ ។ ហើយ២ (ខ) គេហៅកាត់ ជំនួសកងការពារទៅ ហើយ (ឃ) គេជំនួសខាងស្រែទៅ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ ។ សូមអនុញ្ញាតពីលោកប្រធាន ដើម្បីសួរជនជាប់ចោទ ថាតើមានស-២១ (គ) ឬទេ? បើមាន តើស-២១ (គ) មានទីតាំងនៅត្រង់ណា? ហើយស-២១ (គ) នោះមានមុខងារ និង

ភារកិច្ចធ្វើអ្វីខ្លះ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយជនជាប់ចោទឆ្លើយតបនឹងសំណួររបស់មេធាវីរបស់លោក ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! កាលដែលខាងលើឧទ្ទេសនាមមក មន្ទីរស-២១ មានតែពាក្យថាមន្ទីរស-២១ ទេ ។ ឯចំណែកថា ពាក្យថា មន្ទីរស-២១ (ក), មន្ទីរស-២១ (ខ), មន្ទីរស-២១ (គ), មន្ទីរស-២១ (ឃ) កាលដែលយើងខ្ញុំនៅកាន់កាប់នៅទីនោះ មិនចាប់អារម្មណ៍ ទាល់តែសោះ ទើបមកឃើញពាក្យអស់នេះ នៅក្នុងសម័យកាលស៊ើបអង្កេត ។ ទន្ទឹមនេះក៏សង្កេតឃើញពាក្យប្លែកទៀតទេដែរ គឺពាក្យ ២១, ស-២២, ស-២៣ និងស-២៤ ។ តាមការស្រាវជ្រាវ ខ្ញុំក៏ទទួលស្គាល់តាមមតិខាងសហព្រះរាជអាជ្ញា ពេជ្រ សម្បត្តិ ដែលលោកថា អា ក, ខ, គ, ឃ នេះ សំដៅអគារនៅទីនោះ ប៉ុន្តែដល់មិត្ត ធី មកធ្វើសក្ខីកម្មនេះដូចជាទំនងជាង ។ សរុបមករួមទាំង ម-២១ ផង ខ្ញុំគិតថា អាទាំងអស់នេះ គឺជាស្នាដៃច្នៃប្រឌិតរបស់ ណាត កាលដែលគាត់នៅកាន់កាប់អំណាចជាប្រធានប៉ុណ្ណោះឯង ។ បើសិនជាយើងគិតតាមការយល់ដឹងរបស់ខ្ញុំ ស-២១ (ក) សំដៅភ្នំពេញ កន្លែងសួរចម្លើយ។ ឯចំណែក ស-២១ (ខ) ដូចមិត្ត ធី និយាយអ៊ីចឹងសំដៅភ្នំពេញដែរ តែកន្លែងការពារ-- កងការពារ។ ឯចំណែក ស-២១ (គ) បើតាមខ្ញុំស្មាន អានេះសុទ្ធចូលស្មានទេ គឺសំដៅចម្ការផ្តៃឈើនៅតាខ្មៅ ។ មានស-២១ ហ្នឹង វាជាទទួលកេរដំណែលពី៧០៣ មក កន្លែងចម្ការផ្តៃឈើនៅតាខ្មៅមួយកន្លែង ។ ឯចំណែក ស-២១ (គ) និង ២៤ នេះ គឺពិតជាស្រែ មិត្តហ៊ុយ ហ្នឹងហើយ គ្មានប្រែទេ ។ ក៏ប៉ុន្តែ សូមបញ្ជាក់សរុបឡើងវិញ ខាងលើទទួលស្គាល់ជាផ្លូវការទាំងអស់ហៅថា “ស-២១” តែមួយមាត់គត់នេះគឺសូមបញ្ជាក់ជូនប៉ុណ្ណោះ ។

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណ ។

**ស៖** សូមសួរទៅលើ ស្ងួស ធី បន្តទៀត ។ តើលោកធ្លាប់បានដឹងហេតុការណ៍ អ្នកទោសលោតពីអគារដើម្បីសម្លាប់ខ្លួនដែរឬទេ?

**ឆ៖** ចំពោះអ្នកទោសលោតពីលើអគារ គឺខ្ញុំមិនបានដឹងទេ ។ ដោយមូលហេតុអី គឺខ្ញុំនៅកន្លែងធ្វើបញ្ជីនេះ ។

**ស៖** សូមអរគុណ ។ លោកថាលោកមិនបានដែលទទួលបញ្ជាផ្ទាល់ពី តាឌុច ទេ អ៊ីចឹងមែនទេ?

ឆ៖ បាទ, ពិតប្រាកដមែនហើយ ។

ស៖ អ៊ីចឹង តើលោកធ្លាប់មានទៅជួប តាឌុច ផ្ទាល់ ទៅជួបៗផ្ទាល់ជាមួយ តា ឌុច ទេ? មានដែលធ្លាប់ទៅជួបផ្ទាល់ការងារអីក៏ដោយ ដែលធ្លាប់ទៅជួបផ្ទាល់?

ឆ៖ ការដែលខ្ញុំទៅជួបផ្ទាល់ គឺខ្ញុំចងចាំមិនច្បាស់ទេ ប៉ុន្តែខ្ញុំដូចមិនសូវមាន ។

[១៤:៣៤:០៧]

ស៖ ខ្ញុំសុំលោកបញ្ជាក់តទៅទៀត នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៤ លោកបានធ្វើការសម្ភាសន៍ជាមួយបុគ្គលិកមជ្ឈមណ្ឌលកម្ពុជា តើលោកនៅចាំបានទេ?

ឆ៖ នៅចាំបាន ។

ស៖ ខ្ញុំសូមអានចម្លើយតែមួយទេ សួរទៅលោក ។ បុគ្គលិកមជ្ឈមណ្ឌលកម្ពុជា ឈ្មោះ ផាន់ សុជា សួរថា ចុះដូច ឌុច ហ្នឹង គាត់អ្នកគ្រប់គ្រងនៅហ្នឹងអ៊ីចឹង ពូឧស្សាហ៍ជួបគាត់ទេ ។ លោកឆ្លើយថា អត់ទេ ខ្ញុំនៅដាច់ដោយឡែកពីគ្នា ព្រោះគេណោះគេលាក់ការណ៍ គ្រាន់តែកងការពារយើងអត់មានសិទ្ធិទៅសួរគេបានទេ មិនបាច់ដល់អ្នកសួរចម្លើយទេ អត់មានសិទ្ធិទេ ទៅស៊ីបាយ ក៏ក្រុមដោយក្រុមដែរ អត់មានទៅហូបបាយក្រុមនេះ ទៅហូបជាមួយក្រុមនោះបានទេ ។ នេះជាចម្លើយរបស់លោក តើលោកទទួលស្គាល់ និងរក្សាចម្លើយនេះនៅដដែលឬទេ? សូមលោកឆ្លើយ ។

ឆ៖ បាទ, ខ្ញុំសុំទទួលស្គាល់ ។

ស៖ សូមអរគុណ ។ លោកបានបញ្ជាក់ជូនតុលាការថា មន្ទីរសេនាធិការជាអ្នកក្តាប់មន្ទីរស-២១ ផ្ទាល់ អ៊ីចឹងមែនទេ?

ឆ៖ ចំពោះការក្តាប់របស់សេនាធិការមកមន្ទីរស-២១ នេះ គឺខ្ញុំដឹងមិនច្បាស់ទេ ប៉ុន្តែខ្ញុំដឹងរបៀបពីការធ្វើបញ្ជី គឺ ហ៊ី គេប្រាប់ឲ្យខ្ញុំដាក់ថា មន្ទីរស-២១ ក្នុងក្រឡោនសេនាធិការ។ ដូច្នេះ ខ្ញុំសន្និដ្ឋានថា សេនាធិការគឺជាអ្នកបញ្ជា អ្នកគ្រប់គ្រងលើមន្ទីរស-២១ ។

ស៖ សូមអរគុណ ។ ចុះគណៈមជ្ឈិមបានសេចក្តីថា មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា មានក្តាប់មន្ទីរស-២១ ផ្ទាល់ដែរទេ? តើលោកមានដឹងទេ?

ឆ៖ ចំពោះបញ្ហានេះ គឺខាងលើខ្ពស់ គឺខ្ញុំមិនបានដឹងទេ ។

ស៖ សូមអរគុណ ។ តើលោកដឹងទេ តើមានជនណាខ្លះ ដែលមានសិទ្ធិបញ្ជាពីលើ តាឌុច?

**ឆ៖** ចំពោះបញ្ហានេះ គឺខ្ញុំខាងលើ គឺខ្ញុំមិនអាចដឹងបានទេ ។ ពីព្រោះខ្ញុំដឹងថា ធំបំផុត លើ តាឌុច ហ្នឹងហើយ ប៉ុន្តែពីលើគឺខ្ញុំមិនអាចដឹងច្បាស់ទេ មិនដឹងអ្នកបញ្ជា លើ តាឌុច អ្នកណាគេខ្លះទេ?

**ស៖** អ៊ីចឹងលោកដែលឃើញ សុន សេន មក ស-២១ ទេ?

**ឆ៖** ខ្ញុំមិនចាំឆ្នាំមិនច្បាស់ គឺដែលគេហៅអង្គភាពទាំងមូលយកទៅរៀនសូត្រ នៅកន្លែងសាលាអប់រំនយោបាយហ្នឹង គេហៅអង្គភាពទាំងមូលទៅរៀនសូត្រ បានទៅឃើញ សុន សេន នៅកន្លែងសាលានោះ ។

[១៤:៣៨:០៦]

**ស៖** សូមអរគុណ ។ កាលពីព្រឹកមិញលោកបានជម្រាបអង្គសវនាការថា លោកធ្វើការនៅស-២១ហ្នឹង ប្រចាំការនៅកន្លែងការិយាល័យរបស់លោកម្ភៃបួនម៉ោងលើម្ភៃបួនម៉ោង ។ តើលោកបានដឹងពីហេតុការណ៍ ដែលគេបានធ្វើទារុណកម្មទៅលើអ្នកទោសដោយចងជើងព្យួរនឹងខ្សែព្ួរឡើងលើ ហើយជ្រមុជក្បាលចូលក្នុងទឹកពាង តើលោកមានដឹងព្រឹត្តិការណ៍នេះដែរឬទេ?

**ឆ៖** ដូចជាខ្ញុំសូមបញ្ជាក់អ៊ីចឹង ចំពោះព្រឹត្តិការណ៍នេះគឺខ្ញុំអត់បានដឹងទេ ពីព្រោះខ្ញុំនៅកន្លែងធ្វើបញ្ជីនេះ គឺនៅម្នាក់ឯងគឺនៅតែកន្លែងហ្នឹង អត់មានបញ្ហាដើរទៅណាទៅណីច្រើនទេ ហើយកាលអ្នកយាមគេធ្វើអី ក៏ខ្ញុំមិនសូវបានដឹងដែរ ពីព្រោះបញ្ហានេះ គឺខ្ញុំមិនជាចាប់អារម្មណ៍ទៅលើការងារខាងក្រៅទេ គឺមូលអារម្មណ៍ធ្វើការងាររបស់ឯង ឲ្យតែទាន់សភាពការណ៍តែប៉ុណ្ណោះទេ ។

[១៤:៣៩:១១]

**ស៖** សូមអរគុណ ។ អ៊ីចឹងរឿងខ្សែព្ួរដែលចងសន្ទឹង ឥឡូវនៅទុក នៅរក្សាទុករហូតមកដល់សព្វថ្ងៃហ្នឹង តើលោកមានដែលឃើញគេធ្វើទារុណកម្មអ្នកទោសណាមួយដែរ ឬក៏លោកមិនដែលឃើញទេ អាខ្សែព្ួរហ្នឹង វាសល់តាំងពីណាពីណីមក សូមបញ្ជាក់?

**ឆ៖** សូមបញ្ជាក់ដោយត្រង់ ចំពោះខ្សែព្ួរនេះ បើតាមខ្ញុំទៅ ប៉ុន្តែមិនដឹងជាគេចងពីកាលណាទេ ប៉ុន្តែខ្ញុំឃើញនៅកន្លែងហ្នឹង ពីព្រោះខ្ញុំចង់បញ្ជាក់ពីបញ្ហាធ្វើទារុណកម្ម គឺនៅក្នុងគុកគឺអត់មានកន្លែងធ្វើទារុណកម្មទេ ខ្ញុំនិយាយបញ្ជាក់តែប៉ុណ្ណឹង ពីព្រោះអ្នកទោសនៅកន្លែងជុំវិញទាំងអស់ ។

**ស៖** អ៊ីចឹងលោកអាចពិនិត្យបានទេ ថាតើព្រោះការិយាល័យរបស់លោកនេះ វានៅជាប់វាក្បែរខ្សែព្ួរហ្នឹងដែរ វាមិនមែនឆ្ងាយទេ ណ៎ែ ពីក្រោយខ្សែព្ួរហ្នឹង ហើយនិងលោកបើកទ្វារការិយាល័យរបស់លោកទៅ លោកឃើញហើយ ។ អ៊ីចឹងបានខ្ញុំចងដឹងបញ្ជាក់ថា តើលោកដែលធ្លាប់ឃើញគេមានធ្វើ

ទារុណកម្មដែរឬទេ? ក្នុងរយៈពេលដែលលោកនៅបីឆ្នាំជាងនៅហ្នឹង សូមលោកបញ្ជាក់មើល ម្តងទៀតមើល? សូមអរគុណ ។

**ឆ៖** ដូចខ្ញុំសូមបានបញ្ជាក់អ៊ីចឹង បើខ្ញុំបានឃើញគឺខ្ញុំនិយាយថាបានឃើញហើយ ។ ប្រសិនខ្ញុំមិនបានឃើញ គឺខ្ញុំនិយាយថាមិនបានឃើញហើយ ។

**សៈ** សូមអរគុណ ។ នៅស-២១ ការចាប់បញ្ជូនមនុស្សចូលមនុស្សស-២១ បើចាប់ប្តី ឬក៏ចាប់ប្រពន្ធ នោះប្រពន្ធ ឬប្តីនឹងត្រូវចាប់មកតាមក្រោយ ឬដំណាលគ្នា? តើនេះជាការកត់សម្គាល់របស់លោកតើមែនអ៊ីចឹងទេ?

**ឆ៖** ជាការកត់សម្គាល់របស់ខ្ញុំជាទូទៅ ដែលបញ្ជូនមកពីអង្គភាព ឬមន្ទីរផ្សេងៗ តែចាប់ប្តីមកហើយ គឺប្រពន្ធមកជាមួយគ្នាហើយ ។

[១៤:៤១:៣៥]

**សៈ** សូមអរគុណ ។ មុននេះលោកប្រាប់ទៅកញ្ញាមេធាវី ទី ស្រ៊ីនណា ថាអ្នកដែលមានសិទ្ធិសម្រេចឲ្យចាប់មនុស្សមានតែ តាឌុច ទេ ។ តើលោកដឹងទេ តើតាឌុច ហ្នឹង សម្រេចចាប់មនុស្សដោយអត្តនោម័តខ្លួនឯង ឬក៏មានការបញ្ជាពីលើ សូមលោកបញ្ជាក់?

**ឆ៖** ចំពោះការងារអស់នេះ គឺខ្ញុំមិនច្បាស់ទេ ។ ប៉ុន្តែខ្ញុំដឹងថា ក្នុងមន្ទីរស-២១ នេះ គឺមាន ឌុចនេះឈ្មោះខ្ពស់ជាងគេ ដូច្នេះការសម្រេចការអ្វី គឺមានតែគាត់ដែលអាចសម្រេចបាន ហើយការបញ្ជាពីលើគឺខ្ញុំអត់បានដឹងទេ ។

**សៈ** សូមអរគុណ ។ លោក ធី មួយចំណែកធំនៃការងាររបស់លោក គឺត្រួតពិនិត្យឈ្មោះអ្នកទោសត្រូវយកទៅកម្ទេច ដោយលោកជាអ្នកត្រួតពិនិត្យមុននឹងចេញដំណើរទៅកម្ទេច អ៊ីចឹងមែនទេ?

**ឆ៖** ជាការពិតហើយ ។

**សៈ** តើលោកស្រឡាញ់ការងារនេះទេ សូមលោកបញ្ជាក់?

**ឆ៖** ចំពោះការងារនេះ គឺខ្ញុំគ្មានស្រឡាញ់អ្វីបន្តិចទេ ។ ប៉ុន្តែការងារចាត់តាំង បើគេឲ្យយើងធ្វើតើយើងប៊ានប្រកែកទេ សម័យហ្នឹង? ដូច្នេះការធ្វើនេះគឺធ្វើដោយការបញ្ជា ដូច្នេះការស្រឡាញ់ការងារនេះគឺខ្ញុំគ្មានបន្តិចសោះ ។

**សៈ** សូមអរគុណ ។ បើលោកមិនស្រឡាញ់ការងារនេះ ហេតុអ៊ីក៏លោកមិនចាកចេញពីការងារនេះ?

**ឆ៖** សូមបញ្ជាក់ ចំពោះ-- ជាទូទៅថា មូលហេតុអីបានជាមិនស្រឡាញ់ការងារហើយ ម៉េចក៏ចាកចេញ? ក្នុងសម័យនោះ តើឲ្យខ្ញុំចាកចេញទៅកន្លែងណា? បើសិនជាខ្ញុំបាត់តែប្រាំនាទី គឺគេដឹងភ្លាម ហើយសម័យនោះ វាមានអត់មានផ្ទះមានប្រជាជនអីទេ គឺមានទៅសហករណ៍ តើយើងរត់ទៅណា? រត់ទៅសហករណ៍ច្បាស់ជាគេចាប់មកវិញ យើងគ្មានផ្លូវដើរទៅណារួចទេ ដូច្នេះចេះតែទ្រាំៗទៅ ហើយបើរត់ទៅណាក៏គេចមិនរួចដែរ ពីព្រោះបញ្ហានេះយើងមិនដឹងថា យើងទៅនឹងទៅជ្រកកន្លែងណា? ជ្រកសហករណ៍ សហករណ៍គេដេញភ្លាម គេចាប់បញ្ជូនមកវិញដដែល ហើយទៅអត់មានកន្លែងជ្រកសុទ្ធ ។

[១៤:៤៤:៤០]

**ស៖** អ៊ីចឹងសុំលោកបញ្ជាក់មកថែមទៀតមើល តើអ្នកធ្វើការនៅស-២១ ទាំងអស់ តើលោកដឹងទេ? សុទ្ធតែអត់ពេញចិត្តនឹងការងាររបស់ហ្នឹង ក៏ប៉ុន្តែមិនដឹងរត់ទៅណានឹងរួច តើអ៊ីចឹងមែនទេ? នៅក្នុងរបបខ្មែរក្រហមបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ តើលោកមានការភ័យខ្លាចយ៉ាងណាដែរ?

**ឆ៖** ក្នុងរបបខ្មែរក្រហម បីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ គឺចាប់តាំងពីខ្ញុំមកនៅមន្ទីរស-២១ ទួលស្លែងនេះ គឺខ្ញុំមានអារម្មណ៍ភិតភ័យរហូតទាល់បែក គឺដោយសារតែឃើញការចាប់មនុស្សហ្នឹង ហើយចាប់ហើយឃើញការដាក់ស្តែងគឺចាប់ហើយគឺស្លាប់ហើយ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

**លោក អាឡាំង វែនណឺ៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំស្តាប់ភាសាអង់គ្លេសមិនឮថា តើការបកប្រែសំណួរមួយថាតើបុគ្គលិកផ្សេងៗទៀតរបស់ស-២១ ចូលចិត្តស្រលាញ់ការងារហ្នឹងដែរឬអត់? ហើយខ្ញុំជាមេធាវីស្តាប់ចម្លើយសាក្សីអត់បាន ។ សុំសួរម្តងទៀត ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារ សូមសួរសំណួរអម្បាញ់មិញដែលមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីស្តាប់មិនបានជាភាសាអង់គ្លេសនូវចម្លើយរបស់សាក្សី សូមសួរសំណួរដែលមិនច្បាស់នេះមួយសំណួរទៀត ហើយផ្អាក ដើម្បីធ្វើការសម្រាក ។

**លោក ការ សាវុត្ថ៖**

**ស៖** លោកសួស ធី សូមលោកបញ្ជាក់ឡើងវិញ តើលោកភ្លាប់បានទេ បុគ្គលិកកម្មាភិបាលទាំងអស់នៅស-២១ សុទ្ធតែជាអ្នកមិនពេញចិត្តហ្នឹងរបបនោះ អ៊ីចឹងមែនទេ?

**ឆ៖** បុគ្គលិកមន្ទីរស-២១ ដែលធ្វើការនៅទីនោះគឺមិនពេញចិត្តហ្នឹងរបបនោះពិតប្រាកដមែន ។

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនចាំ ដោយមានហេតុផលនៃបញ្ហាខ្លះនៅសេសសល់ អំមិញនេះគឺមានសំណូមពររបស់មេធាវី ស្ទូតហ្សីនស្គី ដែលបានស្នើសុំមកអង្គជំនុំជម្រះ ហើយតាមខ្ញុំយល់ឃើញថា ចម្លើយសេចក្តីសម្រេចពីរ កាលពីម្សិលមិញយើងបានសម្រេចរួចហើយ ប្រហែលជាមិនបានគ្របដណ្តប់ទៅលើសំណើនេះទេ ។ ហើយដោយសារការប៉ុនប៉ងនៃការស្នើសុំរបស់មេធាវី ស្ទូតហ្សីនស្គី មានភាពមិនទាន់ច្បាស់លាស់អ៊ីចឹង គឺប្រគល់ភារៈនេះទៅលោកស្រីចៅក្រម ខាតរាយថ៍ ដើម្បីសួរបញ្ជាក់មុននឹងសម្រាកដើម្បីមានឱកាសពិចារណាសម្រេចនៅក្នុងអំឡុងពេលសម្រាក ។ សូមអញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ លោកស្រីមេធាវី ស្ទូតហ្សីនស្គី ខ្ញុំសុំឲ្យលោកស្រីបំភ្លឺបញ្ហាមួយចំនួនឯកសារទីមួយដែលលោកស្រីមេធាវីយោងនោះគឺD25/5/5 នោះ នៅក្នុងអត្ថបទអង់គ្លេស តើបញ្ជីអ្នកទោស ឬបញ្ជីដែលមានឈ្មោះ ភូ ហ្គុតស៊ុនថារី នៅទីនោះ ប៉ុន្តែនៅក្នុងឯកសារជាភាសាបារាំង និងភាសាអង់គ្លេសនៃឯកសារដដែលហ្នឹងយ៉ាងហោចណាស់នៅក្នុងអត្ថបទភាសាបារាំង និងខ្មែរដែលមានលេខឯកសារដូចគ្នា ឯកសារនោះគឺជាឯកសារជីវប្រវត្តិនៃឈ្មោះមនុស្សដែលលោកស្រីបានបញ្ជាក់ហ្នឹង។ អ៊ីចឹងដើម្បីឲ្យយើងច្បាស់លាស់ តើឯកសារណាមួយដែលលោកស្រីបញ្ជាក់ហ្នឹងមុននឹងយើងថយទៅសម្រាកដើម្បីមានការសម្រេចនោះ?

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

សូមអរគុណលោកស្រីចៅក្រម គឺថាមានខុសគ្នាក្នុងភាសាពីរខុសគ្នា ។ ក្នុងភាសាអង់គ្លេសគឺឃើញនៅក្នុង D25/5/12 នេះវាហាក់ដូចជានឹងបញ្ជីអ្នកទោសដដែលហ្នឹង ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ប៉ុន្តែលោកស្រីមេធាវីយោងទៅរកបញ្ជីអ្នកទោស ឬក៏ប្រវត្តិរូប?

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

ខ្ញុំយោងទៅរកបញ្ជីអ្នកទោស នេះគឺជាឯកសារតែមួយដែលថានៅក្នុងភាសាខ្មែរលេខERN 001 88877 ហើយរហូតទៅដល់ --78 នៅខាងចុង ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយធ៌៖**

សំណួរទីពីរដែលខ្ញុំសួរទៅលោកស្រីមេធាវីអំពីគោលបំណងក្នុងការដាក់លើកសំណើនេះ ដូចជាសេចក្ដីសម្រេចម្សិលមិញដែលចង្អុលបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមិនតាំងសំណួរ ឬក៏សួរសំណួរតាមសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទេ ដូច្នេះអង្គជំនុំជម្រះក៏នៅរក្សាសិទ្ធិរបស់ខ្លួន ។ ប៉ុន្តែការនោះមិនមែនជាទម្លាប់ដែលត្រូវតែធ្វើនោះទេ ។ តើលោកស្រីនៅតែចង់ឲ្យលើកឯកសារនេះមកដេញដោលចំពោះមុខតុលាការ ដើម្បីឲ្យអង្គជំនុំជម្រះដាក់ទម្ងន់វាយតម្លៃថាតើឯកសារនេះគួរយកជាភស្តុតាងដែរឬទេ?

[១៤:៥១:៣០]

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

ពិតមែនហើយ ឯកសារនេះយើងចង់ដាក់មកដេញដោលចំពោះមុខតុលាការដើម្បីឲ្យអង្គជំនុំជម្រះសម្រេចលើឯកសារនេះទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួននៅក្នុងរឿងក្ដី ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយធ៌៖**

នៅទីបំផុតនោះ D25/5/5 នោះមានឯកសារយោងមួយខ្លឹមសារយោងមួយនិយាយមានឈ្មោះបុគ្គលម្នាក់ដែលលោកស្រីចាប់អារម្មណ៍នោះ ។ តើលោកស្រីសុំឲ្យអង្គជំនុំជម្រះធ្វើការបំភ្លឺបញ្ជាក់ពីឯកសារនោះ ពីព្រោះថាលោកចង្អុលពីក្បាលទ្បានមួយ និយាយពីកាលបរិច្ឆេទនៃការសម្លាប់ ប៉ុន្តែក្នុងករណីខ្លះគឺសេចក្ដីពិស្ដារ ហើយនិងស្ថានភាពរបស់បុគ្គលដែលមានក្នុងបញ្ជីដែលលោកស្រីបញ្ជាក់នោះមិនសូវច្បាស់ ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

ទាក់ទងទៅនឹងបញ្ជីអ្នកទោសនេះដែល D25/5/5 នេះផងដែរ ហើយនៅក្នុងឯកសារមួយទៀតដែលមានស្លាស ចុងក្រោយលេខ១២ ជាអង់គ្លេស ហើយខ្ញុំចង់បានសំណួរមួយថាតើសាក្សីបានធ្វើបញ្ជីនេះដែរឬអត់? ដូចដែលយើងមើលនៅបញ្ជីមួយដែលនិយាយពីកាលបរិច្ឆេទកម្ទេចនោះ ដែលថា លោកភឹង តុន ដែលថា ផ្អាកទុកសិននោះដើម្បីឲ្យមានការបំភ្លឺ ហើយតើពាក្យនេះមានន័យដូចម្ដេច? ។ល។

ដើម្បីគោលបំណងយើងបានច្បាស់ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ពេលដែលលោកស្រីប្រើថា លោកបានធ្វើ អ៊ីចឹងដែលថា ពាក្យធ្វើហ្នឹងជាអ្នកប្រឌិតឡើង ឬក៏ជាអ្នករៀបចំធ្វើនោះអ៊ីចឹង?

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ពេលសម្រាក អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីនិងម្ភៃនាទី ចូលមកវិញដើម្បីបន្តដំណើរការនីតិវិធី ។ មន្ត្រីតុលាការសម្របសម្រួលដល់ផ្តល់ទីកន្លែងសមរម្យសម្រាប់សាក្សីសម្រាក ហើយឲ្យនាំគាត់មកកាន់សវនាការបានមុនម៉ោងកំណត់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១៤:៥៤នាទី ដល់ម៉ោង ១៥:១៨នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្ត កិច្ចដំណើរការនីតិវិធីសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះបន្តទៀត ។ ហើយមុននឹងប្រគល់វេទិកាទៅមេធាវីការពារក្តី អង្គជំនុំជម្រះប្រកាសនូវសេចក្តីសម្រេចការទទួលយកពាក់ព័ន្ធនឹងឯកសារ ដែលបានស្នើសុំដោយមេធាវី ស្ទូតហ្សីនស្តី ជាអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ចំពោះឯកសារពីរ គឺឯកសារ D25/5/13 និងឯកសារដែលមានលេខERN00188853 ឯកសារទាំងពីរនេះ អង្គជំនុំជម្រះចាត់ទុកថា បានដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ។ ដោយឡែក ឯកសារមួយទៀតខ្ញុំប្រគល់នាទីជូនទៅចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ដើម្បីធ្វើការតាំងសំណួរ ។ សូមអញ្ជើញ លោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ សូមឲ្យខាងសោតទស្សន៍ ដាក់ឯកសារភាសាអង់គ្លេសនៃឯកសារលេខ D25/5/5 សូមឲ្យសោតទស្សន៍បញ្ចាំងឯកសារនេះ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** សូមអរគុណ ។ តើសាក្សីអាចធ្វើការពិនិត្យបញ្ជីនេះ ហើយសុំឲ្យបង្វិលចុះទៅទំព័រទីពីរ ។ ខ្ញុំមានសំណួរពីរ ចង់សួរទៅកាន់សាក្សី សំណួរទីមួយ គឺតើលោកបានរៀបចំបញ្ជីនេះដែរឬទេ?

**ឆ៖** ចំពោះបញ្ជីនេះ គឺខ្ញុំអត់បានរៀបចំទេ ។

**ស៖** តើលោកអាចជម្រាបអង្គសវនាការបានទេថា ផ្អាកទុក ឬក៏ទុកសិននៅក្នុងផ្នែកប្រអប់ខាងស្តាំនៅជួរទីដប់ បានន័យថា ផ្អាកទុក ឬក៏ទុកសិន មានន័យយ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីប្រឹក្សាសាក្សី ។

**លោក គង់ សំអុន៖**

សូមអរគុណ ។ ដោយសារឯកសារនេះ មានជាភាសាអង់គ្លេសមិនមែនជាភាសាខ្មែរទេ ដូច្នេះសាក្សីប្រហែលមិនអាចពិនិត្យបានថា តើគាត់ធ្វើឬអត់? សូមឲ្យបញ្ចាំងជាភាសាខ្មែរវិញបើសិនជាចង់បញ្ជាក់ថា ជាឯកសាររបស់គាត់ឬអត់? សូមអរគុណ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

កញ្ញា ស្វូតហ្វ៊ីនស្តី តើកញ្ញាអាចឲ្យលេខ ERN ជាភាសាខ្មែរបានដែរឬទេ?

[១៥:២៣:០១]

**លោកស្រី ស៊ីលឃី ស្វូតហ្វ៊ីនស្តី៖**

ខ្ញុំសូមអភ័យទោស ។ ខ្ញុំសូមផ្តល់លេខ ERN គឺ 00188877 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ ផ្លាស់ឯកសារនេះដាក់ឯកសារលេខ ERN00188877 ដល់លេខ 00188878 លើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

មិនមែនលេខ ERN ត្រឹមត្រូវនោះទេ គឺលេខ ERN របស់ឯកសារនោះគឺ 00188877 ។

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចមានទេ? មានឯកសារនេះទេ? ឯកសារដែលមានលេខ ERN00188877 រហូតដល់ 00188878 ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** សូមអរគុណ ។ សូមឲ្យបង្វិលទៅទំព័រខាងក្រោមនៅផ្នែកខាងស្ដាំជួរលេខដប់ តើលោកសាក្សីអាចមើលឃើញអក្សរដែលសរសេរនៅក្នុងហ្នឹងទេ គឺនៅផ្នែកខាងស្ដាំជួរលេខដប់ ស្ដាំបំផុត ។

**ឆ៖** នេះគឺឯកសារហ្នឹងហើយដែលខ្ញុំសរសេរ ។

**ស៖** ដូច្នេះលោកបានសរសេររៀបចំឯកសារនេះ តើលោកអាចជម្រាបជូនអង្គសវនាការបានដែរឬទេថា? ថាតើពាក្យនៅចុងខាងស្ដាំបំផុតនោះ វាសរសេរយ៉ាងម៉េចនៅក្នុងហ្នឹង? គេដាក់យ៉ាងម៉េច? គឺនៅជួរលេខដប់ ស្ដាំ ខាងស្ដាំចុងបំផុត ។

**ឆ៖** នៅខាងស្ដាំចុងបំផុត គឺដាក់ថា "ផ្អាក" ។

**ស៖** សូមអរគុណ។ តើពាក្យហ្នឹងមានន័យយ៉ាងម៉េច ទាក់ទងទៅនឹងអ្នកទោសមួយហ្នឹង ពាក្យ "ផ្អាក" ហ្នឹងមានន័យយ៉ាងម៉េច?

**ឆ៖** ចំពោះពាក្យ "ផ្អាក" នេះបើតាមខ្ញុំចាំមិនច្បាស់ទេកាលហ្នឹង ប៉ុន្តែ បើនិយាយទៅគឺបែបខ្ញុំសន្និដ្ឋានថា ហ៊ី ជាអ្នកឲ្យចុះចំពោះដែលឈ្មោះអ្នកទោសអស់ទាំងនេះ ដែលមានពាក្យផ្អាកនេះ គឺផ្អាកនេះ គឺមានតែការផ្អាកសួរ ។

[១៥:២៨:៥៥]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។ ខាងសោតទស្សន៍ អាចបញ្ចាំងរូបភាពដើមឡើងវិញ ។ លោកប្រធានឯកសារមួយនេះ ដែលមានលេខ ERN00188877 រហូតដល់លេខ 00188878 គឺបានដាក់ដេញដោលនៅចំពោះមុខអង្គសវនាការយើងរួចហើយ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត សូមប្រគល់វេទិកាទៅមេធាវីការពារ បើមានសំណួរបន្តត្រូវសួរដល់សាក្សីរូបនេះសូមអញ្ជើញ ។

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** លោក ធី សព្វថ្ងៃនេះចំពោះការសកម្មភាពការងាររបស់លោកនៅស-២១ តើលោកគិតយ៉ាងម៉េច ឬក៏ថាតើលោកយល់យ៉ាងម៉េចដែរ ចំពោះការងារដែលលោកធ្វើនៅស-២១? សូមលោកបញ្ជាក់ ។

**ឆ៖** ខ្ញុំសូមបញ្ជាក់ ការងារសព្វថ្ងៃដែលខ្ញុំធ្វើនៅស-២១ គឺធ្វើនៅក្រោមការបញ្ជា ការចាត់តាំងរបស់ពីខាងលើទាំងអស់ ។ បើខាងលើគេធ្វើអ្វី ហើយបញ្ជាឲ្យធ្វើអ្វី គឺខ្ញុំត្រូវតែធ្វើទៅតាមហ្នឹង បើខ្ញុំមិនធ្វើទេ គឺខ្ញុំនឹងត្រូវទទួលទោស ។

**ស៖** សូមអរគុណ ។ អ៊ីចឹងសព្វថ្ងៃនេះដដែល តើលោកមានការសោកស្តាយយ៉ាងណាខ្លះចំពោះការបានចូលរួមចំណែកក្នុងការយកមនុស្ស ដែលគ្មានកំហុសទៅកម្ទេច? តើលោកមានការសោកស្តាយទេ? សូមលោកបញ្ជាក់ ។

**ឆ៖** ចំពោះសព្វថ្ងៃនេះ គឺខ្ញុំមានការសោកស្តាយជាខ្លាំង ចំពោះអ្នកទោសដែលទាំងអស់ ដែលខ្ញុំគិតទៅគឺមិនដឹងជាគ្នាមានកំហុសអីផង គឺចាប់យកមកទាំងខ្សែៗ ដូច្នេះការដែលខ្ញុំបានចូលធ្វើកន្លែងនេះ គឺសព្វថ្ងៃនេះ គឺខ្ញុំមានការសោកស្តាយជាខ្លាំងចំពោះការដែលខ្ញុំបានចូលទៅក្នុងកន្លែងហ្នឹង ។

[១៥:៣១:២៤]

**លោក ការ សាវុត្ថ៖**

សូមអរគុណ ។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ ផ្តល់ឱកាសទៅជាប់ចោទប្រសិនបើមានចង់ធ្វើការកត់សម្គាល់នូវសក្ខីកម្មរបស់សាក្សីនេះ ប្រសិនបើមានគឺ អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ ធ្វើការកត់សម្គាល់ ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ដំបូងខ្ញុំសូមជូនការសង្កេតមួយតូច ព្រោះខ្ញុំយល់ថាវាជាប្រយោជន៍ដល់ការស្រាវជ្រាវដល់អង្គសវនាការយើងអំពីបញ្ហាស-២១ ។ សំណួររបស់កញ្ញា ទី ស្រ៊ុនណា បាននិយាយថា ហ៊ី ហើយនិង ហោ មនុស្សតែម្នាក់ ឬក៏មនុស្សពីរនាក់? ខ្ញុំដឹងរឿងនេះ ហ៊ី នេះគឺជាឈ្មោះរបស់មិត្ត ហ៊ី ឈ្មោះដើម ខឹម វ៉ាក ដល់ថ្ងៃមួយនោះគាត់ទៅបានសំបុត្រដើរផ្លូវ ដែលមេខ្ញុំមេយើងខ្ញុំ មេទាំងខ្ញុំមេទាំងមិត្ត ហ៊ី នោះសរសេរសំបុត្រឲ្យ សំបុត្រដើរផ្លូវហ្នឹងលោកគ្រូ សុន សេន គាត់មិនសរសេរមិត្ត ហ៊ី ទេគាត់សរសេរមិត្ត ហោ ។ ដូច្នេះ ដើម្បីជូនជាកិត្តិយសដល់មេ មិត្តហ៊ីគាត់រក្សាពាក្យ ហោ នោះសម្រាប់ឈ្មោះគាត់ជារៀងរហូតតាំងពីពេលនោះមក ។ ដូច្នេះ ហ៊ី និង ហោ នេះពាក្យតែមួយម៉ាត់ទេ ។ ខ្ញុំជូនសក្ខីកម្មនេះដើម្បីជាពន្លឺនៃជាស្រាវជ្រាវរបស់អង្គជំនុំជម្រះយើងទាំងមូលរួមទាំងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផង ។

តទៅទៀតនេះ ខ្ញុំសូមជូនជាការកត់សម្គាល់ដែលខ្ញុំត្រូវតែធ្វើ ចំពោះរូបមិត្ត ធី ឈ្មោះពេញវិញ ឈ្មោះ សួស ធី នេះ ។ មិត្តធី នេះពិតជាបុគ្គលិករបស់មន្ទីរស-២១ ។ ខ្ញុំអត់ទាមទារឯកសារអីជាលក្ខខណ្ឌទេ ខ្ញុំស្គាល់ ។ ខ្ញុំបានឆ្លើយចំពោះសហចៅក្រមស៊ើបអង្កេត ក៏ឆ្លើយទទួលស្គាល់គាត់ជាថាគាត់ជាបុគ្គលិករបស់មន្ទីរស-២១ពេញច្បាប់ ។ ហើយក៏បានធ្វើទាំងអង្គការលេខពីរសន្លឹកជូនចៅក្រមស៊ើបអង្កេតផង ទទួលស្គាល់ថា មិត្តធី នៅខាងបញ្ជីមួយរយ ។ ខ្ញុំសូមមិនបានអាន ឬក៏យោងទៅលើកំណត់ហេតុសួរចម្លើយនោះទេ គឺកំណត់ ហើយនិងលេខ ERN នៃអង្គការលេខដែលខ្ញុំធ្វើជូនសហចៅក្រមស៊ើបអង្កេតទេ ។ នេះខទីមួយដែលខ្ញុំសូមបញ្ជាក់ ។

ខទីពីរ ដែលខ្ញុំសូមបញ្ជាក់ អំពីសក្ខីកម្មរបស់មិត្ត ធី ខ្ញុំសូមជូនជាការបំពេញថែមនូវសក្ខីកម្មខ្លះដែលមិត្តធី បានធ្វើ គឺសក្ខីកម្មពីរចំណុច ។ ទីមួយអំពីអ្នកទោសរត់ អ្នកទោសដែលរត់រួចចេញពីមន្ទីរស-២១ ខ្ញុំក្តាប់បាន គឺយោធារបស់កងពល១៧០ ពេលនោះខ្ញុំ និងមិត្តហ៊ី នាំគ្នាចេញទៅក្រៅ ខ្ញុំទើបនឹងបានទទួលតំណែងជាប្រធានថ្មីរបស់មន្ទីរស-២១ ខ្ញុំនាំគ្នាចេញទៅក្រៅ ទៅលេងមិត្តម្នាក់ដែលយើងខ្ញុំទាំងពីរនាក់ស្គាល់ ដើម្បីសុំមាន់គេយកមកចិញ្ចឹមនៅស-២១ ពេលនោះអ្នកទោសរត់ ។ អ្នកទោសហ្នឹងគឺពួក១៧០ កងពល១៧០ គេរត់ទៅអង្គភាពរបស់គេ អង្គភាពឃើញរត់ទៅ គេចាប់ទុក គេទូរស័ព្ទមកសេនាធិការ សេនាធិការបញ្ជាឲ្យប្រគល់មកស-២១វិញ ។ នេះរឿងអ្នកទោសរត់ ពិតប្រាកដដែលខ្ញុំបានដឹង ។ រឿងនេះខ្ញុំបានរាយការណ៍ជូនសហចៅក្រមសង្កេតហើយ ខ្ញុំដឹងតែរឿងនេះមួយគាត់អំពីអ្នកទោសរត់នៅស-២១ ឯចំណែកអ្នកទោសដែលជាអតីតបុគ្គលិកមន្ទីរស-២១ រត់ឈ្មោះ ចយ ខ្ញុំក្តាប់មិនបានទាល់តែសោះ ។ ជារឿងមួយដែលខ្ញុំភ្ញាក់ផ្អើលបំផុតនៅក្នុងពេលនេះ ។

ទីពីរ ខ្ញុំបានបញ្ជាក់ជូន សក្ខីកម្មទីពីរ ខ្ញុំសូមបន្ថែមថា ក្រោយពីអ្នកទោសដែលរត់ទៅអង្គភាពដើមវិញនោះ យើងខ្ញុំអត់មានបានប៉ានចាប់អ្នកណាទេ ទាល់តែក្រោយយូរមកទៀតមិត្ត ហ៊ី គាត់ឃើញសកម្មភាពមិត្ត ប៉ូច-- នៅ ប៉ូច មិនល្អ ដោយចាប់ខ្សែចង្វាក់ជាមួយនឹង នៅ ផន ហៅ សុក ចាស់ផង ហើយគាត់រាយការណ៍ជាបណ្តើរៗហូរហែឲ្យខ្ញុំ ខ្ញុំបានរាយការណ៍សុំអនុញ្ញាតពីមេ ។ នៅពេលនោះ លោកគ្រូ សុន សេន, លោកគ្រូ សុន សេន ក៏អនុញ្ញាតឲ្យខ្ញុំចាប់មិត្ត ប៉ូច កំណត់ឈ្មោះមិត្ត ប៉ូច នៅក្នុងបញ្ជីរួមរបស់ ស-២១ ស្រាប់ អ្នកទោសស-២១ ដែលត្រូវកម្ទេចស្រាប់ ។

សរុបមក កិច្ចដំណើរការចាប់បុគ្គលិក ស-២១ ដែលមានប្រភពដើមពីខាង៧០៣ក្តី ពីខាងក្រុងក្តី ខ្ញុំបានរាយការណ៍ជូនសហចៅក្រមស៊ើបអង្កេត ក៏ដូចជារាយការណ៍ជូនអង្គសវនាការយើងនេះ គឺអង្គ

ជំនុំជម្រះសាលាដំបូងយើងនេះហូរហែហើយ ខ្ញុំមិនបញ្ជាក់ថែមទៀតទេ ។ ខ្ញុំសូមបំភ្លឺជូនសក្ខីកម្មពេលនេះ តែត្រឹមតែប៉ុណ្ណេះ ។

តទៅទៀត ខ្ញុំនិយាយសក្ខីកម្មទាំងអស់របស់មិត្ត ធី ផ្សេងទៀត ខ្ញុំទទួលស្គាល់ថា សក្ខីកម្មទាំងអស់របស់មិត្ត ធី មានលក្ខណៈពិតជាមូលដ្ឋាន ។ រឿងជាច្រើនខ្ញុំមិនដឹង តែដល់មិត្ត ធី គាត់និយាយ ខ្ញុំជឿថា ជារឿងពិត ដែលកើតឡើងអំពីការអនុវត្តជាក់ស្តែងរបស់គាត់ វាទៅជាសំណុំរឿងមួយបង្គ្រប់និងសេចក្តីដែលខ្ញុំបានរាយការណ៍ ជូនអង្គសវនាការយើងហូរហែ វាធ្វើឲ្យអង្គសវនាការទាំងមូលជាតិប្រជាជនកម្ពុជាទាំងមូល លោកយល់អំពីឧក្រិដ្ឋកម្មនៅស-២១ នេះ កាន់តែបានពេញលេញមួយកម្រិតថែមទៀត ដោយសារសក្ខីកម្មរបស់មិត្ត ធី ។

ទីពីរ ខ្ញុំសូមសរសើរស្មារតីរបស់មិត្ត ធី ដែលជំនឿជឿជាក់លើសុភវិនិច្ឆ័យ នៃអង្គជំនុំជម្រះសាលាដំបូងយើង រាយការណ៍ត្រង់ ។ ជឿជាក់ថា អ.វ.ត.ក ជាយន្តការតែមួយគត់ សម្រាប់រកយុត្តិធម៌ជូនជាតិប្រជាជនកម្ពុជាទាំងមូល ក៏ដូចជាការរកយុត្តិធម៌ជូនអ្នករងគ្រោះដែលស្លាប់បាត់បង់ជីវិតទៅនៅ ស-២១ ។ នេះខ្ញុំសូមសរសើរស្មារតីគេ ដែលសហការស្មោះត្រង់ជាមួយនិងតុលាការ ។ ទុក្ខលំបាកវេទនារបស់មិត្ត ធី ខាងផ្លូវចិត្ត ខ្ញុំជឿ ជឿទាំងស្រុង អត់ប្រកែកទេ ធ្វើការជំនាន់នោះ អ៊ីចឹង ។ ខ្ញុំសង្កេតមិត្ត ធី ខ្ញុំឃើញ ខ្ញុំជឿសេចក្តីរាយការណ៍នៅពេលនេះ ។ ទន្ទឹមនេះ ខ្ញុំក៏សូមសរសើរដែរ សក្ខីកម្មរបស់គាត់ គាត់ជាកម្មាភិបាលមួយមធ្យម ។ បើនិយាយពីនៅក្នុងស-២១ គាត់ជាកម្មាភិបាលមួយមធ្យម មិនជាប់ផ្ទាល់នឹងខ្ញុំទេ គាត់ក៏មិនប៉ានភ្ជាប់នឹងខ្ញុំដែរ ព្រោះខ្ញុំខ្លួនឯង មិនចង់ឲ្យអ្នកណាមកជាប់ផ្តេសផ្តាសទេ ។ ខ្ញុំជាឧក្រិដ្ឋជនមួយខ្ពស់ជាងគេបំផុតនៅស-២១ ។ ខ្ញុំចេញមុខតែម្នាក់ឯងទទួលខុសត្រូវចំពោះអាយុជីវិតមនុស្ស ដែលបាត់បង់ទៅនៅស-២១តែម្នាក់ឯង ទាំងខាងផ្លូវច្បាប់ ទាំងខាងផ្លូវចិត្តមិនចង់ឲ្យកូនចៅណា មកជាប់ជាមួយនិងខ្ញុំ ។ ដូច្នេះ អ្នកដែលមិនជាប់ផ្ទាល់ កុំមកតាំងខ្លួនជាអ្នកជាប់ផ្ទាល់ នេះបញ្ហាមួយ ។ ហើយបញ្ហាពីរ មួយទៀត អ្នកណាដែលមិនមានប្រវត្តិរូបជាប់នៅស-២១ សូមមេត្តាកុំភ្ជាប់ខ្លួនមកស-២១ ។ សូមកុំភ្លេចថា ស-២១ ជាយន្តការឧក្រិដ្ឋរបស់ ប៉ុល ពត អ្នកឯងកុំមកភ្ជាប់ ខ្ញុំមិនឲ្យភ្ជាប់ទេ នេះគឺខ្ញុំសូមនិយាយប៉ុណ្ណេះ ។

[១៥:៤០:៣៧]

សរុបមក ខ្ញុំសរសើរគុណធម៌របស់មិត្ត ធី ហើយក៏សុំតាំងខ្លួនដាច់ខាតថា ខ្ញុំនៅតែចេញមុខទទួលខុសត្រូវតែម្នាក់ឯង ចំពោះមុខច្បាប់ ក៏ទាំងខាងផ្លូវចិត្តក្នុងឧក្រិដ្ឋកម្មទាំងអស់នៅស-២១ ។

នេះខ្ញុំសូមបញ្ចាក់ដោយខ្លីប៉ុណ្ណោះ ដោយគោរព ។

**ប្រធានអង្គជំនុំ៖**

លោក សួស ធី អង្គជំនុំជម្រះអរគុណលោក ដែលលោកបានអញ្ជើញមកផ្តល់សក្ខីកម្ម ហើយបានអត់ធ្មត់នៅក្នុងការដំណើរការនីតិវិធីនៃការផ្តល់សក្ខីកម្មនេះ ទោះបីជាមានការប្រឈមនឹងការតាំងសំណួរជាច្រើន ។ ហើយមួយថ្ងៃកន្លះកន្លងមកនេះក៏ដោយ ហើយឃើញថា លោកមានការប្រឹងប្រែង ហើយមានការចេតនានៅក្នុងការផ្តល់សក្ខីកម្ម នូវអ្វីដែលជាការពិត ដែលលោកបានដឹង បានឃើញ ជូនដល់អង្គសវនាការ ហើយដូចជាការកត់សម្គាល់របស់ជនជាប់ចោទ ដែលបានធ្វើការកត់សម្គាល់ចំពោះសក្ខីកម្មរបស់លោករួចហើយ ។ ហើយឥឡូវនេះ ដោយសារការផ្តល់សក្ខីកម្មរបស់លោក គឺបានផ្តល់ទីបញ្ចប់ហើយ ។ ដូច្នេះអង្គជំនុំជម្រះ អនុញ្ញាតឲ្យលោកវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោកវិញ ។

មន្ត្រីតុលាការសម្របសម្រួល រៀបចំគាត់ ដើម្បីប្រគល់ជូនគាត់ទៅ ជូនដល់ខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីរៀបចំគាត់ ជូនដំណើរគាត់ត្រឡប់ទៅលំនៅដ្ឋានវិញ ។

ដោយឡែកសាក្សីមួយទៀត គឺKW-15 ដែលជាសាក្សីបម្រុងសម្រាប់ថ្ងៃនេះ ក៏សូមរៀបចំជូនដំណើរគាត់ត្រឡប់ទៅកាន់លំនៅដ្ឋានដែរ ហើយឲ្យខាងអង្គភាពគាំទ្រសាក្សីអ្នកជំនាញ បញ្ជូនគាត់មកកាន់សាលសវនាការនៅថ្ងៃច័ន្ទសប្តាហ៍ក្រោយ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក ដើម្បីដំណើរការនីតិវិធីសវនាការស្តាប់សក្ខីកម្មរូបគាត់ ។

[១៥:៤៣:០៥]

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះធ្វើដំណើរការនីតិវិធីបន្តទៀត ដោយការអាននូវសក្ខីកម្មរបស់សាក្សីដែលមិនកោះអញ្ជើញគាត់មកផ្តល់សក្ខីកម្មផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះ ។ ហើយសក្ខីកម្មទីមួយ គឺដែលមានឈ្មោះ មាស ប៉េងគ្រី ឯកសារ D28/7 ERN ជាភាសាខ្មែរ 00163699 ដល់លេខ 00163703 ជាភាសាបារាំង លេខ ERN00165078 ដល់00165082 ជាភាសាអង់គ្លេស00163704 ដល់00163708 ហើយក្រឡាបញ្ជី សែ កុលវុឌ្ឍី អាននូវសក្ខីកម្មរបស់សាក្សីរូបនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

"ការិយាល័យសហចៅក្រមស៊ើបអង្កេត សំណុំរឿងព្រហ្មទណ្ឌ លេខ០០២ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦ លេខស៊ើបសួរ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី៖

ឆ្នាំ២០០៧ ខែវិច្ឆិកា ថ្ងៃទី២៩ នៅវេលាម៉ោងពីរ និងសាមសិបនាទីថ្ងៃត្រង់ នៅភូមិជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ។

យើង ងួន អ៊ឹម អក្សរកាត់ "ង.អ" ជាអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញដែលត្រូវបានចាត់ដោយដីកាចាត់ឲ្យស៊ើបសួរជំនួស របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ បានឃើញច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ។

បានឃើញវិធាន២៤, ២៨ និង៦០ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។ បានកត់ត្រាយកចម្លើយពីឈ្មោះ មាស ប៉េងគ្រី អក្សរកាត់ "ប.គ" ជាសាក្សីដែលបានផ្តល់ព័ត៌មាន ស្តីពីអត្តសញ្ញាណដូចខាងក្រោម៖

[១៥:៤៥:៥៤]

ឈ្មោះ មាស ប៉េងគ្រី ឈ្មោះបដិវត្តន៍ ឈ្មោះ មាស គ្រី កើតនៅឆ្នាំ១៩៥៥ ។

ជននេះបានប្រកាសថា ខ្លួនចេះអាន សរសេរ និងយល់ភាសាខ្មែរ ។

ជននេះបានប្រកាសថា ខ្លួនមិនចេះអាន និងសរសេរភាសាដទៃទេ ។ ហេតុដូច្នេះ ច្បាប់ដើមនៃកំណត់ហេតុនេះត្រូវបានសរសេរជាភាសាខ្មែរ ។

យើងបានជូនព័ត៌មានរួចហើយដល់ជននេះថា ការស្តាប់យកចម្លើយនេះនឹងត្រូវថតយកសំឡេង ឬរូបភាព ។ ជននេះបានប្រាប់យើងពីទំនាក់ទំនងរបស់គេជាមួយនិង ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណីថា ពុំមានពាក់ព័ន្ធទេ ។

ជននេះបានស្បថ ស្របតាមបញ្ញត្តិនៃវិធាន២៤ នៃវិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញ ។

យើងបានប្រាប់ដល់ជននេះ អំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ស្របតាមបញ្ញត្តិនៃវិធាន២៨នៃវិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញ ។

សួរ/ឆ្លើយ៖

"ង.អ" អក្សរកាត់ឈ្មោះ ងួន អ៊ឹម ជាអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ ។

ង.អ: ជាដំបូងសូមលោករៀបរាប់ពីប្រវត្តិរបស់លោកតាំងពីដើមមក ។

"ប.គ" ជាអក្សរកាត់របស់ឈ្មោះ មាស ប៉េងគ្រី ជាសាក្សី ។

ប.គ: ខ្ញុំរៀនដល់ថ្នាក់ទី១១ នៅវត្តកំពង់សំបួរ ។ ដល់ពេលមានរដ្ឋប្រហារលែងមានគ្រូបង្រៀនខ្ញុំឈប់រៀន ហើយនៅធ្វើស្រែចំការ ។ ដល់ឆ្នាំ១៩៧៣ ខ្ញុំចូលធ្វើទ័ពស្រុក១៨ ស្រុកកោះធំ នៅធ្វើជាទ័ព

ស្រុកបានជិតមួយឆ្នាំ ទើបគេបញ្ជូនឲ្យទៅធ្វើជាទ័ពភូមិភាគពិសេស ។ នៅក្នុងកងពលលេខ១២ ដែល តា ណាត និងតា ពីន ជាប្រធានកងពល ។ កាលណោះខ្ញុំមានតួនាទី ជាយុទ្ធជន ។

ង.អ: តើក្រោយថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ លោកធ្វើការនៅកន្លែងណា?

ប.គ: ពេលវ៉ៃភ្នំពេញបែកហើយ ទើបខ្ញុំមកនៅតាខ្មៅ បានប្រហែលជាបី ទៅបួនខែ ទើបគេរើសឲ្យខ្ញុំទៅរៀនបើកបរឡាន របស់កងពល៧០៣នៅភ្នំពេញ នៅម្តុំវត្តកោះ ។

[១៥:៤៨:១២]

ង.អ: រៀនបើកបររយៈពេលប៉ុន្មានខែ?

ប.គ: ពីរ ទៅបីខែដែរ ព្រោះវារៀនអត់បានទៀងទាត់ ។ កាលពីខ្ញុំរៀននោះមានគ្នាដប់ពីរនាក់ ខ្ញុំរៀនដំបូង ឲ្យរៀនបើកឡានតូច ដល់ពេលខ្ញុំចេះហើយ ទើបគេឲ្យរៀនបើកឡានធំទៀត ។

ង.អ: តើលោកមានរៀនជួសជុលធ្វើម៉ាស៊ីនឡានទេ?

ប.គ: អត់ទេ ចេះតែប៉ះកង់ឡាន និងធ្វើអ្វីបន្តិចបន្តួច ។

ង.អ: តើពេលរៀនចេះហើយ គេបញ្ជូនលោកទៅណាវិញ?

ប.គ: ពេលចេះហើយ គេបញ្ជូនខ្ញុំទៅបើកឡានឲ្យសេនាធិការ អតីតអគ្គសេនាធិការពីជំនាន់ លន់ នល់ ។ ការងារបើកឡាន កាលណោះគេឲ្យខ្ញុំដឹកប្រមូលក្រដាសស្នាមដែលសេសសល់ពីរបប លន់ នល់ យកទៅចោល ។

ង.អ: តើដល់ឆ្នាំទើបលោកចូល ស-២១?

ប.គ: ប្រហែលឆ្នាំ១៩៧៦ ទើបគេជ្រើសរើសខ្ញុំឲ្យមកនៅទួលស្លែង តួនាទីជាអ្នកបើកឡានដដែល ។

ង.អ: តើអ្នកណាជាអ្នកចាត់តាំងលោកឲ្យមក ស-២១?

ប.គ: កាលណោះ អង្គភាពរបស់សេនាធិការជាអ្នកចាត់តាំងឲ្យមក ស-២១ ពេលមកធ្វើការ គឺនៅជាមួយ ហ៊ឹម ហ៊ុយ គាត់ជាប្រធានក្រុម ។

ង.អ: តើលោកបើកឡានដឹកអ្វីខ្លះនៅ ស-២១?

ប.គ: កាលខ្ញុំនៅទីនោះ គឺខ្ញុំបើដឹកជញ្ជូនចម្រុះ អ្នកទោសក៏ដឹក ដឹកឈើធ្វើរោងក៏ដឹក ដឹកបន្លែក៏ដឹក តែអ្នកទោសខ្ញុំបានដឹកតិចទេ មិនបានច្រើនទេ ។

ង.អ: តើលោកដឹកអ្នកទោសចេញ ឬចូល?

[១៥:៥០:០៤]

ប.គ: ខ្ញុំដឹកអ្នកទោសពីរនាក់ ពីវិមានឯករាជ្យចូលទួលស្លែងម្តង ហើយដឹកអ្នកទោសមួយម្នាក់ពីបាត់ដំបងមកទួលស្លែង ។ ខ្ញុំធ្លាប់ដឹកអ្នកទោសចូលតែពីរដងទេ ពេលនោះខ្ញុំទៅជាមួយ ហ៊ីម ហ៊ុយ អ្នកទោសទាំងអស់នេះ គឺគេចាប់រួចហើយ ខ្ញុំគ្រាន់តែទៅដឹកមកទួលស្លែងតែប៉ុណ្ណោះ ។

ង.អ: តើអ្នកទោសដែលដឹកយកមកមានសភាពយ៉ាងម៉េច?

ប.គ: អ្នកទោស គឺសុទ្ធតែគេចងស្លាបសេក និងចងមុខ ។

ង.អ: ពេលលោកចុះទៅយកអ្នកទោស តើមានក្រដាសស្នាមគេបញ្ជាឲ្យទៅទេ?

ប.គ: ខ្ញុំដឹងទេ ខ្ញុំដឹងតែពីបើឡាន ។

ង.អ: ពេលដឹកអ្នកទោសមកដល់ តើលោកដឹកអ្នកទោសចូលដល់គុកទួលស្លែងតែម្តង?

ប.គ: ខ្ញុំដឹកចូលមកត្រឹមមាត់ច្រក ហើយមានកងការពារគេមកយកអ្នកទោសចូលទៅក្នុងគុក។

ង.អ: តើលោកមានធ្លាប់ដឹកអ្នកទោសចេញពីទួលស្លែងទេ?

ប.គ: ខ្ញុំធ្លាប់ដឹកអ្នកទោសចេញម្តងពីរដងដែរ ។ ដឹកយកទៅបឹងជើងឯក ពេលដឹកនោះ គឺដឹកតែពេលយប់ទេ ។

ង.អ: ពេលនោះលោកប្រើឡានអ្វី ដើម្បីសម្រាប់ដឹកអ្នកទោស?

ប.គ: ខ្ញុំប្រើឡាន*ឡង់រ៉ូវ័រ* ឡាននោះគឺបិទដំបូលជិត ។ អ្នកទោសដែលដឹកចេញនោះ មានចំនួនបួនទៅប្រាំមួយនាក់ ។

ង.អ: ពេលលោកដឹកអ្នកទោសចេញ តើអ្នកទោសមានសភាពយ៉ាងម៉េច?

ប.គ: អ្នកទោស គឺសុទ្ធតែគេចងមុខ និងចងស្លាបសេក ។ ពេលដឹកទៅដល់ជើងឯកមានគ្នាគេមួយក្រុមនៅរង់ចាំទទួលអ្នកទោសនៅទីនោះ ពេលគេអូសអ្នកទោសចុះពីឡាន យកទៅដាក់ក្នុងផ្ទះឈើមួយ នៅទីនោះហើយ ទើបខ្ញុំត្រឡប់មកវិញ ។

ង.អ: លោកនៅចាំទាល់តែគេវៃអ្នកទោសចោលហើយ ទើបត្រឡប់មកវិញ?

ប.គ: អត់ទេ ពេលដាក់អ្នកទោសចុះអស់ពីឡានហើយ ។ ពួកខ្ញុំ និងអ្នកការពារតាមឡានម្នាក់ត្រឡប់មកទួលស្លែងវិញ ។

[១៥:៥២:១០]

ង.អ: តើលោកមានស្គាល់ប្រធានក្រុមនៅជើងឯកនោះទេ?

ប.គ:  អត់ដែលស្គាល់ទេ ។ កាលពីជំនាន់នោះ គឺយើងធ្វើការងារដាច់ៗពីគ្នា សូម្បីតែពេលហូបបាយក៏ដាច់ដោយឡែកពីគ្នាដែរ ។

ង.អ:  ក្រៅពីដឹកអ្នកទោស តើលោកមានដឹកអ្វីផ្សេងទៀតទេ?

ប.គ:  ខ្ញុំធ្លាប់ដឹកឈើយកទៅធ្វើផ្ទះនៅជើងឯក  កាលពីមិនទាន់យកអ្នកទោសទៅវៃចោលនៅទីនោះបានពីរបីដង ។

ង.អ:  ពេលដឹកអ្នកទោសចេញ តើគេមានដែលណែនាំលោកយ៉ាងម៉េចខ្លះទៀតទេ?

ប.គ: គេអត់ដែលណែនាំអ្វីទេ គេគ្រាន់តែប្រាប់ថា ដឹកអ្នកទោសយកបឹកជើងឯក ហើយឲ្យមិត្តឯងមានការប្រយ័ត្នប្រយែង ។

ង.អ:  តើលោកធ្លាប់ដឹក ឌុច ទៅណាទេ?

ប.គ:  អត់ទេ ។

ង.អ:  តើលោកធ្លាប់ជួប ឌុច ទេ?

ប.គ:  ធ្លាប់ជួបនៅពេលដែល ឌុច ហៅទៅរៀនសូត្រ ឬក៏ប្រជុំនៅខាងត្បូងផ្ទះរបស់គាត់ ។

ង.អ:  តើពេលលោកដឹកអ្នកទោសយកទៅជើងឯក លោកធ្លាប់ឮអ្នកទោសស្រែក ឬយំទេ?

ប.គ: អត់ដែលឮសូរអ្វីទេ ព្រោះអ្នកទោសសុទ្ធតែស្ងៀមស្ងាំង ហើយម្យ៉ាងទៀតមានអ្នកយាមនៅជិះក្នុងឡានជាមួយអ្នកទោសដែរ ។

ង.អ:  ក្រៅពីការដឹកជញ្ជូន តើលោកមានធ្វើអ្វីផ្សេងទៀតទេ?

ប.គ:  មានការដាំបន្លែ និងចិញ្ចឹមសត្វនៅជិតលូទឹកស្អុយ ។

ង.អ:  តើនៅពេលណាទើបគេបញ្ជូនលោកមកនៅព្រៃស?

ប.គ:  ក្រោយមកប្រហែលជាឆ្នាំ១៩៧៧ ខ្ញុំបើកឡានក្រឡាប់  គេបញ្ជូនខ្ញុំឲ្យមកនៅជាមួយ  តាហ៊ុយ នៅព្រៃស ។

ង.អ:  តើព្រៃស គេឲ្យលោកធ្វើអ្វីខ្លះ?

ប.គ:  គេឲ្យខ្ញុំលើកភ្លឺស្រែ ជីកប្រឡាយ ស្ទូង ។ ដល់ពេលខ្ញុំនៅយូរទៅ គេទុកចិត្ត គេឲ្យខ្ញុំបើកឡាន សេរ៉ឹមសេ ។

ង.អ:  តើការធ្វើស្រែនៅព្រៃស មានលក្ខណៈធូរស្រាលដែរទេ?

ប.គ: ការធ្វើស្រែនៅទីនោះគឺមានផែនការតឹងរឹងណាស់ ។ គេឲ្យខ្ញុំក្រោកម៉ោងបួន ភ្លឺ ធ្វើការរហូតដល់ម៉ោងដប់មួយថ្ងៃត្រង់ ទើបសម្រាកហូបបាយថ្ងៃ បន្តិចរួចចាប់ផ្តើមធ្វើការបន្តទៀតរហូតដល់ម៉ោងប្រាំមួយល្ងាច ។ រួចហើយហូបបាយម៉ោងប្រាំពីរល្ងាច ។ ការងារគឺធ្វើទៅតាមផែនការដែលគេកំណត់ ដូច្នេះ យើងត្រូវតែធ្វើឲ្យទាន់ផែនការ ។ ពេលខ្លះខ្ញុំធ្វើការបន្ថែមពេលយប់ក៏មាន ។

[១៥:៥៤:៥៣]

ង.អ: តើការហូបចុកយ៉ាងម៉េចដែរ?

ប.គ: ការហូបចុកនៅព្រៃស គឺគេឲ្យហូបពីរពេល ។ ពេលថ្ងៃត្រង់ និងពេលល្ងាច តែមិនសូវគ្រប់គ្រាន់ទេ ដោយសារខ្ញុំបញ្ចេញពលកម្មច្រើន ។

ង.អ: តាមលោកដឹងនៅព្រៃស តើមានអ្នកជំងឺច្រើនទេ?

ប.គ: មានដែរ តែគេមានពេទ្យសម្រាប់ព្យាបាល ។

ង.អ: តើ ឌុច ធ្លាប់ចុះទៅព្រៃសទេ?

ប.គ: អត់ដែរឃើញទៅ នៅស្រែនោះមាន គឺមានតែ នុន ហ៊ុយ ទេ គាត់ជាអ្នកកាន់ក្តាប់នៅទីនោះ ។

ង.អ: តើលោកនៅព្រៃស រហូតដល់ឆ្នាំណា?

ប.គ: ខ្ញុំនៅទាល់តែបែកភ្នំពេញឆ្នាំ១៩៧៩ ។

ង.អ: តើលោកមានអ្វីចង់បន្ថែមទៀតទេ?

ប.គ: អត់មានទេ ។

ប្រសិនបើមានតម្រូវពីអង្គជំនុំជម្រះ ដើម្បីសាកសួរលោកពេលក្រោយទៀត សូមលោកជួយសហការ ។

បញ្ចប់ការស្តាប់ចម្លើយសាក្សីនៅម៉ោងបួនល្ងាចថ្ងៃខែឆ្នាំដដែល ។

ឯកសារថតចម្លងនៃកំណត់ហេតុមួយច្បាប់ត្រូវបានប្រគល់ឲ្យសាក្សីនេះ។

អានឲ្យស្តាប់ហើយ សាក្សី មិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា ឬផ្តិតមេដៃ។”

[១៥:៥៦:២២]

**ប្រធានអង្គជំនុំ៖**

អានអាក្រោយឲ្យចប់ ហត្ថលេខា ហើយនិងផ្តិតមេដៃ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

“សាក្សី មាស ប៉េងគ្រី ។ អ្នកស៊ើបអង្កេត ងួន អ៊ឹម ។”

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទ, ចំពោះសក្ខីកម្មរបស់សាក្សី មាស ប៉េងគ្រី ដែលបានអានដោយក្រឡាបញ្ជី សវនាការ សែ កុលវុឌ្ឍី ដែលលោកបានស្តាប់អម្បាញ់មិញនេះ តើលោកមានអ្វីកត់សម្គាល់លើចម្លើយនេះដែរឬទេ? អញ្ជើញលោកមេធាវីការពារ ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន សូមលោកប្រធានអនុញ្ញាតឲ្យក្រឡាបញ្ជី អានពេលដែល មាស ប៉េងគ្រី ធ្វើសេចក្តីប្រកាសនៅក្នុងពេលដែលទៅទួលស្លែងជួបគ្នានោះ ដែលចុះទៅពិនិត្យជាក់ស្តែងដល់ទីកន្លែងនេះ ។ សូមឲ្យអានអានោះសិន ចាំជនជាប់ចោទធ្វើការកត់សម្គាល់ជាក្រោយ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មានទេក្រឡាបញ្ជីអាន-- មានទេ?

ឯកសារយ៉ាងម៉េចទៅ មានលេខយ៉ាងម៉េច? ផ្តល់ឲ្យលេខ ERN មក ។

**លោក ការ សាវុត្ថ៖**

ឯកសារលេខ D48/1 ។

**ប្រធានអង្គជំនុំ៖**

មើលៗឯកសារ D48/1 ។

អានបានទេ? ឬក៏ព្រីនចេញមក សឹមអាន ក្រឡាបញ្ជី សែ កុលវុឌ្ឍី?

អានកំណត់ហេតុនេះបន្តទៀត ។

**លោកស្រី សែ កុលវុឌ្ឍី៖**

“ការិយាល័យសហចៅក្រមស៊ើបអង្កេត សំណុំរឿងព្រហ្មទណ្ឌលេខ០០២ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦ ។ លេខស៊ើបសួរ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ។

កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ឆ្នាំ២០០៨ ថ្ងៃទី២៦ ខែកុម្ភៈ នាវេលាម៉ោងប្រាំបីព្រឹក បានឃើញការបើកស៊ើបសួរលើឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋប្រឆាំង និងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញា

ទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ។

បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៥, ៦, ២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ ។

បានឃើញវិធាន៥៥.៨ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

បានឃើញដីការបស់យើងស្តីពីការចុះពិនិត្យដល់ទីកន្លែងចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៨ ។

យើង យូ ប៊ុនឡេង និង ម៉ាសែល ឡឺម៉ុងដ៍ ជាសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយមានការចូលរួមដោយលោក ហ៊ម ហែល និងលោក លី ចាន់តុលា ជាក្រឡាបញ្ជី និងលោក ប៉ាន់ ប៉ាំងដារណ្ណ និងលោក អ៊ុច ចាន់ណូរ៉ា ជាអ្នកបកប្រែដែលបានបកប្រែរួចហើយ នៃអង្គជំនុំជម្រះវិសាមញ្ញ ។

យើងបានចុះទៅដល់កន្លែងមណ្ឌលប្រល័យពូជសាសន៍ជើងឯក ដែលស្ថិតនៅចម្ងាយដប់ប្រាំគីឡូម៉ែត្រ ខាងទិសនិរតីទីក្រុងភ្នំពេញ នៅក្នុងខេត្តកណ្តាល ។ នៅទីកន្លែងនោះយើងឃើញមាន លោក ស្រី ជាលាង និង លោក រ៉ូប៊ឺត ពើទីត ជាសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ ។ លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលចូលរួមដោយសហមេធាវីរបស់ខ្លួនលោក ការ សាវុត្ថ និងលោក ហ្វ្រង់ស្វ័រ រូ ។

សាក្សី មាស ប៉េងគ្រី, ហ៊ឹម ហ៊ុយ, [redacted] ។ លោក ហ្សរ៉េនឡឺស៊ិក ដែលជាអ្នកជំនាញការចាត់តាំងដោយដីកាចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ ក៏មានវត្តមាននៅទីកន្លែងនោះដែរ ។”

**ប្រធានអង្គជំនុំ៖**

ម៉េចហើយមានបញ្ហាអីទេ?

ឈប់សិន១ កុំអាលអាន វុឌ្ឍី ។

*(ចៅក្រមកពិភាក្សាគ្នា)*

[១៦:០៧:២៥]

ឥឡូវនេះ អង្គជំនុំជម្រះសូមជម្រាបដល់ភាគី ហើយនិងសាធារណជនបានជ្រាបថា ដោយសារឯកសារក្រោយនេះ មានការពាក់ព័ន្ធផ្ទាល់ទៅនឹងសាក្សីមួយចំនួនទៀត ដែលត្រូវការការពារនូវអត្ត-សញ្ញាណមុនពេលកោះហៅសាក្សីនោះមកធ្វើសក្ខីកម្ម ។ ហេតុដូច្នេះ គឺឯកសារដែលស្នើសុំឲ្យមានការអានដោយក្រឡាបញ្ជីសវនាការ ដោយមេធាវីការពារក្តីនោះអង្គជំនុំជម្រះមិនអាចដំណើរការបានទេ

ហើយដោយសារកាលវិភាគដែលបានគ្រោងទុក គឺអង្គជំនុំជម្រះរៀបចំកាលវិភាគសម្រាប់រសៀលនេះ គឺអាននូវចម្លើយសាក្សីដែលបានផ្តល់សក្ខីកម្មចំនួនបីនាក់ ដោយហេតុផលពាក់ព័ន្ធទៅនឹងវិធានការការពារសាក្សី ដែលមិនទាន់បានមកធ្វើសក្ខីកម្ម ហើយដែលមានឈ្មោះនៅក្នុងកំណត់ហេតុ អង្គជំនុំជម្រះមិនទាន់បានធ្វើការពិនិត្យដើម្បីធ្វើការដកចេញ ឬក៏ប្រើរហស្សនាមនៅក្នុងកំណត់ហេតុដើម្បីអានទេនោះ ដែលវាធ្វើឱ្យប៉ះពាល់ដល់វិធានការការពារ ។ ហេតុដូច្នេះ អង្គជំនុំជម្រះផ្អាកនូវក្នុងការអាននូវសក្ខីកម្មរបស់សាក្សីនេះត្រឹមនេះ ហើយការដំណើរនៃការអាននូវសក្ខីកម្មសាក្សីបន្តបន្ទាប់ទៀត នឹងកំណត់កាលបរិច្ឆេទសម្រាប់ការអានចម្លើយសាក្សីនៅពេលក្រោយ។ ដូច្នេះ ថ្ងៃនេះអង្គជំនុំជម្រះសម្រេចផ្អាកដំណើរសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ។ ហើយដំណើរការសវនាការអង្គជំនុំជម្រះសម្រេចលើកទៅបន្តនូវថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ ចាប់ពីវេលាម៉ោងប្រាំបួនព្រឹកទៅ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឱ្យនាំគាត់មកកាន់សាលសវនាការនូវថ្ងៃច័ន្ទ ក្រោយឱ្យបានមុនម៉ោងប្រាំបួនព្រឹក ៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការផ្អាកនៅម៉ោង ១៦:១០នាទី]*